ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 18-May-2012, 11:51
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២**

**ម៉ោង ០៩:០៨ នាទី**

**សវនាការលើកទី៦១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក មៃឆល ផេសមិន
*(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី
*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោក គីម ម៉េងឃី

លោក បាណាបេ ណេគ្វី
*(Mr. Barnabé NEKUIE)*

លោក ប៉ាស្កាល់ អូប៊ីង
*(Mr. Pascal AUBOUIN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ពាន ឃាន (TCW-504) | ខ្មែរ |
| លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សារបស់សាក្សី) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ពាន យាន** (TCW-504)

សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖........................................................ ទំព័រ ២

សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្តើមពី៖................................................ ទំព័រ ២៦

សួរដោយលោក ពេជ អង្គ ផ្តើមពី៖ ........................................................................ ទំព័រ ៣៣

សួរដោយលោក សុន អរុណ ផ្តើមពី៖........................................................................ទំព័រ ៤២

សួរដោយលោក អេនឌ្រូ អ៊ីនូហ្ស៊ី ផ្តើមពី៖ ................................................................... ទំព័រ ៥១

សួរដោយលោក អាង ឧត្តម ផ្តើមពី៖ .......................................................................ទំព័រ ៦៩

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី៖ ..................................................................ទំព័រ ៧៤

សួរដោយលោក គង់ សំអុន ផ្តើមពី៖........................................................................ ទំព័រ ៨៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៨:២៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ និងនៅថ្ងៃស្អែកតាមកាលវិភាគដែលបានគ្រោងទុក គឺបន្តការស្តាប់សក្ខីកម្មសាក្សី ពាន ឃាន ដែលបានតាំងសំណួរដោយតំណាងសហព្រះរាជអាជ្ញាមួយរយៈពេលរួចហើយ ហើយនិងបន្តតាំងសំណួរដោយតំណាងសហព្រះរាជអាជ្ញានៅពេលវេលាដែលសេសសល់សម្រាប់កិច្ចដំណើរការចាប់ផ្តើមដំបូងនេះ។ ហើយនិងតាមលំដាប់លំដោយនៃភាគីដែលពាក់ព័ន្ធនៅក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ ព្រមទាំងអង្គជំនុំជម្រះផង។

លោកស្រី សែ កុលវុឌ្ឍី តើ-- សូមរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ពេលនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន។ ដោយឡែកសាក្សី ពាន ឃាន មានវត្តមានរង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ មន្ត្រីរដ្ឋបាលតុលាការសូមអញ្ជើញសាក្សី ពាន ឃាន ព្រមទាំងមេធាវីប្រឹក្សាផងអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទុបសវនាការ។

[០៩:១០:១១]

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:១១:៣៥]

**ប្រធានអង្គជំនុំ៖**

សួស្តីលោក ពាន ឃាន! ហើយនៅពេលនេះឃើញទឹកមុខដូចជាស្រស់ស្រាយសង្ឃឹមថា លោក ពាន ឃាន នឹងមានសុខភាពល្អជានិច្ចនិរន្តរតទៅ ហើយនិងនៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មនេះនឹងអាចដំណើរការប្រព្រឹត្តទៅបានល្អ។

មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអង្គជំនុំជម្រះសូមជម្រាបជូនតំណាងសហព្រះរាជអាជ្ញាអន្តរជាតិថា សវនាការកាលពីព្រឹកថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១២ កន្លងទៅនេះបានប្រព្រឹត្តទៅអស់រយៈពេលមួយម៉ោងសាបសិបនាទី គឺមួយភាគបួននៃពេល រយៈពេលសម្រាប់សវនាការមួយថ្ងៃតាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាក្នុងការបន្ថែមរយៈពេលសួរសាក្សី ពាន ឃាន អង្គជំនុំជម្រះបានសម្រេចប្រគល់ជូនតាមសំណើសុំ តែដោយសារតំណាងសហព្រះរាជអាជ្ញាអន្តរជាតិហ្នឹងគឺបានសួរដេញដោលអស់រយៈពេលមួយម៉ោងសាមសិបនាទីរួចហើយ។ ដូច្នេះ តំណាងសហព្រះរាជអាជ្ញានៅសល់ពេលវេលាតែ ចាប់ពីពេលនេះទៅរហូតដល់ពេលសម្រាកប៉ុណ្ណោះ គឺសម្រាកនៅខាងមុខនេះ។ សូមតំណាងសហព្រះរាជអាជ្ញាជ្រាប ហើយអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

[០៩:១២:៥៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ មុនពេលដែលយើងចាប់ផ្តើមដេញដោលទៅលើសាក្សី គឺមានចំណុចមួយចំនួនដែលខ្ញុំសូមលើកឡើងជូនអង្គជំនុំជម្រះ និងភាគីសំខាន់ៗរួមជាមួយនឹងសហសេវិករបស់ខ្ញុំដែលកំពុងតែនៅជាមួយខ្ញុំ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**បន្តសួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

សូមគោរពសួស្តី អរុណសួស្តីលោក ពាន ឃាន។ សូមអរគុណដែលលោកមកផ្តល់សក្ខីកម្មសាជាថ្មី ដើម្បីជួយស្វែងរកការពិតដល់អង្គជំនុំជម្រះសាលាដំបូង។ អ្វីដែលខ្ញុំចង់ធ្វើនាពេលនេះ គឺថាយើងបានសម្រាកពីរសប្តាហ៍រួចមកហើយចាប់ពីពេលដែលលោកបានមកផ្តល់សក្ខីកម្មនៅទីនេះ។ ហើយខ្ញុំចង់មើលចំណុចអង្គហេតុមួយចំនួនដែលលោកបានលើកឡើងកាលពីលើកមុន ដើម្បីឲ្យព័ត៌មានមួយចំនួនលម្អិតសម្រាប់ពេលវេលារបស់ខ្ញុំដែលនៅសល់។

**ស៖** លោកបាននិយាយជាមួយនឹងយើងខ្ញុំថា នៅពេលចាប់ខ្លួន កុយ ធួន លោកធ្វើការនៅច្រាំងចំរេះ តើអ៊ីចឹងដែរឬទេ?

[០៩:១៤:១៤]

**លោក ពាន ឃាន៖**

**ឆ៖** ខ្ញុំពេលនុ៎ង ខ្ញុំនៅច្រាំងចំរេះពិតមែន ប៉ុន្តែមិនធ្វើការងារអីទេ គ្រាន់ថានៅមើលថែទាំ ជម្រះស្មៅជម្រះអីនាយអាយជុំវិញផ្ទះគេហ្នឹង។ ប៉ុណ្ណឹងទេ។

**ស៖** លោកក៏បាននិយាយប្រាប់យើងខ្ញុំថា ក្នុងអំឡុងពេលនេះ លោកក៏បានមើលថែទាំ កុយ ឃួន និងផ្តល់យកអាហារទៅឲ្យគាត់ផងដែរ តើត្រឹមត្រូវដែរឬទេ ខ្ញុំគ្រាន់តែចង់បញ្ជាក់ទេ ត្រង់ចំណុចហ្នឹង? តើអ៊ីចឹងដែរឬទេ?

[០៩:១៥:០២]

**ឆ៖** ចំណុចនេះ ប្រាកដជាត្រឹមត្រូវដូច្នោះមែន។

**ស៖** សូមអរគុណ។ ដើម្បីឲ្យយើងយល់ទាំងអស់គ្នា លោកនិយាយថា ច្រាំងចំរេះគឺជាកន្លែងធ្វើការរបស់ កុយ ឃួន។ ដូច្នេះ តើលោកអាចរៀបរាប់ជូនអង្គជំនុំជម្រះបានដែរឬទេ? ច្រាំងចំរេះហ្នឹងគឺមើលទៅវាទីតាំងហ្នឹងយ៉ាងម៉េចដែរ? វាជាផ្ទះមួយតូច ឬក៏យ៉ាងម៉េច? សូមឲ្យលោកជួយរៀបរាប់។

**ឆ៖** តាមខ្ញុំការពិនិត្យឃើញនៅពេលនេះ ច្រាំងចំរេះមិនមែនជាការងារអីធំដុំទេ។ គ្រាន់តែជាការស្នាក់នៅបណ្តោះអាសន្ន មួយរយៈៗប៉ុណ្ណោះ។

**ស៖** ដើម្បីខ្ញុំចង់សួរបញ្ជាក់លោក ថាតើច្រាំងចំរេះនុ៎ង គឺជាកន្លែងតូច ឬក៏កន្លែងមួយធំ ហើយមានមនុស្សធ្វើការនៅកន្លែងនោះប៉ុន្មានដែរ តាមដែលលោកដឹង?

**ឆ៖** កន្លែងច្រាំងចំរេះគឺកន្លែងតូចទេ មិនមានជាអីធំដុំទេ។ មនុស្សប្រហែលជា២០ទៅ៣០នាក់ប៉ុណ្ណឹងទេ រស់នៅកន្លែងនោះ។

**ស៖** តើមនុស្សទាំងអស់នោះ ធ្វើការឲ្យ កុយ ឃួន ឬក៏មានអ្នកផ្សេងដែលមកពីមន្ទីរផ្សេងមកធ្វើការនៅទីនោះ?

[០៩:១៧:០៥]

**ឆ៖** អ្នកទាំងនោះ គឺនៅជាមួយនឹង កុយ ឃួន ទាំងអស់។ អត់មានអ្នកក្រៅទេ។

**ស៖** សូមអរគុណ។ លោកក៏បានជ្រាបជូនយើងខ្ញុំផងដែរថា ក្រោយ កុយ ឃួន ហៅ ធុច ត្រូវបានចាប់ខ្លួន លោកនៅច្រាំងចំរេះរយៈពេលពីរខែបន្តទៀត។ ដូច្នេះ តើលោកអាចរៀបរាប់បានដែរឬទេ តើមានអ្វីកើតឡើងក្រោយពី កុយ ឃួន បាត់ខ្លួននោះ?

**ឆ៖** ខ្ញុំដូចជាមិនឃើញព្រឹត្តិការណ៍អ្វីចម្លែកទេ។ ការរស់នៅរបស់ខ្ញុំជាធម្មតា ដូចសព្វដង។

**ស៖** តើលោកធ្វើម្ដេចបានជាលោកដឹងថា ធុច នោះ ត្រូវបានគេចាប់ខ្លួន?

**ឆ៖** ពេលនោះ ខ្ញុំដឹងតាមមិត្តភក្តិប្រាប់ និយាយប្រាប់ខ្ញុំ ទើបបានខ្ញុំដឹង។

**ស៖** តើមិត្តភក្តិហ្នឹង រស់នៅជាមួយលោកនៅច្រាំងចំរេះ ឬក៏យ៉ាងម៉េច?

**ឆ៖** គេរស់នៅជាមួយគ្នា នៅច្រាំងចំរេះពិតមែន។

**ស៖** លោកក៏បានឆ្លើយនៅថ្ងៃទី០២ ខែឧសភា ថាលោកៗមានរយៈពេលមួយនោះ ធ្វើការឲ្យយន់ ប្រពន្ធរបស់ កុយ ឃួន ដែលជាប្រធានតំបន់៣២ ថាតើគាត់ហ្នឹងមាននៅច្រាំងចំរេះដែរឬទេ ប្រពន្ធរបស់គាត់ហ្នឹង មាននៅច្រាំងចំរេះដែរឬទេ?

[០៩:១៩:២៨]

**ឆ៖** ក្នុងពេលនោះ អត់ឃើញប្រពន្ធគាត់ទៅនៅហ្នឹងទេ។

**ស៖** អ៊ីចឹង គាត់នៅឯណាវិញទៅ?

**ឆ៖** ខ្ញុំក៏មិនបានដឹងថា ប្រពន្ធគាត់នៅកន្លែងណាទេ ក្នុងពេលនោះ។

**ស៖** តើលោកធ្លាប់បានជួបគាត់ ឬក៏បាននិយាយជាមួយនឹងគាត់ ក្រោយពេលបាត់ខ្លួន កុយ ឃួន ដែរឬទេ?

[០៩:២០:០៧]

**ឆ៖** តាំងពីបាត់ខ្លួន កុយ ឃួន ខ្ញុំអត់ដែលបានជួបមុខគាត់ទាំងអស់។

**ស៖** ឥឡូវនេះ គឺលោកបាននិយាយថា លោកបានឮថា កុយ ធួន ចាប់ខ្លួនដោយអង្គការ។ តើលោកមានឮព័ត៌មានថាមានអ្វីកើតឡើងទៅលើប្រពន្ធរបស់គាត់ដែរឬទេ? ឬក៏លោកបានទទួលព័ត៌មានដែរឬទេថា មានការកើតឡើងអ្វីចំពោះប្រពន្ធរបស់គាត់នោះ?

**ឆ៖** ខ្ញុំមិនបានទទួលដំណឹងអ្វីទាំងអស់ក្រោយពីចាប់ខ្លួន កុយ ឃួន។ មិនដឹងជាគាត់ទៅណា ឬកន្លែងណា គាត់ស្លាប់ ឬរស់ ក៏ខ្ញុំមិនដឹងដែរ។

**ស៖** សូមអរគុណ។ ខ្ញុំ ដើម្បីប្រតិចារឹកនៅពេលដែលយើងនិយាយអំពីគាត់នេះ គឺថាបុគ្គលប្រពន្ធនេះ បុគ្គលនេះមានចុះបញ្ជីនៅក្នុងលេខបញ្ជីលេខ ស-២១ លេខ12149 ត្រង់ឯកសារ E3/342 លេខ ERN គឺ 00330124។ លោក ពាន ឃាន លោកបានឆ្លើយនៅថ្ងៃ០៣ ឧសភា ថាអង្គការបានផ្សព្វផ្សាយតាមវិទ្យុថា កុយ ឃួន គឺជាជនក្បត់ផ្ទៃក្នុង ហើយ កុយ ឃួន ចូលជាមួយនឹង សេ.អ៊ី.អា។ នៅពេលដែលលោកស្ដាប់ឮការផ្សព្វផ្សាយដូច្នេះ តើលោកមានអារម្មណ៍យ៉ាងម៉េចដែរនៅពេលនោះ?

[០៩:២២:២៨]

**ផៈ** នៅពេលនោះ ខ្ញុំចេះតែមានការព្រួយបារម្ភ។ ព្រួយបារម្ភទីមួយដែលថា នឹកគាត់ ធ្លាប់រស់នៅជាមួយគ្នា។ ព្រួយបារម្ភទីពីរត្រង់ថា ខ្ញុំនៅពេលនោះ មិនដឹងទៅនៅកន្លែងណាទៀត បើអត់ពីគាត់ ព្រោះធ្លាប់នៅជាមួយគាត់។ ខ្ញុំមានតែប៉ុណ្ណឹងទេ។

**សៈ** លោកក៏បាននិយាយជាមួយនឹងយើង ប្រាប់យើងខ្ញុំនៅថ្ងៃ០៣ ឧសភា ផងដែរថា លោកបានឮថា ក្រោយពេលចាប់ កុយ ឃួន នោះ បុគ្គលិកក្រោមបង្គាប់របស់គាត់ហ្នឹងក៏នឹងត្រូវគេចាប់ខ្លួនផងដែរ។ ដូច្នេះនៅពេលដែលឮអ៊ីចឹង តើលោកមានភ័យខ្លាចថាគេនឹងអាចចាប់ខ្លួនលោកដែរឬទេ នៅពេលនោះ?

**ផៈ** ក្នុងអារម្មណ៍ខ្ញុំ ខ្ញុំប្រាកដជាព្រួយអ៊ីចឹងមែន ព្រោះចរិត-- មានអារម្មណ៍ថាភ័យខ្លាចដូចអ្នកដទៃដែរ។ មិនដឹងគេយកទៅណា។

**សៈ** សូមអរគុណ។ នៅពេលនេះ ខ្ញុំសូមសួរចំណុចផ្សេង។ លោកក៏បាននិយាយនៅថ្ងៃទី០២ ខែឧសភា ផងដែរថា នៅពេលដែលលោកចូលបដិវត្តន៍ លោក-- គេឲ្យលោកសរសេរប្រវត្តិរូបផ្ទាល់ខ្លួន។ តើក្រៅពីរយៈពេលនោះ តើលោកមានធ្លាប់សរសេរប្រវត្តិរូបផ្ទាល់ខ្លួនផ្សេងទៀតដែរឬទេ នៅក្នុងអំឡុងពេលណាមួយក្រៅពីពេលដែលគេឲ្យសរសេរម្តងនោះរួចមកហើយនោះ?

**ផៈ** ចំណុចនេះ ខ្ញុំចាំមិនបាន ខ្ញុំចាំបានតែម្តងហ្នឹង។

[០៩:២៥:១៥]

**សៈ** តើលោកដឹងដែរឬទេថា-- តើលោកមានដឹងដែរឬទេថា មិត្តរបស់លោក ឬក៏បុគ្គលិកផ្សេងទៀតនៅក្នុងទីក្រុងភ្នំពេញនោះ ត្រូវបានគេឲ្យសរសេរប្រវត្តិរូបផងដែរ នៅពេលនោះ?

**ផៈ** ខ្ញុំអត់បានឃើញ និងបានយល់ទេ ព្រោះរឿងអ្នកផ្សេងក៏ខ្ញុំមិនដែលបានឃើញរឿងរបស់គេដែរ។ អត់បានដឹង។

**សៈ** ក៏ប៉ុន្តែលោកបាននិយាយប្រាប់យើងខ្ញុំថា គេបានឲ្យលោកចូលរួមនៅក្នុងវគ្គស្វ័យទិតៀន និងវគ្គទិតៀន។ ដូច្នេះ តើមានការពិភាក្សាអ្វីខ្លះដែរ នៅក្នុងកិច្ច-- នៅពេលប្រជុំស្វ័យទិតៀនហ្នឹង ប្រជុំទិតៀននោះ?

[០៩:២៦:៣៤]

**ផៈ** ក្នុងពេលប្រជុំទិតៀន និងស្វ័យទិតៀននោះ ដល់រាល់ពេលល្ងាច ក្នុងមួយថ្ងៃគេត្រួតពិនិត្យ

ត្រូវត្រួតពិនិត្យគុណសម្បត្តិ និងការខ្វះខាតដែលធ្វើបានក្នុងមួយថ្ងៃ។ ហើយបើថាយើងអត់មានការខ្វះខាតអី អត់មានខុសឆ្គងអី ចាត់ទុកថាជាការគុណសម្បត្តិ អាហ្នឹងគេអត់ទិតៀនយើងទេ។ ហើយបើយើងមានការខុស ខ្វះចន្លោះត្រង់ណាដែលមិនត្រូវតាមបំណង ឬបំពេញភារកិច្ចក្នុងមួយថ្ងៃហ្នឹងមិនបានសម្រេចអ្វីមួយ អាហ្នឹងគេទិតៀនកសាង រំឭកឲ្យយើង។

**ស៖** ប្រសិនបើមានអ្នកណាម្នាក់នៅតែធ្វើខុសទៀត តើគេមានដាក់ទណ្ឌកម្មទៅលើកំហុសនោះដែរឬទេ?

**ឆ៖** តាមខ្ញុំចំណាំមើលពេលនោះ ទាំងខ្លួនខ្ញុំក៏ដោយ ទាំងអ្នកដទៃក៏ដោយ ដូចមិនដែលឃើញធ្វើទណ្ឌកម្មអីទេ គ្រាន់តែថាបើនៅមានកំហុស មិនបានកែប្រែមិនអស់ គេនៅតែទិតៀន គេនៅរំឭកឲ្យយើងកែប្រែកំហុសហ្នឹងជាច្រើនលើក។

[០៩:២៨:៤៣]

**ស៖** លោក ពាន ឃាន លោកស្នាក់នៅទីក្រុងភ្នំពេញក្នុងចន្លោះឆ្នាំ៧៥ ទៅដល់ ៧៩។ តើលោកអាចរៀបរាប់ពិពណ៌នាថាក្នុងអំឡុងចន្លោះឆ្នាំនោះ ស្ថានភាពទីក្រុងភ្នំពេញនោះយ៉ាងម៉េច? ហើយមានប្រជាជនរស់នៅក្នុងទីក្រុងភ្នំពេញដែរឬទេ? ហើយប្រជាជនអាចធ្វើការផ្លាស់ទី ធ្វើដំណើរទីកន្លែងមួយទៅកន្លែងមួយបានដែរឬទេ?

**ឆ៖** ក្នុងអំឡុងពេលនោះ ខ្ញុំវាមិនបានចាប់អារម្មណ៍ទេ ឃើញពីសភាពធម្មតា។ អត់ឃើញប្រជាជនទៅណាមកណាទៀតទេ ក្រោយពីរំដោះទៅ ដែលខ្ញុំឃើញ ឃើញពេលចូលរំដោះដំបូងតែប៉ុណ្ណឹងទេ ក្រោយមកអត់ដែរឃើញអីទាំងអស់។

[០៩:២៩:៥៦]

**ស៖** នៅពេលដែលលោកនិយាយថា ក្រោយពីរំដោះភ្នំពេញភ្លាមនោះ លោកបានឃើញប្រជាជនទាំងក្រុមៗត្រូវបានគេជម្លៀស នៅថ្ងៃទី១៧ ខែមេសា នោះតែម្តង ឬក៏យ៉ាងម៉េច តាមអ្វីដែលលោករៀបរាប់នោះ?

**ឆ៖** ពេលនោះខ្ញុំឃើញ ថ្ងៃរំដោះ១៧ មេសា ហ្នឹង ដោយសារតែខ្ញុំដើរពី-- ធ្វើដំណើរពីឧដុង្គមកក្រុងភ្នំពេញហ្នឹង ឃើញគេហូរហែតាមផ្លូវ។ ដល់ទីក្រុងភ្នំពេញ ដល់ខ្ញុំចូលទៅដល់ទីក្រុងភ្នំពេញមានភាពស្ងាត់ជ្រងំ។ តែប៉ុណ្ណឹងទេ។

**ស៖** លោកបានប្រាប់យើងថា លោកដឹងពីរឿងហ្នឹងពេលក្រោយថា ស្ថានភាពហ្នឹងជាធម្មតា ដែលអ្វីដែលលោកបានដឹងហ្នឹងថាតើអ្នកដែលចាកចេញពីទីក្រុង គឺសុទ្ធតែអ្នកដែលគេជម្លៀសចេញពីទីក្រុងភ្នំពេញ តើគេត្រឡប់មកវិញទេ បាទ ក្រោយពីថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ តើអ្នកទាំងនោះបានត្រឡប់មកភ្នំពេញវិញដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹង ថាគេត្រឡប់មកវិញ ឬគេទៅនៅទីណាតាមស្រុកខេត្តណាទៀត ព្រោះខ្ញុំមិនបានដឹងដែរ។

**ស៖** ដូច្នេះ ការរស់នៅក្នុងទីក្រុងភ្នំពេញកាលពីពេលនោះ តើលោកផ្ទាល់តើលោកអាចដើរហើរដោយសេរីទៅកន្លែងណាផ្សេងទៀតនៅក្នុងទីក្រុងដូចដែលលោកចង់ដើរបានទេ?

[០៩:៣២:២១]

**ឆ៖** ក្នុងពេលនោះ ខ្ញុំមិនអាចដើរតាមសេរីបានទេ គឺថា ព្រោះមិនទាន់មានបទបញ្ជាការចាត់តាំងពី ប៉ង់ ឬ លីន ថាទៅយកបន្លែកន្លែងនោះ ទៅយកអង្ករកន្លែងនេះ ដូចថាមកយកអង្ករនៅផ្សារថ្មី ឬក៏ទៅច្រាំងចំរេះ ឬព្រែកព្នៅអីអ៊ីចឹងទៅ ទៅរកបន្លែអីយកមកកន្លែង ក-១ ហ្នឹង ទើបខ្ញុំដើរបាន។

**ស៖** ចុះអ្នកដែលធ្វើការជាមួយលោកវិញ ឬក៏អ្នកផ្សេងទៀតដែលធ្វើការនៅក-១, ក-៣ ហើយនិងមន្ទីរផ្សេងៗទៀតដូចលោកហ្នឹង តើពួកគេអាចដើរហើរដោយសេរីបានទេ ឬក៏គេត្រូវការតែមានការអនុញ្ញាត ឬក៏លិខិតដើរហើរទើបបានដើរបាន?

**ឆ៖** រឿងអ្នកក្រៅពីខ្ញុំក៏ខ្ញុំក្លាប់មិនបានដែរ ប៉ុន្តែខ្ញុំគ្រាន់តែជម្រាបថា ដែលខ្ញុំឃើញចំពោះរូបខ្ញុំគឺអ៊ីចឹង។

**ស៖** សូមអរគុណលោក ពាន ឃាន។ នៅពេលនេះឆ្នាំ១៩៧៥ ដល់៧៩ គឺចន្លោះហ្នឹងនៅក្នុងទីក្រុងភ្នំពេញ តើលោកធ្លាប់បានកត់សម្គាល់ដែរឬទេ ថាតើអ្នកធ្វើការជាមួយលោក ឬក៏អ្នកណាម្នាក់ត្រូវបានគេដកចេញ ឬក៏គេយក ឬក៏បាត់ខ្លួនពីកន្លែងធ្វើការដែរឬទេ តាមដែលលោកសង្កេតនោះ?

**ឆ៖** ក្នុងពេលនោះ ខ្ញុំដឹងតែទីមួយរឿងចំពោះ កុយ ឃួន ទីពីររឿង ប៉ង់។ ខ្ញុំចាំច្បាស់តែប៉ុណ្ណឹងទេ ដែលក្រៅពីហ្នឹងទៀត ខ្ញុំអត់បានដឹងដែរ។

[០៩:៣៥:០៥]

**ស៖** ខ្ញុំចង់ឲ្យដឹងថា តើខ្ញុំយល់ច្បាស់ពីចម្លើយរបស់លោកដែរឬទេ? តើលោកចង់ប្រាប់ខ្ញុំថាក្រៅពីអ្វីដែលលោកបានដឹងពីការបាត់ខ្លួនរបស់ កុយ ឃួន ហើយនិង ប៉ង់ ហ្នឹង ខ្ញុំចង់សួរថា តើលោក

បានដឹង ឬក៏បានឃើញថា អ្នកណាម្នាក់បាត់ខ្លួន ឬក៏ត្រូវបានគេចាប់ដែរឬទេ នៅក្នុងសម័យកាលនោះ?

**ឆ៖** ខ្ញុំមានដឹង ឬក៏ឃើញអ្នកណាផ្សេងទៀតទេ ដឹងតែប៉ុណ្ណឹង។

**ស៖** សូមអរគុណលោក ពាន ឃាន។ ឥឡូវនេះ យើងនឹងចូលទៅដល់ចំណុចមួយ នៅពេលដែលយើងបានបញ្ឈប់នៅថ្ងៃទី០៣ ឧសភា យើងបានពិភាក្សាគ្នាអំពីការសម្ភាសន៍ បទសម្ភាសន៍របស់លោកពីមុន មុនពេលដែលលោកមកផ្តល់សក្ខីកម្មនៅតុលាការនេះ ហើយលោកបានជម្រាបប្រាប់យើងថា តាមដែលខ្ញុំចាំនោះគឺថា លោកថា លោកបានផ្តល់បទសម្ភាសន៍ពីរ តើត្រូវដែរឬទេ?

**ឆ៖** បញ្ហានេះ ខ្ញុំពិតជាបានសម្ភាសន៍ពីរដងមែន។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំបានទេ ថាតើនៅក្នុងការសម្ភាសន៍នោះ សម្ភាសន៍ទាំងពីរលើកហ្នឹងជាមួយអ្នកណាខ្លះ? តើលោកចាំទេ?

**ឆ៖** ខ្ញុំអត់បានចាំផង។

**ស៖** ឥឡូវនេះ ខ្ញុំនឹងបង្ហាញជូនលោកនូវ កំណត់ហេតុពីសប្តាហ៍មុនៗ នៅក្នុងកំណត់ត្រាដែលលោកបានផ្តល់សម្ភាសន៍ទៅឲ្យសហ-- អ៎! អ្នកស៊ើបអង្កេតរបស់តុលាការនេះ ហើយឯកសារចុះថ្ងៃទី ២៧ សីហា ឆ្នាំ២០០៩។ តើលោកបានចាំទេថា លោកបានផ្តល់បទសម្ភាសន៍នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០០៩ នោះ?

[០៩:៣៧:៥៩]

**ឆ៖** ឆ្នាំ២០០៩ ខ្ញុំនៅចាំបានថាម្តងដែរ។

**ស៖** តើលោកនៅចាំទេថា អ្នកដែលសម្ភាសន៍លោកមួយក្រុមផ្សេងទៀត ម្តងទៀតនោះអ្នកណាខ្លះ? តើលោកនៅចាំទេ?

**ឆ៖** ខ្ញុំគ្រាន់តែដឹងថា ខ្ញុំបានសម្ភាសន៍ពីរដង តែក្នុងម្តងៗ ខ្ញុំអត់បានចាំថា ក្រុមណាយ៉ាងទេ ភ្លេចបាត់ទៅ អត់បានចាំ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ លោកប្រធាន នៅពេលនេះ ខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សី នូវឯកសារ E187.1 ហើយនេះជាឯកសារដែលតុលាការបានទទួលស្គាល់ ហើយនៅក្នុងសវនាការនៅថ្ងៃទី០២ ឬក៏ទី០៣ ខែឧសភា គឺឯកសារ E187.1 បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិយកទៅជូនសាក្សី ដើម្បីពិនិត្យ!

[០៩:៣៩:៥៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ពាន ឃាន តើលោកទទួលបានឯកសារនេះទេនៅពេលដែលគេសម្ភាសរួច មុនដែលលោកមកផ្តល់សក្ខីកម្មនេះ តើលោកបានទទួលឯកសារនេះដែរឬទេ?

**លោក ពាន ឃាន៖**

**ឆ៖** ឯកសារទាំងពីរនោះ គឺពិតជាអ៊ីចឹងមែន។ ប៉ុន្តែគ្រាន់ថាខ្ញុំវាអត់បានចាំពីមុន គ្រាន់តែធ្លាប់ភ្លេចភ្លាំងប៉ុណ្ណឹង។

[០៩:៤១:១១]

**ស៖** យើងយល់បែបនេះលោក ពាន ឃាន។ ហើយឯកសារនេះ បាទ យើងពិនិត្យឃើញថាជាសេចក្តីសង្ខេបនៃសន្ទនារបស់លោកជាមួយនឹងក្រុមមួយនៅថ្ងៃទី២៥ កក្កដា ឆ្នាំ២០០៥ គឺការពិភាក្សាដែលយើងពិភាក្សានៅពីរបីថ្ងៃនេះ តើលោកនឹកឃើញទេ ថាតើលោកបានជួបអ្នកណាម្នាក់នៅក្នុងខែកក្កដា ឆ្នាំ២០០៥ ហ្នឹង ឬក៏ក្នុងអំឡុងខែហ្នឹង តើលោកចាំដែរឬទេ?

**ឆ៖** អ្ហឺ! ខ្ញុំគ្រាន់តែចាំថា សម្ភាសលើកទីមួយ ដំបូងគេ គឺមានទាំងជនជាតិខ្មែរ ស្ត្រីម្នាក់ ហើយប្រុសពីរទៅបីនាក់ ហើយក្នុងនេះមានជនជាតិបារាំងមួយ។ អាហ្នឹងសម្ភាសលើកទីមួយ។ ឯសម្ភាសលើកទីពីរ ខ្ញុំភ្លេចឈ្មោះគាត់ហើយ ប៉ុន្តែដឹងថាជនជាតិបរទេសមួយ ហើយនិងក្រៅពីនោះខ្មែរ អត់មានស្រីទេ មានតែប្រុសទាំងអស់ តែខ្ញុំមិនបានចាំឈ្មោះពួកគាត់ទេ។ ខ្ញុំភ្លេចទៅ។

**ស៖** បាទ ដូច្នេះយើងនឹងផ្តោតទៅលើចំណុចនេះ ថាតើព័ត៌មានប៉ុន្មានដែលលោកអាចនឹកឃើញឡើងវិញនៅលើព័ត៌មាននេះ ឯកសារនេះ។ ខ្ញុំនឹងសួរមន្ត្រីគ្រប់គ្រងករណីរបស់ខ្ញុំ ឲ្យបង្ហាញទំព័រជាភាសាខ្មែរ ជាលេខ ERN 00801770។

បាទ សូមបង្ហាញឯកសារនេះនៅលើអេក្រង់ផងដែរ។ សូមការអនុញ្ញាតពីតុលាការបាទ។

លោក ពាន ឃាន សូមលោកពិនិត្យមើលឯកសារលើក្រដាស គឺនៅទំព័រទី៣ ដែលនិយាយលេខ 00801770 នៅខាងលើឆ្វេងដៃខ្ញុំ ខ្ញុំនឹងអានជូនលោកអំពីវាក្យខណ្ឌខ្លីៗពីរអំពីលើឯកសារនេះ ហើយនិងសួរលោក ថាតើលោកនៅចាំដែរឬទេដែលលោកនិយាយពីរឿងនេះ ដែលប្រាប់ទៅអ្នកសម្ភាសនោះ។

[០៩:៤៤:០៩]

ដកស្រង់៖ "ខ្ញុំមិនពាក់ព័ន្ធជាមួយ សេ.អ៊ី.អា, កា.ហ្សេ.បេ នោះទេ ឬក៏គម្រោងក្បត់ធ្វើរដ្ឋប្រហារនោះឡើយ។ អ៊ីចឹងហើយខ្ញុំមិនដឹងថាមូលហេតុអ្វីបានជាខ្ញុំហៅថា ជាជនក្បត់ទេ។ ប៉ុន្តែខ្ញុំរស់នៅដោយភ័យខ្លាច ដោយសារតែមនុស្សគ្រប់គ្នានៅតែបាត់ខ្លួន។ ហើយទោះបីជាខ្ញុំមិនបានដឹងថា ពួកគេរស់ ឬស្លាប់ក៏ដោយ។ មានការខ្សឹបខ្សៀវគ្នា ថាប្រជាជនដែលបាត់ខ្លួននោះ គឺស្លាប់អស់ហើយ។ ពួកយើងមាន-- យើងមានសេរីភាពក្នុងការដើរហើរខ្លះ ហើយយើងអាច-- ហើយយើងអាចដឹងថា ប្រជាជនបានបាត់ខ្លួន គេប្រើពាក្យថា "ដក" ប៉ុន្តែគ្រប់គ្នាបានសន្និតច្រើនទៅៗ ហៅថាប្រជាជនមួយចំនួនត្រូវបានចាប់ខ្លួន។ ជួនកាលត្រូវគេដក មានន័យថា បញ្ជូនទៅ ប៉ុន្តែមិនមានន័យថាចាប់ទេ។ តើនេះជាសេចក្តីសង្ខេបត្រឹមត្រូវអំពីអ្វីដែលលោកបាននិយាយដែរឬទេ លោក ពាន ឃាន?

**ឆ៖** ចំណុចនេះគឺ ខ្ញុំពិតជាយល់អ៊ីចឹង តាមការយល់ និងតាមការពនិត្យឃើញក្នុងពេលនោះ គឺមានដូចដែលខ្ញុំឆ្លើយពីមុនមកអ៊ីចឹង។

[០៩:៤៦:០១]

**ស៖** សូមអរគុណច្រើន។ ខ្ញុំសូមអនុញ្ញាតចូលទៅដល់ផ្នែកមួយទៀត ហើយខ្ញុំនឹងនិយាយពីប្រធានបទនេះដោយសង្ខេបទេ។ លោកបានជម្រាបតុលាការហើយថា នៅដំណាក់កាលមួយ ប៉ង់ ខ្លួនឯងក៏បាត់ខ្លួនដែរ។ តើលោកនៅចាំដែរឬទេថា លោកដឹងដោយវិធីណាថាគាត់បាត់ខ្លួន ឬក៏ថាគេចាប់ខ្លួនគាត់នោះ និយាយពីរឿង ប៉ង់?

**ឆ៖** នៅពេលនោះខ្ញុំមិនបានឃើញគេចាប់គាត់ ឬគេនាំគាត់ទៅណាទេ ប៉ុន្តែធម្មតាខ្ញុំជាមួយគាត់ៗ គ្រប់គ្រងខ្ញុំរាល់ថ្ងៃនៅ ក-១ ហ្នឹង នៅជាមួយគ្នាទាំងអស់គ្នារាល់ថ្ងៃ។ ស្រាប់តែក្រោយមក ពីរបីថ្ងៃក្រោយមក បាត់ខ្លួនគាត់ ហើយខ្ញុំចេះតែសង្ស័យ ថាតើគាត់ទៅណា? រយៈពីរបីថ្ងៃអត់ទាន់ដឹងដែរ។ ដល់ក្រោយមកទៀត បានមានមិត្តភក្តិគេប្រាប់ថា គាត់ ប៉ង់ ហ្នឹងត្រូវគេចាប់ខ្លួនហើយ។ អ៊ីចឹងខ្ញុំក៏លែងនឹកនាទៀតទៅ។ បាត់ដំណឹង។

[០៩:៤៧:៥៧]

**ស៖** លោក ពាន ឃាន យើងអាចនឹងត្រឡប់មកចំណុចនេះ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ នៅឆ្នាំ២០០៥ ហើយសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ គឺខ្មែរ ERN00801769 គឺទំព័រលេខ២ ជាភាសាខ្មែរបាទ។ ខ្ញុំពិនិត្យឃើញថា ខ្ញុំមិនបានរក ERN ជា-- បាទជាភាសាអង់គ្លេស 000809701 បារាំង ERN00644575។ លោក ពាន ឃាន ពិនិត្យលើឯកសារនេះ ដូចដែលលោកបាននិយាយនៅលើ ទំព័រទី២ នៅភាសាខ្មែរនោះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សុំអនុញ្ញាតបង្ហាញតុលាការដើម្បីបង្ហាញឯកសារនេះនៅលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតសូមអញ្ជើញ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ពាន ឃាន តើលោកអាចនឹកឃើញដែរឬទេ? មើលឯកសារនេះ។ មានកថាខណ្ឌមួយដែលនិយាយថា “ប៉ង់ ត្រូវបានជំនួសដោយ លីន ដែលបានស្លាប់នៅព្រំដែនដោយសារជំងឺបេះដូង”។ អ្វីដែលខ្ញុំចាប់អារម្មណ៍នោះ គឺប្រយោគមួយចំនួន បន្ទាប់ពីនោះមក ដែលនិយាយពីខាងក្រោយហ្នឹងមក ជាផ្នែកមួយដែលនិយាយថា គេនិយាយថា ប៉ង់ បានធ្វើក្បត់ជាតិ។ យើងបានឮថា ប៉ង់ បានធ្វើអំពើក្បត់ទោះបីជាគ្មានប្រកាសជាផ្លូវការក៏ដោយ។ សេចក្តីដកស្រង់៖ “ខ្ញុំមិនប្រាកដថា តើ កុយ ធួន នៅរស់ឬក៏ស្លាប់ទេ ហើយក៏ជាមិនច្បាស់ថា មានរឿងអ្វីកើតឡើងចំពោះ ប៉ង់ នោះដែរ”។ តើនេះជាខ្លឹមសារសង្ខេបត្រឹមត្រូវអំពីអ្វីដែលលោកនិយាយដែរឬទេ ដែលថា ប៉ង់ លោកបានឮថា ប៉ង់ ធ្វើអំពើក្បត់ជាតិ ប៉ុន្តែលោកមិនដឹងច្បាស់គ្រាន់តែឮ តើអ៊ីចឹងមែនឬទេ?

[០៩:៥០:១១]

**លោក ពាន ឃាន៖**

**ឆ៖** ចំណុចនេះពិតជាត្រឹមត្រូវអ៊ីចឹងមែន ប៉ុន្តែខុសត្រង់ថា ឈ្មោះ កុយ ឃួន នេះត្រូវជា កុយ ធួន អាហ្នឹងមិនមែន កុយ ធួន ទេ គឺ កុយ ឃួន ច្បាស់ តាមខ្ញុំចាំ។

**ស៖** សូមអរគុណលោកសាក្សីដែលលោកបានបញ្ជាក់ពីចំណុចនេះ។ ខ្ញុំអាចនឹងនិយាយដោយសង្ខេប គឺថាសូមផ្អាកបន្តិច គឺថានេះគឺជាការប្រើឈ្មោះខុសៗគ្នា គឺ កុយ ឃួន ឬ កុយ ធួន ដែលថាមានឈ្មោះហៅក្រៅថា ធុច។ អ៊ីចឹងដើម្បីកំណត់ត្រាតុលាការឯកសារ IS5.39 ដែលបង្ហាញអំពីបញ្ហា

នេះឲ្យកាន់តែច្បាស់ ហើយខ្ញុំនឹងនិយាយពិស្តារពីបញ្ហានោះទេ គ្រាន់តែជម្រាបជូនសាក្សីថា ERN ជាភាសាខ្មែរ 00005994 ហើយទំព័រដូចខាងក្រោមនេះ គឺយើងនឹងអាចឃើញហត្ថលេខា និងកាលបរិច្ឆេទដែលមានឈ្មោះថា ឃួន។ ឯកសារនេះ គឺនៅក្នុងខែកុម្ភៈ និងមីនា ឆ្នាំ១៩៧៧។

[០៩:៥១:៣៨]

បាទ គឺទំព័រដែលជាភាសាបី គឺខ្មែរ ERN គឺ 00006066 ទំព័រហ្នឹងគឺដែលចុះហត្ថលេខាដោយ ឃួន ជាភាសាអង់គ្លេស ខ្មែរក៏មាន។ អង់គ្លេស គឺ ERN 00769830 បារាំង ERN 00766794 ដោយមិនចំណាយពេលច្រើនទៀត។ ខ្ញុំសូមអនុញ្ញាតបន្តទៅទៀតគឺថា ឯកសារនេះអាចបំភ្លឺអំពីការប្រើឈ្មោះពីររបស់ កុយ ឃួន ឬក៏ កុយ ធួន ហៅ ធុច នេះ។

លោក ពាន ឃាន ត្រឡប់មករកពីការចាប់ខ្លួន ប៉ង់ វិញ ហើយនិងការបាត់ខ្លួន ប៉ង់ វិញ។ លោកបានជម្រាបតុលាការថា ប៉ង់ គឺអ្នកជំនួយរបស់មេ-- ជំនួយការរបស់មេដឹកនាំជាន់ខ្ពស់។ នៅពេលដែលបាត់ខ្លួន ប៉ង់ នេះទៅ តើគេបានដឹងជាទូទៅដែរឬទេ ក្នុងចំណោមដែល-- អ្នកដែលធ្វើការជាមួយលោក ឬក៏មានការកត់សម្គាល់ថា គាត់បាត់ខ្លួនដែរឬទេ?

**ឆ៖** នៅពេលនោះ ជាទូទៅគេដឹងថាគាត់បាត់ខ្លួនមែន។ នៅក្នុងចំណោមរង្វង់ ក-១, ក-៣ ហ្នឹងក៏គេដឹងដែរ ថាគាត់បាត់ខ្លួន។

**ស៖** លោកបាននិយាយថា លោកបានភ័យខ្លាចក្រោយពីបាត់ខ្លួន កុយ ឃួន នោះទៅ។ តើលោកបាត់-- លោកភ័យខ្លាចដោយសារបាត់ខ្លួន កុយ ឃួន ឬក៏ដោយសារ ប៉ង់ បាត់ខ្លួនបាទ?

**ឆ៖** និយាយទៅពេលនោះ ពេល កុយ ឃួន បាត់ខ្លួន ខ្ញុំមានការភ័យខ្លាចម្តង។ ដល់ឃើញ ប៉ង់ បាត់ខ្លួនម្តងទៀត ខ្ញុំកាន់តែភ័យខ្លាចថែមទៀតមិនដឹងវារឿងរ៉ាវហ្នឹងវាទៅយ៉ាងណាខ្ញុំក៏មិនដឹង គ្រាន់តែឃើញព្រឹត្តិការណ៍អ៊ីចឹងនៅពេលនោះ។

[០៩:៥៤:៣០]

**ស៖** តាមដែលលោកបានដឹងថា តើមានអ្នកណាធ្លាប់មកស៊ើបអង្កេត ឬក៏មកសាកសួរអំពីការបាត់ខ្លួនរបស់ ប៉ង់ ឬក៏គេចង់ដឹងថា តើ ប៉ង់ ទៅឯណា? គេមករកដល់ ក-១, ក-៣ គេចង់ដឹង ឬក៏មិនមានរឿងបែបនេះ?

**ឆ៖** តាំងពីពេលនោះមកអត់មានឃើញអ្នកណាមកសាកសួរ ស៊ើបអង្កេតទេ គឺស្ងាត់រហូតមកទល់បច្ចុប្បន្ននេះ។

**សៈ** ចូលទៅដល់ប្រធានបទមួយផ្សេងទៀត លោក ពាន ឃាន។ យើងបានពិភាក្សាអំពីបញ្ហានេះ គឺនៅថ្ងៃទី០៤ ឧសភា អំពីកិច្ចប្រជុំមួយចំនួនដែលធ្វើឡើងនៅ ក-៣ ហើយដើម្បីរំឭកព័ត៌មានខ្លះទាក់ទងទៅនឹងបញ្ហានៅ ក-៣ នោះ គឺនៅក្នុងវគ្គប្រជុំនោះ គឺថាក្រុមមនុស្សមួយចំនួនដែលលោកបានឃើញ គឺថាសុទ្ធតែជាមេដឹកនាំជាន់ខ្ពស់។ ពីព្រោះថាការប្រជុំនោះមិនមែនសម្រាប់មហាជននោះទេ គឺថាសម្រាប់ក្រុមពិសេសនេះ ហើយក្រុមនោះ គឺៗក្រុមនោះមាន ប៉ុល ពត, នួន ជា, ខៀវ សំផន ហើយជួនកាលមាន សុន សេន ផង។ តើលោកនៅនឹកឃើញដែរឬទេ ថាប្រជុំនោះវាញឹកញាប់ប៉ុនណាដែលថា-- ឬក៏លោកដឹងថា គេប្រជុំញឹកញាប់ប៉ុនណាដែរ នៅក្នុងរយៈកាលនោះបាទ?

**ឆៈ** បើតាមខ្ញុំចំណាំបាន ពេលនោះ គឺក្នុងមួយខែ មានតែពីរទៅបីដងតែប៉ុណ្ណោះទេ។

[០៩:៥៧:០៥]

**សៈ** សូមអរគុណលោកសាក្សី។ លោកបានប្រាប់យើងថា លោកបានផ្តល់អាហារ ឬក៏យកម្ហូបអាហារទៅឲ្យមេដឹកនាំនោះ តើលោកបានចូលបន្ទប់ដែលមេដឹកនាំជាន់ខ្ពស់ហ្នឹងប្រជុំដែរឬទេ ក្នុងការផ្តល់ម្ហូបអាហារនោះ?

**ឆៈ** នៅពេលនោះ ខ្ញុំមិនបានចូលទៅដល់កន្លែងប្រជុំទេ ព្រោះកន្លែងហូបបាយ កន្លែងគាត់ពិសាបាយ នៅខាងក្រៅផ្សេង ហើយខ្ញុំនៅចង្ក្រានបាយខាងកន្លែងគេដាំស្ល គ្រាន់តែលើកបាយស្លទៅជូនពួកគាត់ពិសាតែប៉ុណ្ណោះ។

**សៈ** តើលោកបានឮពីអ្នកណាម្នាក់ ឬក៏តើលោកបានដឹងដោយវិធីណា? ថាតើគោលបំណងនៃការប្រជុំទាំងអស់នោះ គេប្រជុំដើម្បីធ្វើអ្វី? សម្រេចរឿងអ្វីដែរឬទេ?

[០៩:៥៨:៣៧]

**ឆៈ** រឿងគោលបំណង ឬក៏ខ្លឹមសារ អង្គប្រជុំរបស់ពួកគាត់ ខ្ញុំអត់បានយល់ទេ។ អត់បានដឹងទាំងអស់។ គ្រាន់តែដឹងថា មានការប្រជុំតែប៉ុណ្ណឹង។

**សៈ** សូមអរគុណ។ លោកបានប្រាប់យើងខ្ញុំថា ការប្រជុំមួយចំនួននោះ គឺប្រជុំសម្រាប់តែក្រុមតូចទេ។ ថាតើមានការប្រជុំផ្សេងទៀត មានមនុស្សច្រើនចូលរួមដែរឬទេ នៅពេលដែលលោកបានរៀបចំម្ហូបអាហារ ឬក៏បាយទឹកសម្រាប់អ្នកប្រជុំទាំងអស់នោះៗបាទ?

**ឆៈ** ក្នុងពេលនោះ អត់ឃើញ មានអ្នកណាក្រៅទេ។ ឃើញតែអ៊ំប៉ុន្មាននាក់ បីបួននាក់តែប៉ុណ្ណឹង។

**ស៖** តើលោកធ្លាប់បានឮដែរឬទេ ថាមានការប្រជុំជាមួយក្រុមអ្នកណាផ្សេងទៀត នៅក្នុងក-៣ ក្រៅពួកគាត់ទាំង-- អ៎ំទាំងប៉ុន្មាននាក់ហ្នឹងបាទ?

**ឆ៖** ខ្ញុំអត់ដែរឃើញទេ ឃើញតែប៉ុណ្ណឹង។

[១០:០០:១៨]

**ស៖** សូមអរគុណ។ យើងមានពេលខ្លី ខ្ញុំអនុញ្ញាតតទៅមុខទៀត។ កាលពីមុន ខ្ញុំបានសួរលោកថាតើលោកបានចាំដែរឬទេ ថាតើ ខៀវ សំផន ធ្លាប់បានចូលរួមប្រជុំជាមួយមនុស្សមួយចំនួន ដែលធ្វើការនៅមន្ទីរ“ក” នោះដែរឬទេ? ហើយខ្ញុំ តាមដែលខ្ញុំចាំនោះលោកមិនបានឃើញគាត់ទេ ដែលថាចូលរួមក្នុងកិច្ចប្រជុំនោះទេ។ តើលោកបានឃើញ ខៀវ សំផន ចូលរួមប្រជុំណាមួយផ្សេងខុសពីមេដឹកនាំជាន់ខ្ពស់ដែលលោកបាននិយាយខាងដើមនេះដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលឃើញគាត់ប្រជុំឯណា បានដឹង ឬក៏បានឃើញ ខ្ញុំក៏អត់ទាំងអស់ ក្រៅពីកន្លែង ក-៣។ អត់មានឃើញទេ ហើយក៏មិនបានដឹងដែរ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម ខ្ញុំចង់ត្រឡប់ទៅឯកសារ E187.1 ដែលជាឯកសារសង្ខេបកិច្ចសម្ភាសឆ្នាំ២០០៥។ ខ្ញុំចង់រំឭកការចងចាំរបស់លោកសាក្សីវិញ គឺឯកសារ E187.1 សូមអនុញ្ញាតបញ្ចាំងលើអេក្រង់ លោកប្រធាន។

[១០:០១:៥២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

មន្ត្រីរដ្ឋបាលតុលាការចង្អុលបង្ហាញចំណុច ដែលលោកតំណាងសហព្រះរាជអាជ្ញាមានបំណងដេញដោលដល់សាក្សីផង ដើម្បីពន្លឿននូវកិច្ចដំណើរការនីតិវិធី។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណច្រើនលោកប្រធាន។ មន្ត្រីតុលាការលោកនឹងឃើញចំណុចបន្ទាប់ដែលទំនងជានៅទំព័រទី០៣ ជាភាសាខ្មែរ នៅខាងឆ្វេង ខាងលើ គឺលេខ ERN 00801770 ទំព័រដូចដែលទំព័រដែលយើងបានមើលពីមុនដែរ។ សូមឲ្យខាងបច្ចេកទេសសោតទស្សន៍បញ្ចាំងទំព័រនេះនៅលើអេក្រង់ដើម្បីឲ្យភាគីទាំងអស់បានឃើញ។ សូមអរគុណ។

[១០:០២:៥៩]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ពាន ឃាន ខ្ញុំនឹងអានដោយសង្ខេបទៅលើចំណុចដែលពាក់ព័ន្ធទៅនឹងអ្វីដែលលោក បានឆ្លើយនាពេលនោះ។ ខ្ញុំសូមដកស្រង់សម្ដីលោក៖ "ប៉ង់ គឺជាអ្នករៀបចំការប្រជុំនានា ប៉ុន្តែ ហែម (ខៀវ សំផន) ធ្វើជាប្រធានខាងនយោបាយចំពោះរឿងផ្សេងៗ ក៏ប៉ុន្តែនៅក្រោម ប៉ុល ដែលជាអ្នកទទួល បន្ទុកការប្រជុំនយោបាយជាមួយនឹង នួន"។ ប្រយោគបន្ទាប់និយាយថា៖ "ហែម ដែលឈ្មោះ ខៀវ សំផន ធ្វើជាប្រធានក្នុងកិច្ចប្រជុំសាខាបក្សនៅតាមការិយាល័យនៃមន្ទីរ-ក។ ហែម (ខៀវ សំផន) គឺជា ចៅហ្វាយនាយរបស់ ប៉ង់"។ តើលោកនឹកឃើញថា លោកបានឆ្លើយដូច្នេះដែរឬទេ លោក ពាន ឃាន?

[១០:០៤:០៣]

**ឆ៖** ចំណុចនេះ គឺត្រឹមត្រូវអ៊ីចឹងទាំងអស់។

**ស៖** តើត្រឹមត្រូវដែរឬទេតាមចម្លើយដែលសរសេរនៅទីនេះថា ខៀវ សំផន គឺជាប្រធាននៅក្នុង កិច្ចប្រជុំទទួលបន្ទុកការប្រជុំនយោបាយជា-- បាទ ដែលនិយាយថា ខៀវ សំផន គឺជាប្រធានក្នុងការ ប្រជុំនៅតាមការិយាល័យនៃមន្ទីរ"ក" ហើយ ប៉ង់ គឺជាអ្នករៀបចំការប្រជុំ។ តើត្រឹមត្រូវដែរឬទេ ចំណុចទាំងពីរនេះ?

**ឆ៖** តាមខ្ញុំសង្កេតឃើញនៅពេលនោះ គឺមានអ៊ីចឹងមែន។

**លោក គង់ សំអុន៖**

លោកប្រធាន សូមអនុញ្ញាត។

[១០:០៤:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក គង់ សំអុន៖**

តាមសម្ដីសាក្សីឆ្លើយអម្បាញ់មិញនេះ គឺហាក់ដូចជាមិនច្បាស់ ថាតើអ្វីដែលគាត់ឆ្លើយថា "មាន" មាននៅក្នុងអត្ថបទដែលសហព្រះរាជអាជ្ញាបង្ហាញ ឬក៏មាននូវព្រឹត្តិការណ៍ដែលកើតឡើងពី សម័យនោះ? សូមលោកប្រធានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាបញ្ជាក់ចំណុចនេះបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

[១០:០៥:២៥]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក ពាន ឃាន បន្តទៅនឹងប្រធានបទនេះ ដែលយើងបានពិភាក្សា។ តើលោកចាំដែរឬទេថា-- តើលោកចាំកន្លែងមួយដែលគេហៅថា "បុរីកីឡា" ដែរឬទេ? លោកដឹងថាកន្លែងនោះនៅម្តុំណាដែរ?

**លោក ពាន ឃាន៖**

**ឆ៖** បុរីកីឡា ខ្ញុំគ្រាន់តែឮ ប៉ុន្តែខ្ញុំអត់បានចាំ។ ឮឈ្មោះបុរីកីឡាដែរ ប៉ុន្តែខ្ញុំអត់បានចាំនៅកន្លែងណាពិតប្រាកដទេ។

**ស៖** ខ្ញុំគិតថា ប្រហែលជាយើងមានបញ្ហាបច្ចេកទេសសំឡេង អត់អីទេ! ដំណើរការបានវិញហើយ។ តើលោកចាំទេ បុរីកីឡានោះ ទីតាំងបុរីកីឡានោះ គេប្រើសម្រាប់ធ្វើអ្វីដែរ?

**ឆ៖** បុរីកីឡា ខ្ញុំគ្រាន់តែឮឈ្មោះ ប៉ុន្តែខ្ញុំមិនដឹងកន្លែងនោះជាកន្លែងអ្វី? សម្រាប់ធ្វើអី? ក៏ខ្ញុំមិនដឹងដែរ។

[១០:០៧:០០]

**ស៖** តើលោកនឹកឃើញដែរឬទេថា មានជនជាប់ចោទណាម្នាក់ នួន ជា ឬក៏ ខៀវ សំផន ឬក៏ អៀង សារី ធ្លាប់បានផ្តល់ការបណ្តុះបណ្តាលផ្នែកនយោបាយទៅដល់កម្មាភិបាលក្នុងចន្លោះឆ្នាំ៧៥ ទៅដល់ ៧៩ នោះ?

**ឆ៖** ចំណុចនេះ ខ្ញុំក៏មិនបានដឹងដែរ។

**ស៖** សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន យើងខ្ញុំអនុញ្ញាតចូលឯកសារ E187.1 វិញ ត្រង់ចំណុចសង្ខេបមួយដែលត្រង់-- ដែលលើកឡើងក្នុងខ្មែរ ERN មានលេខ១ ទំព័រ ERN ដូចលេខទំព័រ ERN ដែលយើងខ្ញុំបានបញ្ចាំង

អម្បាញ់មិញ គឺ 00801770។

[១០:០៨:២៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងចង្អុលបង្ហាញដល់សាក្សីនូវចំណុចដែលតំណាងសហព្រះរាជអាជ្ញាអន្តរជាតិប៉ុនប៉ងសួរដេញដោលចំពោះសាក្សី។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ដើម្បីជាប្រតិចារឹកលេខ ERN ជាភាសាបារាំង គឺត្រង់លេខ 00644576 អង់គ្លេសគឺ 00089701។ សូមឲ្យមន្ត្រីតុលាការបញ្ចាំងត្រង់ទំព័រនេះទៅដល់សាក្សីផង ហើយចំណុចនោះនៅត្រង់ចុងទំព័រនេះ។ សូមឲ្យអ្នកបច្ចេកទេសជួយបញ្ចាំងត្រង់ទំព័រនេះផងដែរ នៅលើអេក្រង់។ សូមអរគុណ។

[១០:០៩:២៧]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំចាប់អារម្មណ៍ត្រង់ចំណុចមួយចំណុចនៅក្នុងទំព័រនេះលោក ពាន ឃាន។ ខ្ញុំសូមដកស្រង់សម្តី៖ “នួន ជា និង ហែម (ខៀវ សំផន) បានផ្តល់នូវការអប់រំនយោបាយជាន់ខ្ពស់នៅឯបុរីកីឡាសម្រាប់ក្រសួងនៅភ្នំពេញ និងកម្មាភិបាលមូលដ្ឋាន។ ប៉ង់ បានរៀបចំការប្រជុំទាំងនេះជាមួយ ខាំ មី ដោយផ្តល់នូវសន្តិសុខសុវត្ថិភាព។ អ្នកដែលបានចូលរួមការប្រជុំទាំងនេះបានស្នាក់នៅក្នុងភូមិគ្រឹះជុំវិញបុរីកីឡា ហើយហូបអាហារនៅក្នុងបរិវេណនោះ”។ តើចំណុចនេះ គឺជាការសង្ខេបមួយត្រឹមត្រូវនូវអ្វីដែលលោកបានឆ្លើយជូនអ្នកដែលទៅសម្ភាសន៍លោកក្នុងឆ្នាំ២០០៥ ដែរឬទេ លោក ពាន ឃាន?

**ឆ៖** ចំណុចនេះគឺពិតជាអ៊ីចឹងមែន។

**ស៖** តើលោកអាចជួយប្រាប់យើងខ្ញុំបានឬទេ ពាក្យថា ការអប់រំនយោបាយជាន់ខ្ពស់ តើមានន័យយ៉ាងម៉េចដែរលោក ពាន ឃាន?

[១០:១១:០០]

**ឆ៖** ខ្ញុំសម្គាល់ថា ត្រឹមតែប៉ុណ្ណោះទេ ជាធម្មតានៅជុំវិញ ក-១, ក-៣ ហ្នឹង ជាអចិន្ត្រៃយ៍មានតែប៉ង់ ទេ។ ប៉ុន្តែដល់បុរីកីឡា មានថ្ងៃមួយនោះឃើញមេធំៗបើក-- ទៅចូល-- បើកវគ្គហ្នឹងមានអ៊ំហែម

ដែលចូលរួមផ្ទាល់ ហើយនិងមានប៉ង់ ហើយអ៊ីចឹងខ្ញុំចាត់ទុកថា ពេលនោះប្រជុំវាប្រាកដជាថ្នាក់កំពូលជាង ប៉ង់។ គាត់ទៅប្រជុំរំឭកដាស់តឿន គ្រាន់តែរឿងថាកាលសម័យកសាងហ្នឹងវា និយាយពីរឿងការកសាងប្រទេសធ្វើម៉េចឲ្យរីកចម្រើន ហើយមានសហករណ៍ ហើយណែនាំពីការកុំឲ្យភ្លើតភ្លើនក្នុងការរស់នៅ កុំឲ្យន៎ែ! លើសដែលថាលើសពីរបបប្រជាជនទូទៅ ព្រោះយើងជាវណ្ណៈ កម្មករ កសិករ ព្រោះរឿងហ្នឹងគឺថា កសិករគឺជាប្រភេទវណ្ណៈល្អជាងគេ ចេញពីការបណ្ដុះបណ្ដាល។ ពេលនោះគឺរំឭកពីរឿងបញ្ហាមាគ៌ានយោបាយ កសាងប្រទេស ទៅថ្ងៃមុខឲ្យបានរីកចម្រើន ឲ្យប្រជាជនសម្បូរធូរធារ។ ពេលនោះឃើញខ្លឹមសារឯកសារគឺបាននិយាយអ៊ីចឹង បើតាមខ្ញុំចាំនៅពេលនោះ។

[១០:១៣:២៨]

**ស៖** សូមលោកជួយប្រាប់ពន្យល់យើងខ្ញុំ ថាតើមាននរណាខ្លះដែលចូលរួមនៅក្នុងការអប់រំនោះ ហើយទទួលការអប់រំនោះ? តើជាកម្មាភិបាលជាន់ទាប ឬក៏មេដឹកនាំជាន់ខ្ពស់ ឬក៏ជាកម្មាភិបាលផ្សេង?

**ឆ៖** នៅពេលនោះ ខ្ញុំមិនបានដឹងថាចាប់ពីថ្នាក់ណាទេ គ្រាន់តែថា ការប្រជុំយ៉ាងហោចណាស់ក៏ត្រឹមថ្នាក់ក្របខ័ណ្ឌតំបន់ ឬក៏នៅជុំវិញភ្នំពេញហ្នឹងក៏ចូលរួមដែរ។ ប៉ុន្តែ ខ្ញុំមិនដឹងថាមកពីក្រសួងណាមន្ទីរណា ក៏ខ្ញុំមិនបានចាំដែរ។

**ស៖** តើលោកខ្លួនឯងធ្លាប់ចូលរួមវគ្គអប់រំនេះដែរឬទេ? ឬក៏លោកត្រឹមតែបានឃើញមានការមានវគ្គអប់រំនេះតែប៉ុណ្ណោះ?

**ឆ៖** ក្នុងពេលនោះ គេឲ្យខ្ញុំចូលរួមដែរ ហើយឯខ្លឹមសារនៃការប្រជុំរៀនហ្នឹង គឺដូចខ្ញុំបានបញ្ជាក់ខាងដើមហើយ។

[១០:១៥:៣៤]

**ស៖** តើនរណាដែរ ដែលធ្វើឧទ្ទេសនាមនៅពេលនោះ ពេលដែលលោកចូលរួមប្រជុំនោះ?

**ឆ៖** ខ្ញុំមិនបានចាំ ខ្ញុំភ្លេចទៅ អ្នកឧទ្ទេសនាមខ្ញុំមិនបានចាំទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា មានឈ្មោះប៉ុណ្ណឹងនាក់ដែលឈ្មោះអ្នកដឹកនាំ។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ការប្រជុំដែលលោកចូលរួមនោះគឺ លោកបានឃើញ ខៀវ សំផន និង ប៉ង់? ហើយតើមាននរណាផ្សេងទៀតដែរឬទេ? តើនេះជាអ្វីដែលលោករៀបរាប់ត្រឹមត្រូវអ៊ីចឹងមែនដែរឬទេ?

**ឆ៖** នេះគឺពិតជាត្រឹមត្រូវអ៊ីចឹងមែន។

**ស៖** តើលោកចាំដែរឬទេ ថាការប្រជុំបែបនេះមានការចូលរួមដោយ អៀង សារី ឬក៏ នួន ជា ផងដែរនោះ?

**ឆ៖** បើតាមខ្ញុំចាំថា អ៊ំ អៀង សារី អត់បានចូលរួមទេ បើមានតែអ៊ំ នួន ជា ទេ។

**ស៖** លោកបានជម្រាបប្រាប់យើងខ្ញុំថា មានការបង្រៀនមាគ៌ានយោបាយ តើលោកអាចនិយាយឱ្យបានជាក់លាក់ដែរឬទេ នៅពេលដែលគេរៀនមាគ៌ានយោបាយនោះ គេបង្រៀនអ្វីដែរ?

[១០:១៨:០១]

**ឆ៖** ក្រោយពេលរំដោះភ្នំពេញ ១៧ មេសា មាគ៌ានយោបាយគឺ ទីមួយ កសាងប្រទេស។ ទីពីរ ការពារប្រទេស។ កសាងប្រទេស ដោយកសាងសហករណ៍ ហើយបង្កើតរបប នៃសមូហភាព ហើយបំផុសប្រជាជន មហាជន លើកទំនប់ ជីកប្រឡាយ ដើម្បីកសាងប្រទេសឲ្យបានជឿនលឿន ហើយខាងការពារប្រទេស ខ្ញុំមិនបានជម្រាបជ្រៅទេ គ្រាន់តែថាការពារប្រទេសហ្នឹង ធ្វើម៉េចកុំឲ្យតែខ្មាំងសត្រូវឈ្លានពានមកឈ្លានពានឡើងវិញ ដូចកាលសម័យចក្រពត្តិអាមេរិក កុំឲ្យត្រឡប់មកវិញ។ ខ្លឹមសារគឺមាន សំខាន់គឺមានពីរហ្នឹង។

**ស៖** សូមអរគុណច្រើនលោក ពាន ឃាន ដែលលោកបានឆ្លើយលម្អិតដូច្នេះ។ ចំណុចចុងក្រោយយើងចង់សួរបញ្ជាក់ជាងនេះបន្តិច។ នៅថ្ងៃទី០៣ ខែឧសភា លោកបាននិយាយប្រាប់យើងខ្ញុំថា នៅក្នុងការប្រជុំមួយចំនួនដែលលោកបានចូលរួមជាមួយគេនោះ គេបង្រៀនលោកអំពី "ខ្មាំង" ដែលចូលដៃជាមួយនឹង សេ.អ៊ី.អា អាមេរិក ហើយជ្រៀតចូលបក្ស ហើយក៏គេបង្រៀនអំពីខ្មាំងភ្នាក់ងារគិញកា.ហ្សេ.បេ និងភ្នាក់ងារយួនផងដែរ។ តាមការនឹកឃើញរបស់លោក តាមការចងចាំរបស់លោក តើក្រុមនេះ ឬក៏ក្រុមទាំងអស់នេះ គឺជាក្រុមដែលគេបង្រៀនលោក ដែលថាធ្វើយ៉ាងណាការពារប្រទេសពីក្រុមនេះ ឬក៏យ៉ាងម៉េច?

**ឆ៖** ពិតជាក្រុមនេះតែមួយទេ អត់មានអ្នកផ្សេង។

**ស៖** សូមអរគុណ។ តើគេមានប្រាប់លោក ថាតើខ្មាំងទាំងអស់នេះនៅឯណាដែរ ហើយការពារប្រទេសពីខ្មាំងទាំងអស់នេះ ដោយប្រើរបៀបណាដែរ?

**ឆ៖** ចំណុចសំខាន់ គឺទីមួយ ដែលថាពេលនោះកុំឲ្យយួនឈ្លានពាន កុំឲ្យចក្រពត្តិអាមេរិកវិលត្រឡប់មកវិញ។ ពីរហ្នឹងជាសំខាន់ ខាងការពារប្រទេស។

[១០:២២:០៥]

**ស៖** ដោយសារលោកបានប្រាប់យើងខ្ញុំថា មានខ្មាំងមួយចំនួនជ្រៀតចូលបក្ស បង្កប់ខ្លួននៅក្នុងបក្ស តើគេមានប្រាប់ថា ត្រូវស្រាវជ្រាវ ស្វែងរកខ្មាំងបង្កប់នៅក្នុងបក្សនេះដោយរបៀបណា? ហើយធ្វើយ៉ាងម៉េចចំពោះខ្មាំងទាំងអស់នោះដែរឬទេ?

**ឆ៖** ជាធម្មតា គេតែងតែរម្លឹកដាស់តឿនឲ្យពិនិត្យតាមដានមើលអ្នកណាដែលធ្វើខុសអំពីមាគ៌ាដែលចែងមកដូចខ្ញុំបានបញ្ជាក់ខាងលើ។ បើថាអ្នកណាធ្វើខុសពីហ្នឹង បានន័យថា អ្នកហ្នឹងប្រាសចាកពីមាគ៌ារបស់បក្ស។ ឯវិធីផ្សេងទៀត ខ្ញុំមិនបានយល់ទេ។

**ស៖** សូមអរគុណច្រើនលោក ពាន ឃាន។ ខ្ញុំនឹងចូលទៅដល់ចំណុចមួយទៀត ដោយសារតែពេលវេលា យើងសល់តែមួយចំនួនតែប៉ុណ្ណោះ។ យើងនឹងនិយាយអំពីអង្គមួយទៀតដោយសង្ខេប។ លោកបានជម្រាបប្រាប់យើងខ្ញុំថា "នៅពេលដែល លោក គេបញ្ជូនលោកទៅស្រែមាស ក្រោយពីបាត់ខ្លួន ប៉ង់" តើលោកចាំទេ គេបញ្ជូនលោកនៅពេលណាដែរ?

**អ្នកបកប្រែ៖**

សូមកែតម្រូវ "ស្វាយមាស"។

**លោក ពាន ឃាន៖**

**ឆ៖** អ្ហឺ!នៅពេលនោះ ខ្ញុំគ្រាន់ដឹងថា មុនវៀតណាមចូលភ្នំពេញប្រហែលជាបីខែប៉ុណ្ណោះ គេបញ្ជូនខ្ញុំមកស្វាយមាស ជាកន្លែងសហករណ៍តូចមួយ ជាកន្លែងលត់ដំ។ សហករណ៍ហ្នឹង សហករណ៍គឺថា គឺកន្លែងលត់ដំ កសាងខ្លួន។ ប៉ុន្តែខ្ញុំៗមិនដឹងជាខ្ញុំជាខុសអី គ្រាន់តែខ្ញុំដឹងថាខ្ញុំនៅជាមួយ កុយ ឃួន ដល់ពេលចាប់ កុយ ឃួន ទៅ ខ្ញុំចេះតែមានការភ័យខ្លាចបន្តបន្ទាប់តែប៉ុណ្ណឹងទេ។

[១០:២៤:៤៨]

**ស៖** តើលោកអាចនឹកឃើញដែរឬទេ នរណាគេដែរ ដែលបញ្ជូនលោកទៅស្វាយមាស?

**ឆ៖** ពេលនោះគឺ អ្នកប្រាប់ឲ្យខ្ញុំទៅគឺឈ្មោះ យ៉ុម ប៉ុនមិនដឹង យ៉ុម ហ្នឹងទទួលពីណាទៀតក៏ខ្ញុំមិនបានដឹងដែរ។ យ៉ុម គឺប្រធានមន្ទីរនៅព្រែកប្រា។

**ស៖** សូមអរគុណ។ តើគេបញ្ជូនលោកទៅតែឯងទេ ឬក៏គេបញ្ជូនលោកទៅជាមួយគេផ្សេងរួមគ្នា?

**ឆ៖** នៅពេលនោះ គឺគេឲ្យទៅតែខ្ញុំ ជាមួយគ្រួសារខ្ញុំប៉ុណ្ណឹងទេ។ អត់មានអ្នកណាក្រៅ ផ្សេងទៀត។

**ស៖** នៅពេលដែលលោកនិយាយថា ជាមួយគ្រួសារនោះ តើមាននរណាខ្លះដែរនៅក្នុងហ្នឹង?

**ឆ៖** គ្រួសារ គឺប្រពន្ធខ្ញុំតែម្តង អត់មានអ្នកណាក្រៅ។

**ស៖** សូមអរគុណ។ តើលោកធ្វើការងារអ្វីដែរនៅស្វាយមាស ហើយលោកមានតួនាទីនិងទទួលភារៈធ្វើអ្វីដែរនៅទីនោះ?

[១០:២៦:៥៨]

**ឆ៖** តាមខ្ញុំចាំ ខ្ញុំទៅដល់មុនដំបូង អត់មានតួនាទីអីទេ គឺគេឲ្យទៅបង់សំណាញ់ រកត្រីឲ្យសហករណ៍គេហ្នឹង ហើយក្រោយមកគេឲ្យដាំបន្លែតិចតួច ហើយនិងជួសជុលកីតម្បាញនៅស្វាយមាសហ្នឹង មុនដែលគេបញ្ជូនខ្ញុំមកភ្នំពេញវិញ។ ខ្ញុំឃើញតែប៉ុណ្ណឹង។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំដឹងថា យើងខ្ញុំនៅតែពេលវេលាមួយចំនួនតិចតែប៉ុណ្ណោះ ក៏ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ចំណុចមួយចំនួនឲ្យបានច្បាស់លាស់ ហើយខ្ញុំសុំពេលវេលាបន្ថែម ១០នាទី តែប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធានរយៈពេល១០នាទីបន្ថែម ហើយខ្ញុំអាចសួរបញ្ជាក់បំភ្លឺចំណុចដែលមិនស៊ីសង្វាក់គ្នានៅពេលនេះតែម្តង ឬក្រោយពេលឈប់សម្រាក តាមការអនុញ្ញាតពីលោកប្រធាន។ សូមអរគុណ។

[១០:២៨:០៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយសូមលោកបន្តឲ្យចប់នូវភារកិច្ចរបស់លោកនៅពេលព្រឹកនេះ មុនពេលសម្រាក។ ក្រោយពេលសម្រាក អង្គជំនុំជម្រះនឹងផ្តល់វេទិកាទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ប្រសិនបើយើងបង្ហាញឯកសារនេះឲ្យបានតែមួយរយៈពេលខ្លីប៉ុណ្ណោះ គឺឯកសារ E187.1 ត្រង់ ERN ជាភាសាខ្មែរ 00801769 ERN ជាភាសាអង់គ្លេស គឺ 00089701 បារាំងគឺ 00664475។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ធ្វើការបញ្ចាំងឯកសារនេះនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

[១០:២៩:១៤]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមអរគុណច្រើនលោកប្រធាន។ សូមឱ្យខាងអ្នកបច្ចេកទេសសោតទស្សន៍ធ្វើការបញ្ចាំងឯកសារនេះនៅលើអេក្រង់ផង។ ដោយសារតែយើងខ្ញុំមានពេលវេលាសល់តែបន្តិចបន្តួចប៉ុណ្ណោះ។ ខ្ញុំសូមសួរថា លោក ពាន ឃាន នៅត្រង់ទំព័រដែលយើងខ្ញុំបញ្ចាំងជូនលោកនេះ គឺគេបានសរសេរថា៖ "លីន ជាអ្នកបញ្ជូនខ្ញុំឱ្យទៅទទួលបន្ទុកនៅស្វាយមាស ក្រោយចាប់ ប៉ង់។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំទទួលបន្ទុកភារៈនៅវត្តស្វាយមាស ហើយខ្ញុំធ្វើការងារក្រោម រ៉ា ដែលជាកូនស្រីពៅរបស់ អៀង សារី។ ដូច្នេះនេះជាអ្វីដែលលោកបានឆ្លើយ ហើយជាហេតុការណ៍ដែលកើតឡើងនៅពេលនោះដែរឬទេ?

**លោក ពាន ឃាន៖**

**ឆ៖** នេះគឺក្រោយដែលពេលខ្ញុំទៅស្វាយមាសហ្នឹង គឺ លីន បានបញ្ជូនមកក្រុងភ្នំពេញវិញ ធ្វើកម្មករជួសជុល ហើយកម្មករហ្នឹងមួយក្រុមធំដែរ ប្រហែលជាជិត១០០នាក់ដែរ។ អ៊ីចឹងកម្មករនេះការគ្រប់គ្រងផ្ដើមពី លីន ប៉ុន្តែប្រគល់ឱ្យ រ៉ា ជាអ្នកទទួលខុសត្រូវកន្លែងការងារ គឺពេលនោះ គឺមានអ៊ីចឹង។

**ស៖** គឺ រ៉ា នេះតាមឯកសារដែលបានបង្ហាញនេះ ជាកូនស្រីពៅរបស់ អៀង សារី។ តើអ៊ីចឹងដែរឬទេ?

[១០:៣១:២៦]

**ឆ៖** នៅពេលនោះ ខ្ញុំអត់បានស្គាល់ រ៉ា នេះជាកូនរបស់លោកអ៊ំណាទេ ប៉ុន្តែឮគេប្រាប់ខ្ញុំគឺអ៊ីចឹង។ ហើយខ្ញុំមិនបានស្គាល់ជាក់លាក់ទេ។

**ស៖** សូមអរគុណ។ ដូច្នេះ ដោយសារថា មនុស្សម្នាក់ដែលថា លោកធ្លាប់ទទួលបន្ទុកនៅស្វាយមាស តើភារកិច្ចអ្វីខ្លះដែលលោកធ្វើនៅកាលនោះ តើលោកចាំទេ?

**ឆ៖** ពាក្យដែលថា ទទួលបន្ទុកហ្នឹងគឺខ្ញុំដោយសារថា ខ្ញុំវាអត់បានយល់ន័យហ្នឹង ប៉ុន្តែតាមន័យដែលខ្ញុំចង់និយាយ គឺថា ខ្ញុំត្រូវទទួលបន្ទុកនឹងការលត់ដំខ្លួនខ្ញុំ ក៏ដូចជាអ្នកដទៃទៀតអ៊ីចឹងទេ។ មិនមែនខ្ញុំមានតួនាទី ឬជាអ្នកដឹកនាំធ្វើការងារអីក្រៅពីហ្នឹងទេ។

[១០:៣២:៥១]

**ស៖** ដូច្នេះលោកមិនទទួលខុសត្រូវគ្រប់គ្រងទៅលើអ្នកណាផ្សេងទៀតទេ តាមពិតលោកទទួល

ការលត់ដំ គេយកលោកទៅលត់ដំកន្លែងហ្នឹង តើអ៊ីចឹងឬទេ?

**ឆ៖** ចំណុចនេះ គឺពិតជាអ៊ីចឹង។

**ស៖** តើលោកចាំដែរឬទេ ថាតើស្វាយមាស មានលេខកូដ ឬក៏ជាឈ្មោះកាត់អីដែរឬទេ កាលណោះ នោះ?

**ឆ៖** ពេលនោះ ខ្ញុំមិនដឹងជាមានអីទេ គ្រាន់តែឮគេហៅថា វត្តស្វាយមាសៗ តែប៉ុណ្ណឹង។ ហើយ-- ស្វាយមាសហ្នឹង កន្លែងហ្នឹងមានវត្ត។ ហើយខ្ញុំទៅឃើញវត្តមែន វត្តចាស់។

**ស៖** លោកនិយាយថា គេបញ្ជូនលោកទៅជាមួយប្រពន្ធ ដើម្បីទៅទទួលការលត់ដំ។ តើលោកអាចរៀបរាប់ដោយសង្ខេបបានទេ ថាតើលក្ខខណ្ឌរស់នៅ ការងារ ហើយការហូបចុក គេឲ្យស្នាក់នៅរបៀបណានៅកន្លែងនោះ? បាទនិយាយដោយសង្ខេបជូនតុលាការ។

[១០:៣៤:៣៩]

**ឆ៖** នៅពេលនោះ ខ្ញុំជាមួយប្រពន្ធខ្ញុំ ការរស់នៅបាយទឹកអីមួយថ្ងៃ គឺពីរពេលធម្មតា។ ហើយការងារធ្វើតាមពេលម៉ោង ពីព្រឹកដល់ម៉ោងមួយដណ្ដប់សម្រាកធម្មតា ហើយពេលល្ងាចពីម៉ោងមួយអីចុះមកម៉ោងបួនអីធម្មតា ហើយខ្ញុំក៏ដូចជាអ្នកនៅក្នុងនោះ ទាំងអស់គ្នាដែរ។

**ស៖** នៅពេលដែលគេបញ្ជូនទៅដើម្បីធ្វើការលត់ដំនោះ ថាតើការលត់ដំមានអ្វីខ្លះជាផ្នែកនៃការលត់ដំលើរូបលោក ហើយនិងអ្នកផ្សេងទៀតនោះ?

**ឆ៖** ការលត់ដំ គេប្រគល់ជាភារកិច្ចការងារប្រចាំថ្ងៃ។ អ្នកខ្លះខាងតម្បាញ អ្នកខ្លះខាងជាងធ្វើកីអ៊ីចឹងទៅ អ្នកខ្លះខាងដាំបន្លែអ៊ីចឹងទៅ អ្នកខ្លះខាងភ្ជួរដីអ៊ីចឹងទៅ ចែកមុខសញ្ញាគ្នាអ៊ីចឹង ហើយក៏ប៉ុន្តែគេឲ្យធ្វើតាមពេលវេលាហ្នឹង ដូចខ្ញុំបានបញ្ជាក់ខាងដើម។

**ស៖** ខ្ញុំនឹងសួរសំណួរមួយ បាទ សំណួរពីរចុងក្រោយ លោក ពាន ឃាន នៅក្នុងប្រធានបទដាច់ដោយឡែកពីគ្នា ហើយខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យច្បាស់ថា ដើម្បីឲ្យលោកនឹកឃើញនូវពីការចងចាំ។ លោកបានប្រាប់តុលាការអំពីការស្នាក់នៅឧដុង្គ នៅដើមឆ្នាំ១៩៧៥ ជាមួយ កុយ ឃួន ហើយលោកបាននិយាយថា នៅពេលនោះ លោកបានដឹងអំពី ប៉ុល ពត, សុន សេន ហើយនិង យ៉ា។ នេះ នៅថ្ងៃទី០២ ខែឧសភា ដែលលោកបាននិយាយ។

[១០:៣៦:៥៧]

ហើយលោកបានប្រាប់យើងទៀត ថាហើយមានការប្រជុំមួយ ឬច្រើនដែលមានមេដឹកនាំបាន

ប្រជុំគ្នា ដើម្បីវាយ-- ការវាយប្រហារទីក្រុងភ្នំពេញ។ ថាតើមានការប្រជុំផ្សេងទៀតហ្នឹង លោកបានដឹងអ្វីក្រៅពីអ្វីដែលយើងបានសួរលោកដែរឬទេ ថាតើការប្រជុំទាំងនោះ គេប្រជុំក្នុងការគោលបំណងអ្វី? ការពិភាក្សារបស់គេលម្អិតខ្លះហ្នឹង អំពីរឿងអ្វីដែលលោកបានដឹងនោះ?

**ឆ៖** នៅពេលនោះ គឺមានតែ-- ដឹងតែផែនការវាយរំដោះទីក្រុងភ្នំពេញតែប៉ុណ្ណឹងទេ។ ឯក្រៅពីហ្នឹងទៀត អត់មានទេ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ លោក ពាន ឃាន បន្ទាប់ពីលោកបានមកភ្នំពេញ តើលោកបានឮ ធ្លាប់ឮថាមនុស្សទាំងអស់ ដែលស្ថិតនៅក្នុងរបប លន់ នល់ ហ្នឹង ជួបជោគវាសនាដូចម្ដេចទេ ដូច លន់ នល់, សិរិមតៈ ឬក៏ ឡុង បូរ៉េត តើអ្នកទាំងនោះ ជួបបញ្ហាអ្វីដែរឬទេ? លោកបានដឹងទេ?

**ឆ៖** ឈ្មោះអស់លោកទាំងនោះ ខ្ញុំអត់បានដឹងទេ ក្រោយមក។ ប៉ុន្តែគ្រាន់តែដឹងថា លោក លន់ នល់ ភៀសខ្លួនទៅសហរដ្ឋអាមេរិក ដែលអស់លោកឯទៀត ក្រៅពីហ្នឹងទៀត ខ្ញុំអត់បានដឹងទេ។

[១០:៣៩:០៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោក ពាន ឃាន ដែលលោកបានអញ្ជើញមកផ្ដល់សក្ខីកម្ម ហើយសូមអរគុណលោកប្រធាន ដែលបានអនុញ្ញាតពេលបន្ថែមតាមការស្នើសុំរបស់ខ្ញុំ។ សូមអរគុណ បាទ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរសវនាការ។ ហើយក្រោយពេលចូលសម្រាកនេះ គឺកិច្ចបន្តនៃការសួរដេញដោលចំពោះសាក្សីនេះ និង-- អង្គជំនុំជម្រះប្រគល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលពេលវេលាអង្គជំនុំជម្រះបានកំណត់តាមការសំណើសុំ គឺមួយម៉ោង ដប់នាទី។

បាទ សូមអញ្ជើញលោកមេធាវី!

[១០:៣៩:៥៨]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមអរគុណលោក លោកស្រីចៅក្រម ដោយសារបញ្ហាសុខភាពថ្ងៃនេះ លោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងសវនាការនេះ សម្រាប់រយៈ

ពេលទាំងអស់ដែលនៅសេសសល់នៅថ្ងៃនេះ ប៉ុន្តែសូមចូលរួមសវនាការដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោម។ អាស្រ័យដូចនេះ សូមលោកប្រធានមេត្តាពិចារណា និងសម្រេច។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពាររបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់មួយ ក្រោមបន្ទប់សវនាការនេះសម្រាប់រយៈពេលពេញមួយថ្ងៃនេះ ចាប់ពីពេលនេះទៅរហូតដល់ចប់សវនាការសម្រាប់ថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយតាមដានកិច្ចដំណើរសវនាការយូរបាន។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ សម្រាប់រយៈពេលនៃសវនាការបន្ត សម្រាប់ថ្ងៃនេះ។

[១០:៤១:១៩]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ អៀង សារី។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោមដែលមានរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤២នាទី ដល់ម៉ោង ១១:០៣នាទី)*

[១១:០៣:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធី ហើយជាកិច្ចបន្តនេះអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី-- មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ លោកសាក្សីជម្រាបសួរ។ ខ្ញុំពុំមានសំណួរច្រើនទេ ពីព្រោះថាលោកសហព្រះរាជអាជ្ញាបានចោទសំណួរច្រើនណាស់ទៅហើយ ក៏ប៉ុន្តែយើងនៅសល់សំណួរមួយចំនួនដែរ។

[១១:០៤:១៥]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ខ្ញុំសូមចាប់តែពីចំណុចចុងបញ្ចប់នៃការសួរចម្លើយរបស់លោក ហើយនិងនៅនឹងចំណុចចុងក្រោយដែលលោកបាននិយាយទៅកាន់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី២៦ សីហា នៅក្នុងឯកសារ D276/6 ហើយដែលលោកមានសំណួរសួរលោកថា "លោករំពឹងរង់ចាំអ្វីពី អ.វ.ត.ក?" ហើយលោកបានឆ្លើយថា ចង់ឲ្យ អ.វ.ត.ក រកយុត្តិធម៌ដល់ជាតិ ហើយនិងប្រជាជនកម្ពុជា"។ តើលោកចង់និយាយថាយ៉ាងម៉េច តាមរយៈពាក្យពេចន៍របស់លោកនេះ?

[១១:០៥:០៧]

**លោក ពាន ឃាន៖**

**ឆ៖** សូមអត់ទាន់យល់សំណួរ។

**ស៖** លោកបាននិយាយទៅសហចៅក្រមស៊ើបអង្កេតថា ខ្ញុំសូមឲ្យ អ.វ.ត.ក។ គឺថាអង្គជំនុំជម្រះវិសាមញ្ញដែលថាលោកមានវត្តមាននៅទីនេះតែម្តង "ខ្ញុំសូមឲ្យអង្គជំនុំជម្រះវិសាមញ្ញរកយុត្តិធម៌ឲ្យជាតិ ហើយនិងប្រជាជនកម្ពុជា"។ ខ្ញុំចង់ឲ្យលោកពន្យល់អំពីខ្លឹមសារនៃពាក្យពេចន៍ដែលលោកបាននិយាយនេះ។

**ឆ៖** ត្រង់ចំណុចនេះ ខ្ញុំមានចំណងថា សូមឲ្យសាលាក្តីហ្នឹងរកយុត្តិធម៌ឲ្យជនជាតិខ្មែរដែលរងគ្រោះហ្នឹងឲ្យវាបានពិតប្រាកដ ហើយកុំវាមានតទៅទៀតទៅថ្ងៃមុខថ្ងៃក្រោយ ឲ្យចប់ត្រឹមហ្នឹង។ ឲ្យប្រទេសកម្ពុជាមានភាពសុខសាន្ត យុត្តិធម៌ឡើងវិញ។

[១១:០៦:៤២]

**ស៖** សូមអរគុណលោក។ ព័ត៌មានដែលលោកបានផ្តល់មកយើងនៅថ្ងៃនេះ នេះគឺជារបៀបមួយដែលធ្វើឲ្យយើងអាចរកយុត្តិធម៌បានដល់ប្រជាជនកម្ពុជា។ អាស្រ័យហេតុដូច្នេះសូមឲ្យលោកឆ្លើយឲ្យបានច្បាស់លាស់បំផុត ហើយនិងលោកព្យាយាមនិងផ្តល់ព័ត៌មានមកយើងឲ្យបានច្រើនបំផុត។

សំណួរទីមួយរបស់ខ្ញុំមានដូចតទៅនេះ លោកបាននិយាយថា លោកបានត្រូវ-- ត្រូវបានជ្រើសរើសចូលទៅក្នុងបដិវត្តន៍នៅពេលដែលលោកមានអាយុ១៦ឆ្នាំ គឺបានន័យថានៅក្នុងវ័យកុមារនៅឡើយ។ បើលោកដឹង តើមានក្មេងៗច្រើនត្រូវបានជ្រើសរើសចូលទៅក្នុងបដិវត្តន៍ដែរឬទេ?

**ឆ៖** នៅពេលនោះបើតាមខ្ញុំចាំបាន គឺថា មានជាច្រើនគ្រប់ភូមិ គ្រប់ស្រុកដែលគេឲ្យចូលរួមក្នុងចលនាបដិវត្តន៍ហ្នឹង។ ពិសេសខាងរតនគិរី ជនជាតិភាគតិចក៏គេឲ្យចូលរួម។ និយាយរួម គេឲ្យចូលរួមទូទាំងប្រទេសតែម្តង មិនមែនតែចំពោះបុគ្គលខ្ញុំ។ ប៉ុន្តែក្នុងកាលៈទេសៈនោះ ជាជំហានដំបូងគ្រាន់តែខ្ញុំវាមុនគេ បុណ្ណឹង។ ដល់ក្រោយមកបន្តបន្ទាប់ទូទៅ ទូទាំងខេត្តរតនគិរី មិនថាក្មេងមិនថាចាស់។

[១១:០៨:៥៣]

**ស៖** សូមអរគុណ។ ដូច្នេះ គឺថាមិនប្រកាន់វ័យរបស់មនុស្សនោះទេ។ យោបល់លោកថាហេតុអ្វី ក៏នៅសម័យនោះគេជ្រើសរើសយកកុមារផងដែរ? តើលោកដឹងមូលហេតុទេ?

**ឆ៖** ខ្ញុំមិនបានដឹងពីមូលហេតុដែរ។

**ស៖** តើកុមារទាំងអស់នោះគេប្រគល់ភារកិច្ចអីឲ្យទៅ?

**ឆ៖** នៅពេលនោះ គឺដូចមិនឃើញមានការងារអីធំដុំទេ *(ឮមិនច្បាស់)* ដូចជាខ្ញុំជាដើម គេឲ្យធ្វើនីរសារ រត់ជូនសារ គេឲ្យដាំបន្លែ ដាំអី ធម្មតាៗ។

**ស៖** សូមអរគុណ។ តើនៅពេលណាមួយលោកធ្លាប់ជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** សមាជិកបក្សកុម្មុយនីស្តខ្ញុំអត់បានដឹងទេ។ គ្រាន់តែខ្ញុំដឹងថា ខ្ញុំចូលរួមជាចលនាជាមួយនឹងគេនឹងឯងប៉ុណ្ណឹង។

**ស៖** តើនៅសម័យនោះលោកមានប្រពន្ធហើយឬនៅ?

**ឆ៖** អត់ទាន់មានទេ។

**ស៖** មុនពេលដែលលោកមកដល់ទីក្រុងភ្នំពេញថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ លោកនៅធ្វើបដិវត្តន៍អស់រយៈពេលប្រហែលជា៧ឆ្នាំ។ តើនៅក្នុងរយៈពេលនេះ លោកធ្លាប់បានសង្កេតឃើញថាមានការបាត់ខ្លួនដែរឬទេ?

[១១:១២:១៧]

**ឆ៖** មុនពេលហ្នឹងអត់មានទេ អត់ដែលឃើញ។

**ស៖** តើមានអ្នកណាដែលគេត្រូវបានគេនាំខ្លួនទៅអប់រំ ថានៅមុន-- អ៎! ក្នុងរយៈពេលហ្នឹង ថាមុនឆ្នាំ១៩៧៥ហ្នឹង?

**ឆ៖** អត់ដែលឃើញ។

**ស៖** លោកបានប្រាប់ថា លោកបាននៅជាមួយ កុយ ធួន អស់រយៈពេល១០ឆ្នាំ ហើយនិងជាមួយប្រពន្ធគាត់ផងដែរ ថាក្នុងរយៈពេល១០ឆ្នាំ។ លោកបានជម្រាបថា គាត់មិនដែលនិយាយអំពីការងាររបស់គាត់មកលោកទេ។ តើគាត់ធ្លាប់និយាយអំពីបដិវត្តន៍មកដល់លោកដែរឬទេ?

**ឆ៖** គាត់ធ្លាប់និយាយពីរឿងបដិវត្តន៍។ បដិវត្តន៍ហ្នឹងតស៊ូរំដោះជាតិ គំនិតគ្រាន់តែតែងក្រើនរំឭកថា ឲ្យយើងប្រជាជន និយាយរួមខ្មែរទូទាំងប្រទេសហ្នឹង ត្រូវក្រោកឈរឡើងធ្វើបដិវត្តន៍ដើម្បីរំដោះជាតិ រំដោះពីចក្រពត្តិអាមេរិក។

**ស៖** តើមុនពេលចាប់ខ្លួនគាត់បន្តិចបន្តួចនោះ គាត់ធ្លាប់បាននិយាយអំពីការព្រួយបារម្ភរបស់គាត់ ទាក់ទងនឹងសុវត្ថិភាពរបស់គាត់ផ្ទាល់ដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ។

[១១:១៤:៥០]

**ស៖** លោកបាននិយាយថា នៅពេលដែលគាត់ចាប់ខ្លួន លោកត្រូវបានបញ្ជូនទៅ-- លោកត្រូវបានគេប្រើឲ្យយកចំណីអាហារទៅឲ្យគាត់។ ហើយលោកដឹង-- ហេតុអីបានជាគេបញ្ជូនលោកឲ្យយកម្ហូបអាហារទៅឲ្យគាត់?

**ឆ៖** ពេលនោះ ប៉ង់ អ្នកចាត់តាំងឲ្យខ្ញុំយកទៅ។

[១១:១៥:៤៣]

**ស៖** តើ ប៉ង់ បានឲ្យលោកបំពេញភារកិច្ចអីផ្សេងទៀតក្រៅពីយកម្ហូបអាហារទៅឲ្យគាត់ដែរឬទេ? គឺថាតើ ប៉ង់ បានប្រើឲ្យលោកនិយាយអ្វីមួយទៅលោក កុយ ធួន ហ្នឹងដែរឬទេ?

**ឆ៖** អត់មានទេ។

**ស៖** លោកបានប្រាប់យើងថា លោកធ្វើការនៅច្រាំងចំរេះ ក្នុងរយៈពេលមួយចំនួននោះគឺថារហូតដល់ពេលចាប់ខ្លួនរបស់លោក កុយ ឃួន តើលោកដឹងថា អ្នកណាដែលមកជំនួសលោក កុយ ឃួន ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** តើលោកស្គាល់លោក សូ ហុង ដែរឬទេ?

**ឆ៖** លោក សួរ ហុង ខ្ញុំបានស្គាល់គាត់ ព្រោះគាត់នៅជាពេទ្យរបស់អ៊ំ ប៉ុល ពត ផ្ទាល់។ ហើយក្រោយរំដោះភ្នំពេញ លោក សួរ ហុង ហ្នឹងគាត់នៅក្រសួងការបរទេស។ ប៉ុន្តែខ្ញុំមិនបានទំនាក់ទំនងជាមួយគាត់ទៀតទេ។

[១១:១៨:០២]

**ស៖** តើមានគេដែលធ្លាប់សួរចម្លើយលោកដែរឬទេ នៅពេលដែលលោក កុយ ធួន ត្រូវបានគេចាប់ខ្លួនហើយនោះ?

**ឆ៖** គេអត់ដែលសួរចម្លើយទេ ចំពោះរូបខ្ញុំ ប៉ុន្តែអ្នកក្រៅពីខ្ញុំ គេបំបែកចេញពីច្រាំងចំរេះហ្នឹងទៅអង្គភាពផ្សេងៗអស់ទៅ ប៉ុន្តែមិនដឹងនៅកន្លែងណាខ្លះ ខ្ញុំមិនចាំដែរ។

**ស៖** ទាក់ទងទៅនឹងវត្តស្វាយមាស តើលោកដឹងថា អ្នកណាអ្នកសម្រេចបញ្ជូនមនុស្សទៅស្វាយមាសហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងដែរ។

**ស៖** នៅពេលដែលលោកធ្វើការនៅស្វាយមាស ជាមួយនឹងអ្នកផ្សេងទៀត តើលោកធ្លាប់បានឮនិយាយថា គេបញ្ជូនមនុស្សពីវត្តស្វាយមាសហ្នឹងទៅមន្ទីរស-២១ តើលោកធ្លាប់ឮដែរឬទេ?

**ឆ៖** អត់ដែលឮទេ។

[១១:២០:០០]

**ស៖** នៅពេលដែលលោកធ្វើការនៅស្វាយមាសនោះ មានអ្នកដែលចេញពីស្វាយមាសទៅកន្លែងផ្សេងទៀតដែរឬទេ?

**ឆ៖** ខ្ញុំចាំមិនបាន ព្រោះទៅនៅរយៈខ្លីដែរ ហើយមកនៅភ្នំពេញទៅ។

**ស៖** កាលពីព្រឹកមិញនេះ គឺថាលោកសហព្រះរាជអាជ្ញាបានអានវគ្គមួយនៃកិច្ចសម្ភាសរបស់លោក ដែលនៅក្នុងវគ្គនេះ លោកបានលើកឈ្មោះ ខាំ មី។ តើ ខាំ មី ហ្នឹងជាអ្នកណាទៅ?

**ឆ៖** ខាំ មី បើតាមខ្ញុំចាំ គឺប្រធានយោធា ប្រធានកងការពារយោធា ហៅថា យ-១០។

**ស៖** ហើយអង្គភាពហ្នឹងឈ្មោះអ្វីដែរ?

**ឆ៖** អង្គភាព យ-១០។

[១១:២១:៥១]

**ស៖** បាទ សូមអរគុណ។ តើអង្គភាពហ្នឹងទទួលបន្ទុកខាងចាប់ខ្លួនមនុស្សមែនដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ មិនដែលឃើញផង។

**ស៖** តើមេរបស់ ខាំ មី ហ្នឹងឈ្មោះអ្វី?

**ឆ៖** និយាយរួម ខាំ មី គាត់ទទួលពី បទបញ្ជាពី ប៉ង់ ដែរ បើតាមខ្ញុំដឹង។

**ស៖** ហើយ ប៉ង់ ទទួលបញ្ជាពីអ្នកណាដែរ ប៉ង់ ហ្នឹង?

**ឆ៖** ប៉ង់ ជាធម្មតាទទួលបញ្ជាផ្ទាល់ពី អ៊ំ ប៉ុល ពត តែម្តង។

**ស៖** លោកបាននិយាយថា លោកត្រូវបានគេចោទថាលោកជាជនក្បត់ ហើយលោកមិនយល់ពីមូលហេតុនៃការចោទប្រកាន់នេះទេ តើលោកដឹងថាអ្នកណាជាអ្នកចោទប្រកាន់លោកថា លោកជាជនក្បត់នេះដែរឬទេ?

**ឆ៖** ជាធម្មតា បើថាពេលនោះ បើចាប់មេអង្គភាពណាមួយ ឬក៏ថ្នាក់ណាមួយ អ្នកនៅជាមួយគឺគេចោទថាជាមនុស្សសមាសភាព។ មនុស្សសមាសភាពបីដូចថា ជាសមាសភាព បើថាបុគ្គលនុ៎ងក្បត់ អ្នកនៅជាមួយហ្នឹងគឺគ្រាន់តែជាប់និន្នាការជាមួយនឹងគេដែរ។ អ៊ីចឹងចំពោះខ្ញុំ ខ្ញុំចេះតែភ័យបារម្ភដូច្នេះ។

[១១:២៤:៤៨]

**ស៖** លោកបាននិយាយថា នៅដើមខែឧសភា ហ្នឹង គឺថាអង្គការជាអ្នកចាប់លោក កុយ ឃួន ដែលជាមេរបស់លោក។ ហើយសព្វថ្ងៃនេះ លោកនិយាយថាអ្នកនៅក្រោមបង្គាប់តែងតែ-- ឬក៏ជាទូទៅតែងតែត្រូវបានចាប់ខ្លួនផងដែរ។ លោកនិយាយថា "មានទំនាក់ទំនងរវាងការចាប់ខ្លួនលោក កុយ ធួន ហើយនិងការដែលចោទប្រកាន់មកថា លោកជាជនក្បត់" តើលោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ចំណុចនេះ ខ្ញុំគ្រាន់តែជាការស្រម៉ៃ ហើយនិងការព្រួយបារម្ភរបស់ខ្ញុំទេ។ គេមិនដូចថាចោទខ្ញុំជាជនក្បត់ជាក់លាក់ទេ ប៉ុន្តែជាការបារម្ភរបស់ខ្ញុំ។ ខ្ញុំចេះតែភ័យខ្លាចអ៊ីចឹងទៅ ព្រោះឃើញមនុស្សទូទៅនៅអង្គភាពនោះ គេអ្នកធ្លាប់នៅជាមួយគ្នា វាបាត់អស់ទៅ មិនដែលបានជួបគ្នា។ អ៊ីចឹងខ្លួនឯងចេះតែភ័យទៅ។

[១១:២៦:២៦]

**ស៖** ក៏ប៉ុន្តែ បើសិនជាអង្គការជាអ្នកសម្រេចចាប់ កុយ ធួន តើអ្នកណាសម្រេចចាប់ខ្លួនអ្នកនៅក្រោមបង្គាប់របស់លោក កុយ ធួន ធ្វើឲ្យអ្នកទាំងអស់នោះបាត់ខ្លួននោះ។ អ្នកណាគេជាអ្នកសម្រេច?

**ឆ៖** សំណួរនេះ ខ្ញុំអត់បានដឹងទេ មិនដឹងជាខាងណាជាអ្នកសម្រេចទេ ខ្ញុំគ្រាន់តែយល់ប៉ុណ្ណឹង។

**ស៖** លោកសាក្សី ក្នុងការងារបដិវត្តន៍របស់លោក គឺថានៅក្នុងចន្លោះឆ្នាំ១៩៦៨ ដល់១៩៦៩ តើលោកគោរពបញ្ជារបស់មេកោយរបស់លោកដែរឬទេ?

**ឆ៖** ជាធម្មតា ក្រឹត្យក្រមការងារគេពេលនោះ យើងត្រូវចាត់តាំងបុគ្គលណាឲ្យធ្វើអ្វីមួយមិនតែចំពោះរូបខ្ញុំទេ។ ជាទូទៅ គឺត្រូវតែធ្វើ ធ្វើតាម ត្រូវតែគោរព។

[១១:២៨:៣២]

**ស៖** ចុះបើសិនជាលោកមិនស្តាប់បញ្ជាវិញនោះ មានរឿងអ្វីកើតឡើងទៅ?

**ឆ៖** បើសិនជាករណី--

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេ សំណួរឧបមាណវិធី!

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរអម្បាញ់មិញទេ។ សំណួរឧបមាណវិធី អង្គហេតុនេះមិនមានកើតទេ។ សំណួរនៅក្នុងសវនាការនេះ មិនអាចយករឿងឧបមាអង្គហេតុដែលមិនកើតមានមកតាំងសំណួរចំពោះសាក្សីបានទេ។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** តើលោកបានសង្កេតឃើញអ្វីនៅពេលដែលមានអ្នកណាម្នាក់មិនគោរពបញ្ជា? តើលោកបានសង្កេតឃើញថាមានរឿងអ្វីកើតឡើងទេ? តើលោកធ្លាប់ឃើញ ឬក៏ធ្លាប់ឮពាក់ព័ន្ធនឹងបញ្ហានេះដែរឬទេ?

[១១:៣០:០០]

**លោក ពាន ឃាន៖**

**ឆ៖** ជាទូទៅ និងជាអចិន្ត្រៃយ៍ គ្រាន់ឃើញថា ការប្រជុំដកពិសោធ ពេលថ្ងៃធ្វើការអ៊ីចឹង គេចាត់តាំងធ្វើការអ៊ីចឹងទៅ ពេលល្ងាចប្រជុំដកពិសោធទៅ ហើយត្រង់ណាដែលយើងធ្វើមិនបាន គេទិតៀនៗទៅ គេថា អ្ហ៎! អ្នកឯងធ្វើមិនទាន់បានទេអានេះ ធ្វើមិនទាន់បានល្អទេ ឥឡូវស្អែកហ្នឹង ឬក៏ថ្ងៃក្រោយទៀតធ្វើឲ្យបានល្អ។ ហើយជាទូទៅ គឺអ៊ីចឹង។

**ស៖** ដោយសារតែលោកមានបទពិសោធន៍នៅក្នុងបដិវត្តន៍ តើលោកមានលទ្ធភាពឬក៏អាចមានសេរីភាពក្នុងការបដិសេធមិនទទួលយកការប្រគល់ភារកិច្ចអីមួយឲ្យលោកធ្វើដែរឬទេ?

**ឆ៖** មានដែរ ឧទាហរណ៍ថា ធ្វើនីរសារហ្នឹងទៅឆ្ងាយ ទៅម្នាក់ឯង មិនហ៊ានទៅ ឬក៏ពេលថ្ងៃ ឬក៏ពេលយប់មានឧបសគ្គអី ដែលសន្និដ្ឋាន ខ្លួនឯងសន្និដ្ឋានទៅថាទៅវាមិនកើត ក៏ធ្លាប់បដិសេធដែរ។

**ស៖** ចុះចំពោះបញ្ជាដែលគេផ្តល់ ដែលគេបញ្ជាលោកនោះ តើលោកអាចបដិសេធទេចំពោះបញ្ជាទាំងនុ៎ង?

**ឆ៖** ដូចខ្ញុំបានបញ្ជាក់ខាងដើមអំមិញហើយ ត្រង់ណាខ្ញុំមិនអាចធ្វើបានខ្ញុំត្រូវតែបដិសេធ កន្លែងណាអាចខ្ញុំធ្វើទៅបាន អាហ្នឹងខ្ញុំធ្វើ។

[១១:៣២:៤២]

**ស៖** សូមអរគុណ។ ខ្ញុំនឹងសួរសំណួរចុងក្រោយ កាលពីថ្ងៃទី០២ ខែឧសភា លោកបាននិយាយថា កុយ ឃួន ត្រូវបានអង្គការចាប់ខ្លួន។ ហើយបន្ទាប់មកសហព្រះរាជអាជ្ញាបានសួរថា តើនរណាជាអង្គការ? លោកបាននិយាយថា គឺជាមេដឹកនាំ។ បន្ទាប់មកសហព្រះរាជអាជ្ញា បានសួរថា តើនរណាជាមេដឹកនាំហ្នឹង? ហើយលោកបានឆ្លើយថា គឺ ប៉ុល ពត, នួន ជា, អៀង សារី និង ខៀវ សំផន ក៏ដូចជាសុន សេន ផងដែរជាមេដឹកនាំ។ កុយ ឃួន ត្រូវបានអង្គការចាប់ខ្លួន ហើយចុះ ប៉ង់? ប៉ង់ ដែលជាប្រធានមន្ទីរ ក-១, ក-៣ ហើយនិងជាប្រធានមន្ទីរ ៨៧០។ តើអ្នកណាជាអ្នកបញ្ជាឲ្យចាប់ខ្លួន ប៉ង់?

**ឆ៖** ចំណុចនេះខ្ញុំអត់បានដឹងទេ មិនដឹងថានរណាបញ្ជាទេ ប៉ុន្តែគ្រាន់តែដឹងថាបាត់ខ្លួន គាត់ៗបាត់ខ្លួនប៉ុណ្ណឹង។

[១១:៣៤:០៦]

**ស៖** តើអ្នកណាដែលនៅពីលើ ប៉ង់? ជាថ្នាក់លើរបស់ ប៉ង់ នោះ?

**ឆ៖** ប៉ង់ គាត់ទទួលបទបញ្ជាពី អ៊ំ ប៉ុល ពត តែម្តង។ រាល់កិច្ចការអ្វីទាំងអស់។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

សូមអភ័យទោស ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហមេធាវីនាំមុខអន្តរជាតិ-- អ៎!ជាតិ មេធាវីជាតិនៃសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[១១:៣៥:១០]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម ភាគីទាំងអស់ ហើយនិងសាលសវនាការទាំងមូល។ ខ្ញុំបាទ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនសម្រាប់រយៈពេលដែលនៅសេសសល់សម្រាប់ ដើម-- ខាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំសូមវិលបន្តិចមករយៈពេលដែលនៅឯរតនគិរី។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ខ្ញុំសូមសួរថា តើលោកដឹងទេនៅកាលដែលលោកធ្វើជានីរសារនៅរតនគិរី តើអ្នកណាគឺជាប្រធានតំបន់នៅរតនគិរី?

**លោក ពាន ឃាន៖**

**ឆ៖** នៅពេលនោះ ខ្ញុំអត់បានដឹងទេ។ មិនដឹងអ្នកណាប្រធានតំបន់ ឬស្រុកយ៉ាងណា ខ្ញុំអត់បានដឹងទេ។

[១១:៣៦:២៤]

**ស៖** នៅពេលនោះ លោកគឺជានីរសារនៅស្រុកអណ្តូងមាស តើលោកធ្វើជានីរសារបំពេញការងារសម្រាប់តែស្រុកអណ្តូងមាស ឬក៏លោកធ្វើជានីរសារសម្រាប់ឲ្យអ្នកផ្សេងក្រៅពីគណៈកម្មការស្រុកអណ្តូងមាសផងដែរ?

**ឆ៖** នៅពេលនោះ គឺនៅក្នុងក្របខ័ណ្ឌអណ្តូងមាសនេះឯង។

**ស៖** នៅពេលដែលលោកធ្វើជានីរសារ តើលោកមានធ្លាប់ទទួលនូវការបណ្តុះបណ្តាល ឬក៏ជាការប្រជុំអ្វីទេនៅឯអណ្តូងមាសនោះ?

**ផ៖** វាមិនមានអីជាខ្សែសង្វាក់ធំដុំទេ គ្រាន់តែប្រជុំដូចថា រំឭកឲ្យបំពេញភារកិច្ច ឲ្យធ្វើការងារហ្នឹងឲ្យបានល្អ នាំសំបុត្រទៅឲ្យបាន កុំឲ្យបាត់ អត់មានរៀនសូត្រជាខ្សែសង្វាក់អីទេ នៅពេលនោះ។

[១១:៣៧:៥៥]

**សៈ** តើពេលនោះ គេមានធ្លាប់ណែនាំលោកទេថា ប្រសិនបើលោកប៉ះពាល់ទៅដល់សំបុត្រទាំងអស់នោះ ថាតើអាចមានអ្វីកើតឡើងចំពោះលោក?

**ផ៖** នៅពេលនោះ គេគ្រាន់ឲ្យយើងប្រុងប្រយ័ត្នតែដល់-- ប្រសិនជាមានបញ្ហាយ៉ាងណាៗមួយបាត់សំបុត្រហ្នឹង ឬក៏យ៉ាងណាក៏គេមិនដែលនិយាយប្រាប់ខ្ញុំដែរ។

**សៈ** តើពេលនេះ-- ពេលនោះលោកមានធ្លាប់ទទួលការណែនាំអំពីគោលនយោបាយរបស់បក្សដែរឬទេ?

**ផ៖** ពេលនោះអត់ទេ។ អត់មានទេ។

**សៈ** ខ្ញុំសូមមកលើកសំណួរពាក់ព័ន្ធទៅនឹងកាលដែលលោកធ្វើជានីរសារនៅកំពង់ធំ។ ខ្ញុំចង់សួរថា តើក្រៅពីធ្វើនីរសារតើលោកមានធ្លាប់បានឃើញសកម្មភាពរបស់-- អ្វីខ្លះដែលគេធ្វើទៅលើប្រជាពលរដ្ឋដែលរស់នៅតំបន់ដែលលោកនៅឯកំពង់ធំនោះ?

[១១:៣៩:៤៨]

**ផ៖** ខ្ញុំអត់ដែលឃើញទេ។

**សៈ** តើលោកធ្លាប់ឮគេនិយាយថា មានការជម្លៀសដែរទេ នៅស្រុកសន្ទុក ហើយនិងស្រុកសណ្ដាន់ដែលលោកធ្លាប់នៅ?

**ផ៖** អត់ដែលឮ ដែលឃើញ។ ព្រោះអី ខ្ញុំទៅដល់ ឃើញប្រជាជននៅធម្មតា កកកុញតាមភូមិធម្មតា។

**សៈ** បាទ ខ្ញុំសូមចូលមករយៈពេលដែលមុន១៧ មេសា ឆ្នាំ១៩៧៥ តើពេលនោះ លោកនៅជាមួយលោក កុយ ធួន តែម្ដង ឬក៏យ៉ាងណា នៅក្នុងរយៈពេលចុងឆ្នាំ១៩៧៤ និងដើមឆ្នាំ១៩៧៥?

**ផ៖** ខ្ញុំនៅជាប់ជាមួយ កុយ ឃួន។

**សៈ** តើលោកមានដឹងទេ ថាលោក កុយ ឃួន គាត់ធ្លាប់មានទៅប្រជុំដែរទេ ក្នុងរយៈពេលនោះ?

**ផ៖** ខ្ញុំអត់យល់សំណួរ។

**ស៖** តើលោកមានធ្លាប់ដឹងទេ ថាលោក កុយ ឃួន មានទៅប្រជុំជាមួយអ្នកណាផ្សេងទេ នៅក្នុងរយៈពេលមុនវាយភ្នំពេញឆ្នាំ១៩៧៥?

[១១:៤១:៥៨]

**ឆ៖** ជាធម្មតា កុយ ឃួន មុននឹងមានផែនការអី ក៏ទទួលពី ប៉ុល ពត ដូចគ្នា។

**ស៖** លោកនិយាយថា លោក កុយ ឃួន ទទួលផែនការពី ប៉ុល ពត តើលោកធ្វើយ៉ាងម៉េច-- ដូចម្ដេចទៅ បានគាត់-- លោកដឹងថាលោក កុយ ឃួន ទទួលផែនការពី ប៉ុល ពត?

**ឆ៖** មូលហេតុដែលខ្ញុំថា លោក កុយ ឃួន ទទួលបញ្ជាពី ប៉ុល ពត ព្រោះមុន-- រាល់កិច្ចការអីក៏ដោយ គឺត្រូវតែ-- មុននឹងមានផែនការទៅណា ធ្វើអ្វី គឺ កុយ ឃួន ទៅប្រជុំជាមួយ ប៉ុល ពត អ៊ំប៉ុល ពត អ្នកសម្រេច។

**ស៖** ក៏ប៉ុន្តែលោកមានបានឃើញជាក់ស្ដែង ឬក៏លោកបានជូនដំណើរ កុយ ធួន ទៅប្រជុំជាមួយ ប៉ុល ពត ដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់ឃើញ។

**ស៖** តើប្រជុំនៅទីណា?

**ឆ៖** នៅចម្ការលើ។

**ស៖** តើប្រជុំអំពីការវាយភ្នំពេញដែលលោកបាននិយាយនេះ លោក កុយ ធួន គាត់ទៅប្រជុំជាមួយ ប៉ុល ពត នៅទីណា?

[១១:៤៤:០៣]

**ឆ៖** ខ្ញុំអត់ចាំកន្លែងទេ ប៉ុន្តែដឹងនៅចម្ការលើប៉ុណ្ណឹង។

**ស៖** តើលោក កុយ ធួន មានធ្លាប់ប្រជុំជាមួយ ប៉ុល ពត នៅកន្លែងផ្សេងទៀត មុននឹងវាយភ្នំពេញ?

**ឆ៖** ខ្ញុំអត់ដឹងទេ អត់បានដឹងទេ។ អត់បានឃើញ។

**ស៖** បាទ សូមអរគុណ។ សូមសំណួរបន្តទៀត តើលោកដឹងទេ ថាពេលណាដែលលោក កុយ ធួន ចូលមកភ្នំពេញ?

[១១:៤៥:១៦]

**ឆ៖** លោក កុយ ឃួន ចូលភ្នំពេញនៅពេលព្រមជាមួយនឹងពេលថ្ងៃរំដោះ ១៧ មេសា ហ្នឹង

តែម្តង ប្រហែលជាល្ងាចម៉ោងបួន ម៉ោងប្រាំអីហ្នឹងមកដល់ភ្នំពេញ។

**ស៖** តើពេលនោះលោកមានបានមកជាមួយលោក កុយ ឃួន នោះតែម្តង ឬក៏លោកចូលមកភ្នំពេញក្នុងពេលផ្សេងគ្នា?

**ឆ៖** លោក កុយ ឃួន គាត់ចូលមកមុន ហើយខ្ញុំចូលក្រោយប្រហែលជាម៉ោងបួនកន្លះអី ខ្ញុំចេញពីន៏ែ ឧដុង្គ គេហៅអី ដំណាក់ស្នាច់។

[១១:៤៦:២៥]

**ស៖** តើកន្លែងដំណាក់ស្នាច់ហ្នឹង ជាកន្លែងតែមួយជាមួយនឹង ប៉ុល ពត បោះទីតាំងនៅ ឬជាកន្លែងផ្សេងគ្នា?

**ឆ៖** កន្លែងនោះ គឺជាទីបញ្ជាការភូមិភាគ៣០៤ ដឹកនាំដោយ កុយ ឃួន ហ្នឹងតែម្តង កងពលភូមិភាគ។

**ស៖** នៅពេលដែលលោកធ្វើដំណើរមកភ្នំពេញ តើលោកធ្វើដំណើរមកហ្នឹងម្នាក់ឯង ជាក្រុម តើលោកមានឃើញទិដ្ឋភាពមនុស្សនៅតាមផ្លូវយ៉ាងដូចម្តេចដែរឬទេ?

**ឆ៖** ខ្ញុំមកពីទីកន្លែងនោះ មកភ្នំពេញ ដើរ-- ជិះម៉ូតូមកម្នាក់ឯងទេ ហើយមានគេឌុបមក។

**ស៖** តើលោកមានឃើញមនុស្សធ្វើដំណើរតាមផ្លូវដែរឬទេ?

**ឆ៖** តាមដងផ្លូវឃើញមានហូរហែ ឡាន អ្នកថ្មើរជើង។

**ស៖** តើលក្ខណៈរបស់មនុស្សទាំងអស់នោះជាមនុស្សប្រភេទយ៉ាងដូចម្តេច? ពួកគាត់ជាយោធា ឬក៏ជាមនុស្សយ៉ាងដូចម្តេច?

**ឆ៖** មិនមែនយោធាទេ គឺប្រជាជននៅក្រុងភ្នំពេញហ្នឹងតែម្តង។

**ស៖** ពួកគាត់ធ្វើដំណើរដោយខ្លួនឯងតែម្តង ឬក៏មានអ្នកណាគេអមដំណើរគាត់ជាមួយ?

[១១:៥០:00]

**ឆ៖** អត់ឃើញអ្នកណាគេអមទៅទេ។ ឃើញហូរហែទៅ។

**ស៖** តើលោកមានឃើញមានវត្តមានរបស់យោធាដែលដើរចេញពីភ្នំពេញដែរឬទេ?

**ឆ៖** អត់ឃើញទេ។

**ស៖** តើលោកមានឃើញមនុស្សចាស់ កុមារ ស្ត្រី ឬក៏ព្រះសង្ឃធ្វើដំណើរនៅក្នុងចំណោមប្រជាជនដែលចេញពីភ្នំពេញដែរឬទេ?

**ឆ៖** នៅពេលដាច់ភ្នំពេញភ្លាមៗ វាមិនសូវជាចេញច្រើនអ៊ូអរទេ ប្រហែលរយៈបីថ្ងៃក្រោយពីរំដោះភ្នំពេញ បានមានចេញច្រើនហូរហែ។

**សៈ** បាទ អរគុណ។ ខ្ញុំចង់សួរបញ្ជាក់ថែមបន្តិចទៀត នៅពេលដែលលោកធ្វើដំណើរចូលមកភ្នំពេញ លោកធ្វើដំណើរតាមផ្លូវណា?

**ឆ៖** ខ្ញុំធ្វើដំណើរពីឧដុង្គមក មកកំពង់ស្ពឺ ៗហើយបានឡើងមកវត្តភ្នំ។

[១១:៥២:០៩]

**សៈ** តើលោកអាចបញ្ជាក់បានទេ តើផ្លូវនោះជាផ្លូវជាតិ ឬក៏ថាជាផ្លូវយ៉ាងម៉េច?

**ឆ៖** ពីឧដុង្គមកកំពង់ស្ពឺគឺផ្លូវលំទេ។ ដល់កំពង់ស្ពឺមកភ្នំពេញបានផ្លូវជាតិ។

**សៈ** ពេលដែលលោកមកដល់វត្តភ្នំ តើលោកបោះទីតាំងនៅកន្លែងណានៃវត្តភ្នំ?

**ឆ៖** ខ្ញុំអត់ស្គាល់ ឮគេហៅថាផ្ទះបារាំងៗ នៅជាប់វត្តភ្នំ។

**សៈ** តើប្រវែងប្រហែលជាប៉ុន្មានម៉ែត្រពីវត្តភ្នំ?

**ឆ៖** ប្រហែលជាកន្លះគីឡូ។

**សៈ** លោកមានអាច-- អាចបញ្ជាក់បន្ថែមទេថាតើនៅទិសខាងណានៃវត្តភ្នំផ្ទះបារាំងហ្នឹង?

**ឆ៖** នៅពេលនោះខ្ញុំចាំមិនបាន ព្រោះអីខ្ញុំមិនដែលស្គាល់ភ្នំពេញ និងវត្តភ្នំនៅជ្រុងណាជ្រុងណីទៅដល់ដំបូង។ ព្រោះខ្ញុំនៅហ្នឹងរយៈខ្លីដែរ។

**សៈ** តើពេលនោះលោកបានជួបលោក កុយ ធួន-- កុយ ឃួន ភ្លាមឬយ៉ាងណា?

**ឆ៖** ខ្ញុំទៅដល់ដូចជួបគាត់ ជួប កុយ ឃួន ហ្នឹង នៅកន្លែងហ្នឹង។

[១១:៥៥:០០]

**សៈ** តើពេលនោះលោកមានបានធ្វើដំណើរ ចេញពីកន្លែងទីតាំងរបស់លោកដែរឬទេ?

**ឆ៖** ខ្ញុំក្តាប់សំណួរអត់បាន។

**សៈ** តើនៅពេលលោកមកដល់ផ្ទះបារាំងហ្នឹង លោកនៅកន្លែងផ្ទះបារាំងហ្នឹងតែម្តង ឬក៏លោកមានធ្វើដំណើរខ្លះដែរ នៅជុំវិញកន្លែងដែលជាទីតាំងរបស់លោក?

**ឆ៖** ខ្ញុំអត់បានដើរទៅណាទេ នៅ-- ទៅដល់ភ្លាមខ្ញុំនៅកន្លែងហ្នឹងហើយ។ ហើយក្រោយមកប្រហែលជាពីរបីថ្ងៃបានទៅនៅច្រាំងចំរេះ។

[១១:៥៦:១៨]

**សះ** ក្នុងរយៈពេលដែលលោកនៅទីនោះ ថាតើលោកមានបានឃើញប្រជាជននៅតំបន់នោះយ៉ាងម៉េចដែរ? ខ្ញុំចង់និយាយសំដៅទៅលើសកម្មភាព របស់ប្រជាជននៅទីនោះ ថាតើគាត់មានលក្ខណៈយ៉ាងដូចម្ដេចដែរ?

**ផះ** កាលខ្ញុំទៅដល់នោះ អត់ឃើញមានប្រជាជនទេ ស្ងាត់។

**សះ** បាទ ខ្ញុំចង់សូមបញ្ជាក់បន្ថិច នៅពេលដែលលោកឆ្លើយនឹងសំណួរខ្ញុំពីមុន លោកបាននិយាយថា ពេលដែលធ្វើដំណើរចូលភ្នំពេញ មិនសូវមានមនុស្សប៉ុន្មានទេ ដែលធ្វើដំណើរចេញពីភ្នំពេញ។ ប្រហែលជាក្នុងរយៈពេលពីរបីថ្ងៃក្រោយមក បានក្នុងរយៈពេលហ្នឹងបានមានការធ្វើដំណើរចេញច្រើនទៅចេញពីភ្នំពេញ។ ឥឡូវលោកមានប្រសាសន៍ថា អត់បានឃើញទេ អ៊ីចឹងតើធ្វើយ៉ាងដូចម្ដេចបានលោកដឹងថា មានប្រជាជនចេញពីភ្នំពេញក្នុងរយៈពេលបីថ្ងៃ បន្ទាប់ពីវាយបានភ្នំពេញ។

**ផះ** មូលហេតុដែលខ្ញុំថា ខ្ញុំមិនបានឃើញ ព្រោះអីពេលនោះ ខ្ញុំមកពីឧដុង្គមក មកដល់ភ្លាមវាស្ងាត់មែន ក៏ប៉ុន្តែខ្ញុំមកដល់ប្រហែលពីរបីថ្ងៃមកនៅវត្តភ្នំហ្នឹង ហើយខ្ញុំទៅនៅច្រាំងចំរេះ វាតាមផ្លូវជាតិផ្លូវព្រែកក្ដាមព្រែកអី ឃើញចេញហូរហែ។

[១១:៥៨:៤០]

**សះ** តើក្នុងរយៈពេលមុនលោកទៅច្រាំងចំរេះ ដែលលោកនៅភ្នំពេញហ្នឹង លោកមានចល័តនៅក្នុងទីក្រុងដែរឬទេ?

**ផះ** អត់មានទេ។

**សះ** នៅពេលដែលលោកធ្វើដំណើរទៅច្រាំងចំរេះ ឬក៏នៅច្រាំងចំរេះ តើលោកមានឃើញសកម្មភាពរបស់ប្រជាជនហ្នឹងយ៉ាងម៉េចដែរ ដែលគាត់ធ្វើដំណើរចេញហ្នឹង?

**ផះ** ដំណើរគាត់ចេញមក អ្នកខ្លះមានឡានជិះទៅ អ្នកខ្លះមានម៉ូតូ អ្នកខ្លះដើរ អ្នកខ្លះរុញរ៉ឺម៉កហូរហែអ៊ីចឹងទៅ។

[១១:៥៩:៥៥]

**សះ** តើគាត់មានការរីករាយទេ ដែលធ្វើដំណើរចេញពីភ្នំពេញ?

**ផះ** តាមដែលខ្ញុំសង្កេតមើល គឺមិនជារីករាយប៉ុន្មានទេ។

**សះ** តើពេលនោះមានទាហានខាងណា គេអមដំណើរប្រជាជនចេញពីភ្នំពេញដែរឬទេ?

**ផះ** អត់បានឃើញ។

**ស៖** នៅពេលដែលលោកនៅភ្នំពេញ ក្នុងរយៈពេលពីរបីថ្ងៃនោះ តើលោកមានធ្លាប់ឮសំឡេងគ្រាប់កាំភ្លើងដែរឬទេ?

**ឆ៖** អត់មានទេ ស្វាត់។

**ស៖** តើលោកមានឮសំឡេងស្រែក ឬក៏សំឡេងជជែកគ្នាខ្លាំងៗដែរឬទេ នៅតាមផ្លូវ?

**ឆ៖** អត់បានឮទេ។

[១២:០១:៤១]

**ស៖** តើកន្លែងដែលលោកនៅៗភ្នំពេញនោះ នៅឆ្ងាយពីផ្លូវដែរឬទេ?

**ឆ៖** ខ្ញុំនៅជាប់ផ្លូវចូលវត្តភ្នំហ្នឹង។

**ស៖** នៅពេលដែលមានប្រជាជនចេញពីភ្នំពេញ តើលោកមានបានដឹងទេអំពីការ-- មូលហេតុអ្វីបានជាប្រជាជនចេញពីភ្នំពេញ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ពីមូលហេតុយ៉ាងម៉េចក៏អត់ដឹងដែរ។

**ស៖** ខ្ញុំចង់សុំសួរលោក សួរសំណួរលោកចុងក្រោយថែមបន្តិចទៀត។ តើនៅពេលដែលលោកបានឆ្លើយជាមួយដៃគូរបស់ខ្ញុំថា ពេលនោះ នៅពេលដែលមានការចាប់លោក កុយ ឃួន មនុស្សដែលនៅខាងក្នុងអង្គភាពមានការព្រួយបារម្ភ ដោយសារការបាត់ខ្លួននេះ។ អ៊ីចឹងថាតើលោកមានដែលឮថាមានការបាត់ខ្លួននៅកន្លែងណាផ្សេង ឬក៏អង្គភាពណាផ្សេង ក្រៅពីអង្គភាពរបស់លោកដែរឬទេ?

**ឆ៖** ត្រង់ចំណុចនេះ ដូចខ្ញុំបានបញ្ជាក់ខាងដើមហើយ ខ្ញុំចាំច្បាស់តែ កុយ ឃួន ហើយនិង ប៉ង់ទេ។ ឯការដែលខ្ញុំព្រួយបារម្ភ ជាធម្មតាដូចថាម្ដាយនិងកូន ឬឪនិងឪពុកអ៊ីចឹង គេអ្នកគ្រប់គ្រងយើងគេ-- អ៊ីចឹងដល់គេចាប់មេទៅ កូនចេះតែព្រួយហើយ មិនដឹងជាកំហុសក៏ព្រួយដែរ ត្រូវតែព្រួយអ៊ីចឹងតែម្ដង។

[១២:០៤:៤០]

**ស៖** តើការព្រួយបារម្ភរបស់លោកហ្នឹង ៗមានលក្ខណៈយ៉ាងដូចម្ដេច? ព្រួយថារឿងនេះអាចកើតមានចំពោះលោក ឬក៏គ្រាន់តែព្រួយបារម្ភជាការមិនសប្បាយចិត្ត?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១២:០៥:២១]

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយភាគីទាំងអស់។ កាលណាសំណួរបែបនេះ ជាសំណួរច្រំដែល ហើយឥឡូវនេះម៉ោងដប់ពីរ ហើយលោកមេធាវីហាក់ដូចជាសួរសំណួរដដែលៗ ហើយសំណួរនេះ គឺបានសួររួចហើយ ហើយសាក្សីក៏បានឆ្លើយ។ ដូច្នេះ គឺជាការខាតពេលទេ តាមខ្ញុំសង្កេតទៅលោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការសង្កេតរបស់លោកមេធាវីការពារក្ដីលោក អៀង សារី។ មេធាវីព្យាយាមនិងខិតខំរិះរកសំណួរឯណាដែលចៀសវាងសំណួរដែលច្បាប់ហាមឃាត់។ សំណួរច្រំដែល សំណួរដឹកមុខ សំណួរឧបមាណវិធី អ្វី! ឬក៏សំណួរដែលមិនពាក់ព័ន្ធ ហើយជាពិសេសពេលវេលាមានកំណត់ គប្បីជ្រើសរើសនូវសំណួរសក្តានុពលទាំងឡាយមកតាំងសំណួរ ជៀសវាងជ្រើសរើសយកសំណួរបន្ទាប់បន្សំមកសួរដេញដោលដែលចំណាយពេលវេលាច្រើនឥតប្រយោជន៍។ មេធាវីទំនងមានប៉ុន្មានសំណួរទៀតឥឡូវនេះ ព្រោះពេលវេលាម៉ោងដប់ពីរ ប្រាំនាទីហើយ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកប្រធាន។

[១២:០៦:៤៥]

**ប្រធានអង្គជំនុំ៖**

អរគុណសាក្សី ឥឡូវនេះដល់ពេលអាហារថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះ ហើយសវនាការនឹងលើកបន្តទៅធ្វើនៅរសៀលនេះចាប់ផ្តើមពីម៉ោងមួយសាមសិបនាទី។ ហើយអរគុណសាក្សីដែលបានខិតខំក្នុងការផ្ដល់សក្ខីកម្ម ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅកន្លែងសម្រាកសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មព្រមទាំងមេធាវីប្រឹក្សារបស់គាត់ផងនៅវេលាម៉ោងមួយសាមសិបនាទីរសៀលនេះ។

សូមអញ្ជើញលោកមេធាវី!

**លោក អេនឌ្រូ អ៊ីន្ទូហ្វ៊ី៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរលោក លោកស្រី ហើយខ្ញុំសូមស្នើថាលោក នួន ជា គាត់នឿយហត់ ហើយសូមអនុញ្ញាតពីតុលាការទៅតាមដានពីបន្ទប់ខាងក្រោមនេះ ហើយយើងខ្ញុំនឹង

បំពេញបែបបទទៅតាមនីតិវិធី។ សូមអរគុណលោកប្រធាន។

[១២:០៧:៥១]

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់លោក នួន ជា ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សូមទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិទៅចូលរួមក្នុងកិច្ចសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយមូលហេតុនឿយហត់ មិនអាចបន្តតាមដានកិច្ចដំណើរសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះបាន។ អង្គជំនុំជម្រះយល់តាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមបន្ទប់សវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្តីជនជាប់ចោទ នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា ផង។

[១២:០៨:៥៦]

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ពេញមួយរសៀលថ្ងៃនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោមនៃបន្ទប់សវនាការនេះ ដោយរសៀលនេះទុកឲ្យ នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនៅឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀលនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោមឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៩ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តនេះអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

ជម្រាបសួរសាក្សី ពាន ឃាន! ខ្ញុំឈ្មោះ សុន អរុណ ខ្ញុំមេធាវីរបស់លោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួនសួរទៅលោកដូចតទៅនេះ៖

[១៣:៣៤:២៦]

**ស៖** លោកសាក្សីបើតាមខ្ញុំស្តាប់ចម្លើយនិងសំណួររបស់លោកជាមួយនឹងព្រះរាជអាជ្ញា ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកបានចូលធ្វើ-- ចូលទៅក្នុងបដិវត្តន៍យូរក្រែលដែលមកហើយ។ លោកបានចូលយូរមកហើយ ពីថ្ងៃមុនបានឮម្តងថា លោកបានឃើញៗទង់បដិវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំសូមសួរលោកថា តើលោករៀបរាប់អំពីសភាព និងទ្រង់ទ្រាយរបស់ទង់បដិវត្តនោះ តើយ៉ាងម៉េច សរសេរដោយដៃ ឬដោយអង្គុលីលេខ ឬក៏ស-ខ្មៅ ឬក៏មានពណ៌ ឬក៏ជាសៀវភៅ ឬជាកាសែត ឬទស្សនាវដ្តីរបៀបម៉េច? អាហ្នឹងសូមលោកមានប្រសាសន៍ជម្រាបអង្គសវនាការ។

[១៣:៣៥:៤៦]

**ឆ៖** បាទ សូមឆ្លើយចំពោះលក្ខណៈទ្រង់ទ្រាយនៃទង់បដិវត្ត។ តាមខ្ញុំធ្លាប់ឃើញ គឺមានសញ្ញាកណ្ដៀវ និងញញួរ ចំកណ្ដាល ព័ទ្ធកម្រងកួរស្រូវនៅពីក្រោម។ នោះ គឺទង់បដិវត្ត។ ហើយបើទង់ជាតិ គឺតំណាងឲ្យប្រទេសជាតិ គឺមានសញ្ញាប្រាសាទកំពូលបី ហើយប្រាសាទហ្នឹង មានពណ៌លឿង។ បើតាមខ្ញុំចំណាំឃើញ ប៉ុន្តែសរសេរដោយដៃ ឬក៏យ៉ាងណា ក៏ខ្ញុំមិនបានចំណាំដែរ។

**ស៖** បើអ៊ីចឹង មានន័យថា លោកបានឃើញតែពីក្របក្រៅរបស់ទង់បដិវត្តទេ មិនបានឃើញទាំងមូលដល់ក្នុងអី មាន ហើយសរសេរន័យយ៉ាងម៉េច មិនបានឃើញអ៊ីចឹងទេណ៎ា?

**ឆ៖** គឺអត់ទេ ឃើញតែខាងក្រៅទេ។

**ស៖** សូមអរគុណលោកសាក្សី។ លោកសាក្សី ពេលដែលលោកបាននិយាយតាំងពីសាកសួរ-- តុលាការសាកសួរលោកជិតពីរអាទិត្យហើយហ្នឹង លោកថាលោកបានស្គាល់លោក នួន ជា ដែរ។ ពិតប្រាកដអ៊ីចឹងទេ?

[១៣:៣៨:០៨]

**ឆ៖** ខ្ញុំទើបៗស្គាល់នៅគាត់ ក-៣ ទេ ដោយសារខ្ញុំបានទៅនៅចេញចូល ហើយធ្លាប់លើកបាយទឹកជូនគាត់ ហើយខ្ញុំក៏ធ្លាប់នៅចង្ក្រានបាយជាមួយប្រពន្ធគាត់នៅទីនោះដែរ នៅដាំស្ល។

**ស៖** អរគុណលោកសាក្សី។ លោកស្គាល់លោក នួន ជា ហ្នឹង តើស្គាល់ច្បាស់លាស់ទេ ឬក៏ថាគ្រាន់តែឃើញគាត់ដើរតាមផ្លូវ ឬក៏ថាឮគេចង្អុលប្រាប់ថា ហ្នឹង នួន ជា ហើយ ឬក៏លោកបានស្គាល់បានធ្លាប់និយាយអីលេង ឬនិយាយផ្លូវការជាមួយគាត់ដែរទេ?

**ឆ៖** ខ្ញុំធ្លាប់ស្គាល់គាត់ គ្រាន់តែថាទីមួយ បានលើកបាយទឹកឲ្យគាត់ពិសា ហើយការសំណេះសំណាលសួរសុខទុក្ខគ្នាទៅវិញទៅមក តែប៉ុណ្ណឹងទេ។

**ស៖** អរគុណ។ បើលោកបានស្គាល់អ៊ីចឹង មានន័យថា មិនបានជាស្និទ្ធណាស់ណា ប៉ុន្តែបានស្គាល់។ លោកអាចនិយាយប្រាប់តុលាការបាន ថាតើលោក នួន ជា ជាមនុស្សម្នាក់ដែលមានចរិតឃោរឃៅ ឬក៏ស្លូតបូត ឬក៏ថា ក្នុងរបៀបចរិតគាត់ជាអ្នកដឹកនាំ?

[១៣:៤០:១៥]

**ឆ៖** តាមខ្ញុំចំណាំធ្លាប់ឃើញគាត់ គាត់តែងរាក់ទាក់ធម្មតាជាមួយមហាជន។ មិនដែលឮមានបញ្ហាអីខុសប្រក្រតី ក្រៅពីនោះទេ។

**ស៖** អរគុណ។ លោកដឹង លោកនួន ជា គាត់មានមុខងារធ្វើអ្វីទេ ពេលនៅកំពុងបដិវត្តន៍?

**ឆ៖** កាលណោះខ្ញុំអត់ដែលស្គាល់គាត់ទេ កំពុងតែធ្វើបដិវត្តន៍។ ទើបតែរំដោះភ្នំពេញហើយ ចូលឆ្នាំ ចុងឆ្នាំ៧៥, ៧៦ បានខ្ញុំស្គាល់គាត់នៅ ក-៣ តែប៉ុណ្ណោះ។

**ស៖** មានដឹងមុខងារគាត់ធ្វើអ្វី? ធ្វើអីទេនៅក្រោយឆ្នាំ៧៥មក ដែលលោកបានធ្លាប់លើកបាយ លើកអីជូនគាត់ពិសាហ្នឹង? មុខងារគាត់ធ្វើអ្វី?

**ឆ៖** តាមខ្ញុំដឹងគឺគាត់តំណែងសភាប្រជាជន។

**ស៖** មានដឹង ក្រៅពីគាត់ធ្វើប្រធានសភាប្រជាជនហ្នឹងមានមុខតំណែងអីផ្សេងពីហ្នឹងទៀតទេ?

**ឆ៖** អត់ដែលដឹងទេ។

[១៣:៤២:៣១]

**ស៖** នៅ តាមឯកសារស្ទួរចម្លើយរបស់សហព្រះរាជអាជ្ញា-- សហចៅក្រមស៊ើបអង្កេតលេខ D276/6 ពេលនោះលោកឆ្លើយប្រាប់ទៅចៅក្រមស៊ើបអង្កេតថា លោកធ្វើការនៅខាងសំណង់បានកន្លះខែ កងទ័ពវៀតណាមបានវាយចូលមក។ ពេលនោះនៅចាំទេថា វៀតណាមវាយលុកចូលមកកម្ពុជាពេលណា? លោកចាំពេលវេលាបានទេ?

**ឆ៖** ខ្ញុំមិនចាំប្រាកដទេ។ ប៉ុន្តែដឹងថា ថ្ងៃ០៧ មករា ហ្នឹង ចាំបានតែប៉ុណ្ណឹង។

**ស៖** តើនៅឆ្នាំណា?

**ឆ៖** ឆ្នាំ៧៩។

[១៣:៤៣:៤៦]

**ស៖** មានន័យថា ០៧ មករា ឆ្នាំ១៩៧៩ អ៊ីចឹងទេណា? ត្រឹមត្រូវទេខ្ញុំនិយាយ?

**ឆ៖** បាទ គឺត្រឹមត្រូវអ៊ីចឹង។

**ស៖** ពេលដែលកងទ័ពវៀតណាមវាយចូលមកស្រុកខ្មែរ ជាពិសេសពេល៧៩ លោកបានឆ្លើយជម្រាបទៅខាងសហព្រះរាជអាជ្ញានិងដើមបណ្តឹងរដ្ឋប្បវេណី-- មេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា លោកចេញពីភ្នំពេញថ្ងៃ០៧ មករា ឆ្នាំ១៩៧៩។ ពេលហ្នឹងកងទ័ពវៀតណាមចូលមកដល់ភ្នំពេញហើយ។ លោកបានឃើញហ្នឹងភ្នែកលោកទេ ឃើញទ័ពវៀតណាមចូលមកភ្នំពេញទេ?

[១៣:៤៥:០០]

**ឆ៖** ខ្ញុំអត់បានឃើញផ្ទាល់ទេ ប៉ុន្តែឃើញក្បួនរថក្រោះ និងឡានតាមដងផ្លូវ ហើយមានអ្នកនៅភ្នំពេញហ្នឹងរត់ប្រសេចប្រសាច តាមផ្លូវ តាមថ្នល់ ហើយខ្ញុំចេះតែដើរ ដូចមកលិចមក មកផ្លូវជាតិ

លេខ៤ ទៅកំពង់ស្ពឺ ទៅឧដុង្គ ចេះទៅលិចៗអ៊ីចឹងទៅរហូតដល់ព្រំដែន។

**ស៖** អរគុណ។ អំមិញលោកឆ្លើយថា លោកមិនបានឃើញផ្ទាល់ទេ។ ប៉ុន្តែមួយពាក្យទៀត លោកឆ្លើយថា ឃើញរថក្រោះចូលមក។ រថក្រោះរបស់អ្នកណា?

**ឆ៖** ពេលនោះ គឺសភាពការណ៍ច្របូកច្របល់មិនចាំថាអ្នកណា ប៉ុន្តែគ្រាន់តែឮគេនិយាយថា រថក្រោះវៀតណាមផង រថក្រោះខ្មែរផង។ ហ្នឹងវាច្របូកច្របល់មិនអាចសម្គាល់បានជាក់លាក់។

[១៣:៤៦:៣៦]

**ស៖** អរគុណ។ សំណួរមួយទៀត លោកបាននិយាយច្រើនដងហើយ ថាលោកស្គាល់ ប៉ង់ និង លឹន ច្បាស់លាស់ ហើយមានការជិតដិតជាមួយ ប៉ង់ និង លឹន ផង។ បើលោកស្គាល់ច្បាស់លាស់ តើ ប៉ង់ ជាមនុស្សយ៉ាងណា? ប៉ង់ ជាមនុស្សស្លូតបូត ត្រឹមត្រូវ ឃោរឃៅ យកគេទៅធ្វើបាប អ៊ីចឹង ឬយ៉ាងម៉េច? បើលោកស្គាល់ច្បាស់ សូមលោកជម្រាបមកតុលាការផង។

**ឆ៖** ខ្ញុំស្គាល់ច្បាស់ គឺតាមរយៈការរស់នៅនិងការធ្វើការងារ ព្រោះគាត់អ្នក-- ការងារអ្វីក៏ខ្ញុំទទួលពីគាត់ គាត់អ្នកបញ្ជា។ ឧទាហរណ៍ថា ធ្វើការងារដឹកបន្លែ ឬក៏ធ្វើអីមួយ ទទួលពីគាត់ ហើយគាត់មិនដែលឃើញស្តីបន្ទោសអីធ្ងន់ធ្ងរទេ គ្រាន់តែប្រាប់ធ្វើនេះ ធ្វើនោះ។ ហើយការនិយាយលេងសើចធម្មតា គាត់ដូចមិនមានចរិតអី ឃោរឃៅអីទេ។

[១៣:៤៨:២៣]

**ស៖** សូមអរគុណ។ ពេលដែលថ្ងៃ០៧ មករា ឆ្នាំ១៩៧៩ ហ្នឹង លោកចេញពីភ្នំពេញ។ ពេលនុ៎ង ទ័ពវៀតណាមចូលមក លោកឃើញមានសភាពយ៉ាងម៉េចនៅភ្នំពេញហ្នឹងរញ៉េរញ៉ៃ ឬក៏ថា មនុស្សនៅស្ងៀមក្នុងផ្ទះ? ឬយ៉ាងម៉េចពេលហ្នឹង? គឺលោកជម្រាបអង្គសវនាការឲ្យបានដឹងផង ថាពេលហ្នឹងលោកឃើញនឹងភ្នែកច្បាស់លាស់ តើសភាពនៅភ្នំពេញយ៉ាងម៉េច?

**ឆ៖** នៅពេលនោះ ដូចខ្ញុំបានបញ្ជាក់ខាងដើមហើយថា មានសភាពច្រួលច្របល់ ទាំងតាមផ្ទះ ទាំងតាមដងផ្លូវ មានភាពរញ៉េរញ៉ៃដែរ។

**ស៖** រញ៉េរញ៉ៃហ្នឹង រញ៉េរញ៉ៃបែបរត់ចេញពីក្រុងភ្នំពេញ ឬក៏រញ៉េរញ៉ៃវ៉ៃតប់គ្នា ច្បាំងគ្នានៅភ្នំពេញហ្នឹងទៀត ឬយ៉ាងម៉េច? បាទ សូមបញ្ជាក់ឲ្យច្បាស់បន្តិច។

[១៣:៥០:០៦]

**ឆ៖** ភាពរញ៉េរញ៉ៃហ្នឹងគឺ ការរត់ហ្នឹងតែម្តង រត់ចេញតាមផ្ទះ ពីផ្ទះ តាមដងផ្លូវ ហើយមិន

ឃើញការវ៉ៃច្បាំងគ្នាទេ ប៉ុន្តែវាគ្រាន់តែមានភាពរញ៉េរញ៉ៃប៉ុណ្ណឹង។

**ស៖** អរគុណ។ នៅមុនឆ្នាំ១៩៧៥ ក្នុងអំឡុងពេលដែលលោកតស៊ូក្នុងបដិវត្តន៍ ដើម្បីរំដោះប្រទេសចេញពីពួកចក្រពត្តិ តើលោកមានដែលជួបប្រទះនឹងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកដែរឬទេ?

**ឆ៖** ខ្ញុំបានធ្លាប់ជួបប្រទះនៅកំពង់ធំ មិនមែននៅទីក្រុងកំពង់ធំទេ គឺនៅជុំវិញកំពង់ធំហ្នឹង នៅខេត្តកំពង់ធំហ្នឹងមានទាំងអាម៉ិច និងបេ៥២ ជួនកាលក៏ទម្លាក់ថ្ងៃ ជួនកាលក៏យប់អ៊ីចឹងទៅ។ ហើយម្ដងៗ បេ៥២ ហោះម្ដងជួនក៏ពីរគ្រឿង ជួនបីគ្រឿង ទម្លាក់។ ហ្នឹងធ្លាប់ឃើញ។

[១៣:៥១:៤២]

**ស៖** អរគុណណាស់។ លោកមានសាច់ញាតិបងប្អូនហ្នឹងរងគ្រោះ ដោយសារការទម្លាក់គ្រាប់បែករបស់អាមេរិកាំងហ្នឹងទេ ដែរឬទេ?

**ឆ៖** មិនមានទេ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីផ្អាកតិចសិន! ផ្អាក!

លោកមេធាវីការពារក្ដីលោក អៀង សារី ដឹងបញ្ហាលោក អៀង សារី ទេ?

**លោក អាង ឧត្តម៖**

អត់បានដឹងទេទាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៤:០៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអាចប្រាស្រ័យទាក់ទងជាមួយកូនក្ដីរបស់លោក។ សួរទៅគាត់មានបញ្ហាអី?

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៤:២០]

*(មេធាវីការពារក្ដីលោក អៀង សារី ទៅជួបកូនក្ដីនៅបន្ទប់សោតទស្សន៍ដើម្បីសួរនាំអំពីបញ្ហាសុខភាព)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[១៣:៥៧:៣០]

**លោក ម៉ម រិទ្ធា៖**

សូមគោរពលោកប្រធាន សាក្សីគាត់ត្រូវការទៅអញ្ជើញទៅបន្ទប់ទឹកបន្តិច។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

*(សាក្សីទៅបន្ទប់ទឹក)*

[១៣:៥៧:៥៩]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ លោក អៀង សារី មានបញ្ហាសុខភាពល្មមគួរសមដែរ ប៉ុន្តែដោយសារអន្តរាគមន៍ពីលោកគ្រូពេទ្យបន្ទាន់បង្ហំទៅ គាត់មានស្ថានភាពធូរស្រាលបន្តិច។ ក៏ប៉ុន្តែមិនទាន់ផុតពីការតាមដានយកចិត្តទុកដាក់របស់គ្រូពេទ្យទេ។

ខ្ញុំបានដំណឹងពីគ្រូពេទ្យថា គេនឹងចាត់ការនាំគាត់ទៅមន្ទីរពេទ្យឥឡូវនេះ។ ក៏ប៉ុន្តែយ៉ាងណាក្តីដើម្បីសន្សំពេលវេលា ខ្ញុំបានពិគ្រោះជាមួយលោក អៀង សារី ហើយថា យើងអាចបន្តសវនាការបានដោយមិនចាំបាច់មានវត្តមានគាត់ទេ។ វាលែងតែក្នុងករណីចាំបាច់ណាមួយ ខ្ញុំបាទនឹងជម្រាបតាមក្រោយ តែពេលនេះយើងអាចបន្តបានដោយអវត្តមានរបស់គាត់។ សូមអរគុណលោក។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៩:៤០]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដោយសារបញ្ហាសុខភាពធ្ងន់ធ្ងរចំពោះជនជាប់ចោទ អៀង សារី ហើយអង្គជំនុំជម្រះអនុញ្ញាតឲ្យគ្រូពេទ្យបញ្ជូនគាត់ទៅកាន់មន្ទីរពេទ្យ ដើម្បីពិនិត្យព្យាបាលជាបន្ទាន់ឥឡូវនេះ។ ហើយអម្បាញ់មិញនេះខាងមេធាវីការពារក្តីលោក នួន ជា អ៎! លោក អៀង សារី បានបង្ហាញជំហរច្បាស់លាស់គឺបានពិភាក្សាជាមួយនឹងជនជាប់ចោទ ថាខ្លួនយល់ព្រមឲ្យអង្គជំនុំជម្រះដំណើរការនៅពេលនេះដើម្បីសន្សំពេលវេលា ជំរុញឲ្យល្បឿននៃកិច្ចដំណើរការសវនាការហ្នឹងទៅមុខ។ ហើយអង្គជំនុំជម្រះដោយ

ផ្អែកតាមវិធាន៨១ អនុវិធាន៥ ដែលអាចឲ្យអង្គជំនុំជម្រះបន្តកិច្ចដំណើរការសវនាការបាន ដោយសារមានការយល់ព្រមពីជនជាប់ចោទ ដែលខ្លួនបានសម្រេចចិត្តថាអវត្តមាននៅក្នុងកិច្ចដំណើរការ។ ហើយអម្បាញ់មិញនេះគឺច្បាស់លាស់ហើយ ដោយសារមេធាវីរបស់គាត់បានពិភាក្សាជាមួយនឹងកូនក្ដីរបស់គាត់ ហើយបង្ហាញយ៉ាងជាក់ច្បាស់។ ដូច្នេះអង្គជំនុំជម្រះនៅតែបន្តការធ្វើសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។ ម្យ៉ាងទៀត ការដេញដោលសាក្សីរូបនេះ ឃើញថាយើងលើកពីរដងហើយ ហើយមានបញ្ហា ពីមុនដោយសារខ្លួនគាត់មានបញ្ហាសុខភាព ឥឡូវនេះគាត់ហាក់ដូចជាមានបញ្ហាសុខភាពល្អ ដែលអាចអំណោយផលក្នុងការដេញដោលឲ្យចប់សក្ខីកម្មរបស់គាត់នៅក្នុងអំឡុងពេលដែលយើងកំណត់សវនាការនេះ។ សង្ឃឹមថាថ្ងៃនេះ និងថ្ងៃស្អែកយើងនឹងអាចចប់កិច្ចដំណើរការនេះ។

[១៤:០១:១៥]

អង្គជំនុំជម្រះ សូមអញ្ជើញលោកមេធាវីការពារក្ដីលោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី!

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធានសាជាថ្មី។ ខ្ញុំមានសំណួរប្រហែលជាបីបួនទៀតចប់ហើយ ហើយនិងសហការីខ្ញុំនឹងបន្ត។

**សួរដោយលោក សុន អរុណ៖**

**ស៖** អំមិញខ្ញុំបានសួរលោកសាក្សីថា លោកបានធ្លាប់ឮ ធ្លាប់ដឹងពីរឿងអាមេរិកាំងទម្លាក់គ្រាប់បែក បេ៥២ ឬក៏ស្អីៗផ្សេងៗទៀតទៅ អឺបាន-- ប៉ុន្តែលោកមានបានដឹងថាពេលដែលទម្លាក់គ្រាប់បែកហ្នឹងមានវិនាសកម្ម មានន័យថាសម្លាប់មនុស្ស មានធ្វើឲ្យខូចខាតផ្ទះសម្បែង ស្រែចម្ការ ស្រូវ ដំណាំដាំដុះអីច្រើនទេ? លោកមានបានដឹងរឿងហ្នឹងទេ?

[១៤:០២:២០]

**លោក ពាន ឃាន៖**

**ឆ៖** ពេលយន្តហោះទម្លាក់ គឺមានខូចខាត វាលស្រែ ហើយនិងព្រៃស្រោង ហើយនិងស្ពាន។ ហ្នឹងបើតាមដែលខ្ញុំឃើញ។ ឯរឿងមនុស្សខ្ញុំមិនដែលឃើញទេ។

**ស៖** សូមអរគុណ។ ពេលដែលលោកចូលមកដល់ភ្នំពេញ គឺថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ តើលោកមានឃើញ មានស្រូវ មានអង្ករ មានរបស់របរទ្រព្យសម្បត្តិអីនៅភ្នំពេញហ្នឹងច្រើនទេ? ហើយ

មានមនុស្សដែលមិនទាន់ភៀសខ្លួនពី-- កន្លងផុតថ្មីៗនេះលោកបានជម្រាបតុលាការថា មនុស្សដែលភៀសចេញពីភ្នំពេញប្រហែលជាពីរ ឬបីថ្ងៃក្រោយ។ ប៉ុន្តែពេលលោកមកដល់ឆ្នាំ៧៥ហ្នឹង ថ្ងៃ១៧ មេសា ហ្នឹង មនុស្សបានចេញខ្លះហើយឬនៅ ឬក៏ថានៅកកកុញពេញភ្នំពេញហ្នឹង?

**ឆ៖** តាមដែលខ្ញុំឃើញក្នុងពេលនោះ គឺនៅភ្នំពេញ គឺមានភាពស្ងាត់ជ្រងំ មិនសូវជាអ៊ូអរ អត់មានប្រជាជនកុះករទេ។ អ៊ីចឹងបានខ្ញុំសន្និដ្ឋានថាចាប់ពីថ្ងៃ១៧ មេសា ហ្នឹងចេញជាហូរហែ រហូតមិនដឹងជាផុតថ្ងៃណាទេ ខ្ញុំមិនបានដឹងដែរ។ ប៉ុន្តែរយៈពីរបីថ្ងៃហ្នឹង ប្រហែលជាចុងផុតហើយតាមមើលដែលខ្ញុំទៅឃើញនៅព្រែកក្ដាម ដងផ្លូវព្រែកក្ដាម ខ្ញុំធ្វើដំណើរតាមផ្លូវព្រែកក្ដាមហ្នឹងឃើញ។

[១៤:០៤:៥៧]

**ស៖** មុនភ្នំពេញលោកមិន-- ធ្វើជាកងទ័ព ហើយពេលវៃចូលភ្នំពេញ លោកក៏នៅតែជាកងទ័ពដដែល។ លោក ពេលដែលចូលដល់ភ្នំពេញ ឬមុនចូលភ្នំពេញ ពេលហ្នឹងលោកឃើញកងទ័ពវៀតណាមវៃមកជាមួយគ្នា និងកងទ័ពខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យចូលភ្នំពេញទេ? ឬក៏តែកងទ័ពកម្ពុជាប្រជាធិបតេយ្យសុទ្ធសាធ?

**ឆ៖** មុនរំដោះភ្នំពេញ ខ្ញុំបានធ្លាប់ឃើញនៅកំពង់ធំ កងទ័ពវៀតណាមបោះនៅ។ ហើយខ្ញុំចេះតែសួរគេថាគេបោះធ្វើអី? ថាមកជួយវៃខ្មែរ វៃសត្រូវរួម វៃអាមេរិក។ អាហ្នឹងដឹងបានតែប៉ុណ្ណឹង។ ហើយដល់ពេលមករំដោះភ្នំពេញ ខ្ញុំអត់បានឃើញទេ ព្រោះអីខ្ញុំមិនមែនជាអ្នកវៃទេ ខ្ញុំគ្រាន់តែនៅកន្លែងកុយ ឃ្លួន ហ្នឹង។ ចាំកន្លែង ចាំរបស់របរឲ្យគាត់ហ្នឹង ខ្ញុំមិនមែនជាទ័ពវៃតប់អីទេ។ អ៊ីចឹងខ្ញុំអត់បានឃើញទេ។

[១៤:០៦:៤៧]

**ស៖** អរគុណ។ អំមិញលោកថា បានឆ្លើយថានៅកំពង់ធំ លោកបានឃើញកងទ័ពវៀតណាមឃើញច្រើនទេពេលនុ៎ង?

**ឆ៖** ឃើញច្រើននៅតាមស្ទឹង ឬក៏អូរទេ នៅម្ដុំសន្ទុក ប្រហែលជាពីរទៅបីកន្លែង កងទ័ពវៀតណាមប្រមូលផ្ដុំបោះនៅ ប៉ុន្តែខ្ញុំមិនចាំថាកន្លែងណាខ្លះឈ្មោះអីទេ អត់បានចាំទេ។

**ស៖** បើតាមលោកដឹង កងទ័ពវៀតណាមមកនៅម្ដុំៗដែលលោកឃើញថានៅសន្ទុកអ៊ីចឹងរហូតដល់សណ្ដាន់ អ៊ីចឹង អ្ហឺ!កងទ័ពវៀតណាមរស់ដោយក្រុមរបស់គេ ឬក៏នៅឡូកឡំជាមួយនឹងកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** គេរស់នៅដាច់ដោយគ្នា ធ្វើការដាច់ដោយគ្នា អត់មានច្រឡូកច្រឡំទេ នៅកន្លែងខុសគ្នា។

**ស៖** អរគុណណាស់។ បើតាមលោកដឹង ឬក៏លោកឮគេថា ឬក៏លោកដឹងដោយខ្លួនឯងរបៀបណា ខ្ញុំមិនដឹងទេ ប៉ុន្តែតាមលោកដឹងកងទ័ពវៀតណាមមានច្រើនទេ? ប៉ុន្មានកងពល ប៉ុន្មានកងពលធំ ប៉ុន្មានកងពលតូច លោកអាចជម្រាបតុលាការបានទេ?

**ឆ៖** បើតាមខ្ញុំស្មានមើលទៅ ច្រើនដែរ ប្រហែលជាមួយកងពលធំដែលមកកម្ពុជាហ្នឹង កងទ័ពវៀតណាម។

[១៤:០៩:២០]

**ស៖** សំណួរមួយផ្សេងទៀត។ ពេលបន្ទាប់ពីលោក កុយ ឃួន ត្រូវបានចាប់ខ្លួន លោកដឹងថាតើមានរឿងហេតុអ្វីកើតឡើងចំពោះអ្នកដែលនៅក្នុងជួរ ឬក៏អ្នកធ្វើការជិតដិតជាមួយគាត់ ដូចជាលោកសាក្សី អ្ហឺ!ដូចលោក ពាន ខ្លួនឯងហ្នឹង តើមានការចាប់អារម្មណ៍ថា គេចាប់ កុយ ធួន របៀប-- ហេតុអីបានគេចាប់ កុយ ធួន ទេ-- កុយ ឃួន សូមទោស!

[១៤:១០:១០]

**ឆ៖** ដំបូងឡើយខ្ញុំក៏មិនដឹងពីមូលហេតុអីទេ។ ប៉ុនក្រោយមកខ្ញុំឮថា គេប្រកាសតាមវ៉ាដ្យូថា កុយ ឃួន ជាប់ខ្សែ អ៊ី.អា បក្សត្រូវចាប់ខ្លួន។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** អរគុណណាស់។ បន្ទាប់ពីគេចាប់ កុយ ឃួន មក បើតាមលោកឆ្លើយពីមុនៗមកថា លោកព្រួយបារម្ភសម្រាប់ខ្លួនលោកដែរ មិនអ៊ីចឹងណ៎ះ? ហើយដល់ពេលក្រោយមកគេផ្លាស់លោកទៅនៅវត្តស្វាយ-- វត្តស្វាយមាស ពេលហ្នឹងគេឲ្យលោកទទួលខុសត្រូវនៅវត្តស្វាយមាស លោកឆ្ងល់ថាហេតុអ្វីទេបានជា លោកខ្សែលោក កុយ ឃួន ហើយ កុយ ឃួន ត្រូវគេចាប់ ហើយលោកទៅជាផ្លាស់ទៅកន្លែងផ្សេងហើយលោក មានការងារកក់ក្តៅធ្វើ?

[១៤:១១:៤៥]

**ឆ៖** នៅស្វាយមាស មិនមែនជាការងារកក់ក្តៅទេ គឺកន្លែង ខ្ញុំជម្រាបខាងដើមហើយថា កន្លែងសហករណ៍តូចមួយ កន្លែងលត់ដំធ្វើការងារ មិនមែនជាកន្លែងខ្ញុំទៅមានមុខនាទីតំណែងដឹកនាំអីទេ។ សំខាន់កន្លែងហ្នឹង ការលត់ដំ។ ក្រោយពីគេចាប់ កុយ ឃួន ទៅខ្ញុំតែងតែមានព្រួយបារម្ភមែន ហើយដល់គេផ្លាស់ខ្ញុំពី ក-១ ទៅស្វាយមាស ខ្ញុំកាន់តែមានការចាប់អារម្មណ៍ ថាមិនដឹងខ្លួនខ្ញុំមានបញ្ហាអី។

**ស៖** លោកដឹងទេថា ផ្លាស់ទៅវត្តស្វាយមាសហ្នឹង គេឲ្យលោកធ្វើអីទេ ពេលនុ៎ង?

**ឆ៖** កន្លែងហ្នឹងដូចខ្ញុំបានជម្រាបខាងដើមហើយថា គេធ្វើជាសហករណ៍មួយតូច។ សហករណ៍ប្រមូលផ្តុំ ហើយកន្លែងនោះ មានតម្បាញ មីង១តម្បាញ ត្បាញក្រមា ហើយនិងដាំបន្លែបង្ការ ហើយបើគិតជាមនុស្សវិញប្រហែលជា ៣០នាក់ប៉ុណ្ណោះទេនៅកន្លែងនុ៎ង។ ហើយខ្ញុំមិនមានការងារអីធ្វើធំដុំទេ គឺចូលទៅដល់មុនដំបូង ឲ្យខ្ញុំទៅបង់សំណាញ់។ ហើយក្រោយមកទៀត បានមកដាំបន្លែ អស់ពីដាំបន្លែទៅ គេឲ្យខ្ញុំមកក្រុងភ្នំពេញមកធ្វើកម្មករសំណង់ក្រុងភ្នំពេញ។

[១៤:១៣:៥០]

**ស៖** សូមអរគុណលោកសាក្សី។

**លោក សុន អរុណ៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន ខ្ញុំនឹងផ្ទេរឲ្យលោក-- សហការីខ្ញុំនឹងបន្ត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**លោក អេនគ្រូ អ៊ីទ្ធូហ្ស៊ី៖**

សូមអរគុលោកប្រធាន។ សួស្តីអស់លោក លោកស្រី សួស្តីលោកចៅក្រម លោកសាក្សី។

**សួរដោយលោក អេនគ្រូ អ៊ីទ្ធូហ្ស៊ី៖**

សូមអរគុណសាជាថ្មីដែលលោកបានមកទីក្រុងភ្នំពេញជួយផ្តល់ចម្លើយ។ ខ្ញុំមានតែសំណួរមួយចំនួនតែប៉ុណ្ណោះនៅក្នុងរសៀលនេះ។ ខ្ញុំមានចំណុចអង្គហេតុចំនួនពីរ ដែលត្រូវសួរ។ ទីមួយពាក់ព័ន្ធទៅនឹងការដែលលោកឆ្លើយអំពី ក-១។ លោកបានឆ្លើយរួចមកហើយអំពីទីតាំង ក-១។ ខ្ញុំគ្រាន់តែកត់សម្គាល់ឃើញថា ក-១ នេះនៅជិតសាលមហោស្រពចតុមុខតាមមាត់ទន្លេ ហើយកន្លែងនោះធ្វើគូសប្លង់សាងសង់ដោយ វណ្ណ មូលីវណ្ណ។

[១៤:១៤:៥៧]

**ស៖** លោកសាក្សី តើលោកស្គាល់កន្លែងសាលមហាស្របចតុមុខដែរឬទេ? ឬក៏សាលសន្និសីទចតុមុខដែលគេក៏ហៅអ៊ីចេះ ដូច្នេះដែរ តើលោកស្គាល់ទេ?

**ឆ៖** មហាស្រប ខ្ញុំស្គាល់ ប៉ុន្តែវាមិនដឹងចំណាំថាទិសខាងណា មកខាងណី ជើង ឬក៏ត្បូង លិចកើតទេ ប៉ុន្តែខ្ញុំបានទៅឃើញម្តងដែរ ដើរលេងទៅ ទៅឃើញម្តង។

**ស៖** សូមអរគុណលោកសាក្សី។ លោកបានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះផងដែរ ថាក្រុម

សៀកចិន បានធ្វើការសម្តែងនៅសាលចតុមុខ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យផងដែរ។ តើលោកខ្លួនឯងដឹងថាមានការសម្តែង ពីអ្នកលេងសៀកចិននៅសាលមហាស្របចតុមុខនោះ កាលពីសម័យកម្ពុជាប្រជាធិបតេយ្យនោះដែរឬទេ?

**ឆ៖** ខ្ញុំឃើញម្តងដែរ ប៉ុន្តែខ្ញុំវាមិនបានចាំកន្លែង។ វាយូរហើយ ភ្លេច។

**ស៖** សូមអរគុណលោកសាក្សី។ លោកសាក្សីតើលោកដឹងដែរឬទេថា នៅក្នុងឆ្នាំដដែល គឺចុងឆ្នាំ១៩៧៩ រដ្ឋាភិបាលគាំទ្រដោយវៀតណាម គឺរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលនៅពេលនោះ ហ៊ុន សែន និង ហេង សំរិន មានតួនាទីនៅក្នុងរដ្ឋាភិបាល។ តើលោកដឹងដែរឬទេ ថាកន្លែងដដែលនោះគឺសាលមហោស្របចតុមុខ កន្លែងនោះហើយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា បានរៀបចំការកាត់ទោសបន ប៉ុល ពត ប្រល័យពូជសាសន៍ ដែលនៅទីនោះ គឺគេកាត់ទោសហ្នឹង។ តើលោកមានបានដឹងដែរឬទេ ក្នុងចុងឆ្នាំ៧៩?

[១៤:១៧:៤២]

**ឆ៖** ខ្ញុំអត់បានដឹងរឿងហ្នឹងទេ។

**ស៖** សូមអរគុណលោកសាក្សី។ ចំណុចចុងក្រោយលើចំណុចនេះ តើលោកដឹងដែរឬទេ អគារនេះ អគារដែលហៅថា អ.វ.ត.ក តើលោកដឹងទេ ថាសាលសវនាការនេះ គឺជាការថតចម្លងយកគំរូតាមសាលមហាស្របចតុមុខ ដែលនៅទីនោះ គេធ្លាប់យក មានការកាត់ទោសទៅលើបន ប៉ុល ពត អៀង សារី តើលោកដឹងដែរឬទេ កន្លែងនេះ ដែលគេយកគំរូតាមនុ៎ង?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយទេ សំណួរនេះ មិនពាក់ព័ន្ធនឹងរឿងក្តីនេះទេ។

**លោក អេនគ្រូ អ៊ីន្ធូហ្ស៊ី៖**

លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ជាក់ថា ខ្ញុំកត់ត្រាជាប្រតិចារឹកថា យើងលើកឡើងអំពីបញ្ហានេះ ទាក់ទងទៅនឹងការជំនុំជម្រះដែលគ្រាន់តែជាការៗធ្វើការជំនុំជម្រះ ជាការឆាកល្ខោនតែប៉ុណ្ណោះ ដូចដែលខ្ញុំបានបញ្ជាក់កាលពីលើកមុន។

[១៤:១៩:០២]

**សួរដោយលោក អេនគ្រូ អ៊ីន្ធូហ្ស៊ី៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរអំពីពេលវេលាដែលលោកធ្វើការនៅស្វាយមាស។ លោកបាន

ជម្រាបថា លោកធ្លាប់ធ្វើការងារនៅវត្តស្វាយមាស។

យើងខ្ញុំសូមដាក់ឯកសារមួយគឺE187.1។ ឯកសារនេះ មានបញ្ជាំងនៅលើអេក្រង់រួចមកហើយ កាលពីព្រឹកមិញ។ យើងខ្ញុំចង់សួរសំណួរមួយចំនួនតូចទៅកាន់សាក្សី ដោយយោងទៅលើឯកសារនេះ។

សូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

[១៤:១៩:៤០]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកសាក្សី-- អ៊ំ លោកប្រធាន។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** លោកសាក្សី តើលោកបានឃើញឯកសារនេះ នៅចំពោះមុខលោកដែរឬទេ?

**ប្រធានអង្គជំនុំ៖**

លោកមេធាវី លោកប្រាប់អត្តសញ្ញាណឯកសារ ហើយនិងទំព័រលេខ ERN ផង ដើម្បីកំណត់ជាក់ច្បាស់ក្នុងការឲ្យមន្ត្រីរដ្ឋបាលតុលាការហ្នឹងគាត់ទៅចង្អុលបង្ហាញដល់សាក្សី អំពីចំណុចដែលលោកមានបំណងក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ។

[១៤:២០:៣៧]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំនឹងធ្វើតាមលោកប្រធាន។ ឯកសារនេះមានលេខ E187.1 គឺជាកិច្ចសម្ភាសន៍ជាមួយនឹងសាក្សីរូបនេះ។ អង់គ្លេសលេខ ERN គឺ 00089701 ខ្មែរគឺ 00801769 បារាំងគឺ 00644575 គឺឯកសារតែមួយទេ ដែលបានដាក់បង្ហាញជូនសាក្សីកាលពីព្រឹកមិញ។

[១៤:២១:៤៤]

**សួរដោយលោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

**ស៖** លោកសាក្សី ខ្ញុំចង់សុំសួរលោកនូវសំណួរមួយចំនួន ចំណុចមួយនោះ គេសរសេរថា លីន បញ្ជួន-- ខ្ញុំត្រូវ លីន បញ្ជូនទៅទទួលបន្ទុកនៅវត្តស្វាយមាស ក្រោយពេលដែល ប៉ង់ ត្រូវបានគេចាប់។ តើចំណុចនេះត្រឹមត្រូវតាមអ្វីដែលលោកឆ្លើយពីលោកមុនដែរឬទេ ប្រយោគទីមួយ ដូចអ្វីដែលខ្ញុំអាន

អម្បាញ់មិញ?

**លោក ពាន ឃាន៖**

**ឆ៖** រឿងបញ្ជូនទៅគឺពិតជាបញ្ជូនទៅ ក៏ប៉ុន្តែដូចខ្ញុំបកស្រាយខាងដើមហើយ គឺថាមិនមែនទទួលបន្ទុក ទទួលខុសត្រូវមុខនាទីទេ ជាកន្លែងហ្នឹង ជាកន្លែងលត់ដំ ដូចខ្ញុំបានបញ្ជាក់ហូរហែមកហើយ មិនមែនខ្ញុំទៅដឹកនាំធ្វើជាមេដឹកនាំនៅកន្លែងនោះទេ។

**ស៖** ខ្ញុំយល់អ្វីដែលលោកបានឆ្លើយទៅលើចំណុចហ្នឹង។ ចំណុចទីពីរ ប្រយោគបន្ទាប់គឺថា នៅចុងឆ្នាំ១៩៧៨ ខ្ញុំទទួលបន្ទុកការងារវត្តស្វាយមាសដំបូងគេ ហើយបន្ទាប់មកធ្វើការជាកម្មករនៅផ-១ តើចំណុចនេះក៏ត្រឹមត្រូវឆ្លុះបញ្ចាំងនូវអ្វី ដែលលោកបានឆ្លើយកាលពីលើកមុនផងដែរ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ចម្លើយលើកមុន ត្រង់ឃ្លាថាទទួលបន្ទុក អាហ្នឹងដូចខ្ញុំបញ្ជាក់ខាងដើមហើយ មិនមែនទទួលបន្ទុកដឹកនាំអីទេ ទទួលបន្ទុកក្នុងការលត់ដំ ពាក្យគេថា លត់ដំ កសាងខ្លួន ក្នុងពេលនោះ គេឲ្យខ្ញុំចេញពី ក-១ ទៅលត់ដំ កន្លែងស្វាយមាសហ្នឹងហើយ។

[១៤:២៣:៤០]

**ស៖** សូមអរគុណលោកសាក្សី។ សំណួររបស់ខ្ញុំបន្ទាប់គឺយើងខ្ញុំចង់ធ្វើការបញ្ជាក់បំភ្លឺ ទៅលើអ្វីដែលខ្ញុំកត់ត្រា ដែលអ្វីដែលលោកបានឆ្លើយ។ លោកបានលើកឡើងថា លោកទទួលបន្ទុកការងារលត់ដំ តើអ៊ីចឹងត្រូវដែរឬទេលោក អ្វីដែលលោកឆ្លើយ?

**ឆ៖** គឺពិតជាអ៊ីចឹង ជាការពិតមែន។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំគ្រាន់តែបញ្ជាក់បំភ្លឺទេ។ តាមអ្វីដែលលោកឆ្លើយមានប្រជាជនត្រូវបានគេបញ្ជូនទៅទីនោះ ដើម្បីធ្វើការងារដោយបង្ខំ អ៊ីចឹងថាតើការលត់ដំនោះ ទម្រង់នៃការលត់ដំនៅកន្លែងនោះ តើមានទម្រង់យ៉ាងម៉េចដែរ?

[១៤:២៤:៣៧]

**ឆ៖** លត់ដំនៅកន្លែងនោះ នៅស្វាយមាសហ្នឹង ដូចខ្ញុំបានបញ្ជាក់ខាងដើមហើយថា គេចែកការងារគ្នាធ្វើ ហើយអ្នកខ្លះទៅខាងដាំបន្លែអ៊ីចឹងទៅ អ្នកខ្លះទៅខាងរកត្រីអ៊ីចឹងទៅ អ្នកខ្លះទៅខាងធ្វើកីតម្បាញ អ្នកខ្លះ មីងៗហ្នឹងខាងតម្បាញអ៊ីចឹងទៅ។ អ៊ីចឹងគេចែកការងារគ្នាធ្វើ ប៉ុន្តែគេកំណត់ម៉ោងកំណត់ពេល ដូចខ្ញុំបានបញ្ជាក់ខាងដើមនោះឯង។

**ស៖** សូមអរគុណលោកសាក្សី។ ព្រឹកមិញលោកបានប្រាប់មេធាវី-- លោកបានឆ្លើយប្រាប់

មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីថា គ្មានអ្នកណាត្រូវបានគេដកចេញពីស្វាយមាស យកទៅសម្លាប់ចោលនោះទេ។ តើត្រឹមត្រូវដែរឬទេ មានគេយកប្រជាជនពីស្វាយមាសនេះទៅកន្លែងផ្សេង យកទៅសម្លាប់ចោល? មិនមែនថាយកទៅសម្លាប់ចោលនៅស-២១ ទេ គឺគេយកសម្លាប់ចោលនៅកន្លែងផ្សេង។ តើលោកដឹងអំពីហេតុការណ៍ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ហើយក៏មិនបានឃើញដែរ។

**ស៖** សូមអរគុណលោកសាក្សី។ លោកសាក្សី តើលោកដឹង ឬក៏ស្គាល់បុគ្គលម្នាក់ឈ្មោះ យ៉ុម ដែលនៅក្នុងស-២១ ខ្សែវីដេអូគេបង្ហាញនោះថា គាត់ឈ្មោះ យ៉ុម តើលោកស្គាល់ទេ?

**ឆ៖** ខ្ញុំ-- ខ្ញុំអត់ស្គាល់ទេ។

**ស៖** បាទ គាត់គឺជាស្ត្រីមេម៉ាយ ហើយឈ្មោះរបស់គាត់គឺ យ៉ុម។

[១៤:២៦:៤២]

**ឆ៖** ខ្ញុំអត់ស្គាល់ទេ ឈ្មោះនេះ ហើយក៏មិនដែលជួបមុខដែរ។

**ស៖** សូមអរគុណលោកសាក្សី។ ឯកសារ D224.14 ខ្ញុំសូមបញ្ចាំងនៅលើអេក្រង់។ ខ្មែរលេខ ERN គឺ 00658158 បារាំងគឺ-- ចៅក្រម ឡាវែន៍ ខ្ញុំឃើញគាត់ក្រោកឈរ។ បារាំងគឺលេខ 00131360។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៨:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោក អេនគ្រូ អ៊ីន្ទូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។

[១៤:២៨:៤៨]

**សួរដោយលោក អេនគ្រូ អ៊ីន្ទូហ្វ៊ី៖**

**ស៖** លោកសាក្សី ឯកសារដែលនៅចំពោះមុខលោកនេះ គឺជាចម្លើយរបស់សាក្សីដែលលោកបានឆ្លើយ។ ខ្ញុំសូមអាចចំណុចដកស្រង់មួយចំនួនដែលខ្ញុំចាប់អារម្មណ៍ ដែលក្នុងនេះនិយាយថា៖ "នៅពេលដែលយើងស្នាក់នៅវត្តជ័យឧត្តម វត្តស្ពែង វត្តស្វាយមាស និងកន្ទួត ពុំមានការបង្រៀននយោបាយ

ទេ គ្រាន់តែធ្វើស្រែប៉ុណ្ណោះ។ ប្រជាជនបាត់ខ្លួនជារៀងរាល់យប់ ហើយយើងស្ថិតនៅក្រោមការឃ្លាំមើលរបស់ យ-១០។ បើសិនជានរណាម្នាក់បង្កបញ្ហា យ-១០ នឹងចាប់ខ្លួនហើយយកពួកគេចេញទៅ"។

លោកសាក្សី តើអ្វីដែលខ្ញុំអាននេះ វាធ្វើឲ្យលោកនឹកឃើញដែរឬទេ ថានៅពេលនោះគឺមានគេដកចេញមនុស្ស ចេញពីវត្តស្វាយមាស?

[១៤:២៩:៤៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអធ្យាស្រ័យដែលខ្ញុំកាត់នៅត្រង់ចំណុចនេះ។ យើងខ្ញុំក្រោកឈរដើម្បីជំទាស់។

ជាគោលការណ៍ យើងមិនត្រូវបានអនុញ្ញាតឲ្យយកចម្លើយរបស់សាក្សីផ្សេង មកធ្វើការដេញដោលសាក្សីដែលយើងកំពុងតែដេញដោលនេះទេ។ ដូច្នេះហើយអ្វីដែលយើង ខ្ញុំលើកឡើងនេះ គឺវាមានមូលដ្ឋានត្រឹមត្រូវ ហើយយើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះបង្គាប់ ធ្វើការណែនាំថា យើងគួរតែអនុវត្តតាមគោលការណ៍ណែនាំ ដែលយើងធ្លាប់អនុវត្តរួចមកហើយ។ សូមអរគុណ។

[១៤:៣០:៣១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី! មានអីឆ្លើយតបទៅនឹងការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាទេ?

**លោក អេនទ្រូ អ៊ីនុទ្ធហ្វ៊ឺ៖**

សូមអរគុណលោកប្រធាន។ យើងសូមបង្ហាញជំហរថា យើងមិនឃើញមានមូលដ្ឋានច្បាប់ណាមួយ ដែលអង្គជំនុំជម្រះយកមកផ្អែកជាមូលដ្ឋាននោះទេ។ ចម្លើយនេះ គឺជាចម្លើយដែលមិនបានរៀបចំដោយ អ.វ.ត.ក នោះទេ គឺការសម្ភាសរបស់អ្នកស្រាវជ្រាវ។ ដូច្នេះហើយយើងគិតថា វាមិនមែនជាការផ្ទុយអ្វីទៅនឹងការអនុវត្តរបស់យើងខ្ញុំទាំងអស់នោះទេ។

ខ្ញុំសូមឲ្យអង្គជំនុំជម្រះបញ្ជាក់ផងដែរថា ឯកសារនេះ គឺមិនមាននៅក្នុងបញ្ជីសាក្សីនោះទេ។ ឯកសារនេះ គឺយើងគ្រាន់តែយកមកប្រើដើម្បីធ្វើការផ្ទញ់ទៅលើសាក្សីតែប៉ុណ្ណោះ។

[១៤:៣១:២៩]

ដូច្នេះហើយយើងខ្ញុំសូមយោងទៅលើវិធីសាស្ត្រ ដែលយើងខ្ញុំបានប្រើប្រាស់កាលពីលើកពីមុន ពាក់ព័ន្ធទៅនឹងឯកសារដែលយើងត្រូវការយកមកធ្វើការផ្ទៀងទៅលើសាក្សី។ ដូច្នេះហើយ យើងខ្ញុំសូមលើកឡើងថា នេះជាឯកសារដែលសម្រាប់ផ្ទៀងសាក្សី ហើយយើងខ្ញុំគួរតែអនុញ្ញាតឲ្យយកមកប្រើប្រាស់សម្រាប់ដេញដោលសាក្សីរូបនេះ។ សូមអរគុណ។

[១៤:៣១:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៧:២៤]

**លោក អេនគ្រូ អ៊ីនួហ្វ៊ី៖**

លោកប្រធាន ខ្ញុំសូមកែប្រែពីរចំណុច។ ដើម្បីជាប្រតិចារឹក គឺខ្ញុំនិយាយអំពីបញ្ជីឈ្មោះសាក្សី។ លោកស្រីចៅក្រម ខាតវ៉ាយថ៍ ក៏បានជម្រាបថាឲ្យខ្ញុំយឺតបន្តិច គឺថាសហការីជាតិរបស់ខ្ញុំពាក្យថា "*អ៊ីមភីថ*" គឺការបកប្រែហាក់បីដូចជាមិនត្រឹមត្រូវ អវិជ្ជមានបន្តិច គ្រាន់ពាក្យ "*អ៊ីមភីចមិន*" កន្លែងនេះគឺដើម្បីការជជីកសួរដើម្បីស្វែងរកឲ្យឃើញនូវភាពគួរឲ្យទុកចិត្តបានរបស់សាក្សីរូបនេះ។

សូមអធ្យាស្រ័យលោកប្រធាន ដែលខ្ញុំបានកាត់ផ្តាច់លោកប្រធាន។

[១៤:៣៨:១៤]

**ប្រធានអង្គជំនុំ៖**

បាទអរគុណច្រើន។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ចំពោះបញ្ហាអម្បាញ់មិញនេះ អង្គជំនុំជម្រះនឹងសម្រេចលើបញ្ហានេះនៅពេលដែលត្រឡប់ចូលមកកាន់បន្ទប់សវនាការវិញ។ ហើយមន្ត្រីរដ្ឋបាលតុលាការផ្តល់ការសម្រាកសមរម្យដល់សាក្សីនិងមេធាវីរបស់គាត់ ហើយនិងសូមអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីនេះបន្ត។ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់មេធាវីការពារក្តី នួន ជា ដែលបានធ្វើឡើងមុននេះបន្តិចដូចខាងក្រោមនេះ៖

អង្គជំនុំជម្រះសូមជម្រាបលោកមេធាវីថា សេចក្តីសម្រេចលើសំណើសុំការសួរតទល់សាក្សីដើម្បីឲ្យមានភាពជឿជាក់លើសាក្សីនានា អង្គជំនុំជម្រះនឹងចេញនៅពេលសមស្របខាងមុខនេះ។ ចំពោះឯកសារ D224.14 ភាគីអាចដេញដោលនៅចំពោះមុខអង្គជំនុំជម្រះបាន។ ដោយហេតុថា ឯកសារនេះមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ហើយក៏ពុំមានការជំទាស់តវ៉ាពីភាគីផ្សេងៗទៀតដែរ។ មេធាវីការពារក្តី អាចប្រើឯកសារនេះ ឯកសារ D224.14 ជាមូលដ្ឋានក្នុងការសួរដេញដោលសាក្សីរូបនេះបាន ប៉ុន្តែសូមមេធាវីការពារក្តី និងភាគីសូមជ្រាបថា ដោយបុគ្គលដែលបានផ្តល់ចម្លើយនៅក្នុងឯកសារនេះ មិនត្រូវបានអង្គជំនុំជម្រះកោះហៅឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គសវនាការនោះទេ។ ហេតុដូច្នេះ ឯកសារនេះមានតម្លៃជាភស្តុតាងតិចតួច។

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីអាចបន្តការតាំងសំណួរដេញចំពោះសាក្សីរូបនេះ។

[១៥:០៥:00]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ អ៊ីចឹងលោកប្រធាន តើខ្ញុំគួរតែសួរសំណួរចុងក្រោយដែលខ្ញុំបានសួរទៅលើសាក្សីដែរឬទេ? ខ្ញុំបានអានអ្វីដែលមានសរសេរនៅក្នុងឯកសារ ហើយខ្ញុំបានសួរទៅលោកសាក្សីថា តើមាននឹកឃើញទេ ថាគេមាននាំមនុស្សយកចេញពីស្វាយមាស យកទៅសម្លាប់ចោលនៅកន្លែងផ្សេង? តើខ្ញុំគួរតែសួរសំណួរឡើងវិញទេលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ គួរតែសួរឡើងវិញហើយ ពីព្រោះសាក្សីមិនចាំទេ ចងចាំទេនូវសំណួរដែលលោកសួរ ហើយពេលវេលាឃ្លាតគ្នាយូរហើយ។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អេនគ្រូ អ៊ីនូហ្សុំ៖**

**ស៖** លោកសាក្សី ខ្ញុំនឹងអានចំណុចដែលខ្ញុំអានកាលពីម៉ោងមុននេះឡើងវិញ "ប៉ុន្តែនៅពេលដែលយើងស្នាក់នៅវត្តជ័យឧត្តម, វត្តស្ដែង, វត្តស្វាយមាស និងកន្ទួត ពុំមានការបង្រៀននយោបាយទេ គ្រាន់តែធ្វើស្រែប៉ុណ្ណោះ។ ប្រជាជនបាត់ខ្លួន ជារៀងរាល់យប់ ហើយយើងស្ថិតនៅក្រោមការឃ្លាំមើលរបស់ យ-១០។ ប្រសិនបើជានរណាម្នាក់បង្កបញ្ហា យ-១០ នឹងចាប់ខ្លួន ហើយយកពួកគេចេញ"។ ខ្ញុំជឿថាសំណួរដែលខ្ញុំសួរនោះ គឺថាតើអ្វីដែលខ្ញុំអាននេះ ធ្វើឲ្យលោកចាំដែរឬទេ ថាមានគេយកមនុស្សពីវត្តស្វាយមាសចេញទៅ?

[១៥:០៦:៤៧]

**លោក ពាន ឃាន៖**

**ឆ៖** តាមដែលខ្ញុំចាំ ថាមានយកចេញ ប៉ុន្តែគេយកទៅសម្លាប់ យកទៅណាក៏ខ្ញុំមិនដឹងដែរ។ ត្រង់យកចេញ មាន។ ប៉ុន្តែមិនដឹងយកទៅណា អត់ដឹង។

**ស៖** សូមអរគុណលោកសាក្សី។ តើលោក លោកខ្លួនឯងនេះមានចូលរួមក្នុងការត្រួតពិនិត្យមើលការលត់ដំ ដែរឬទេ? ឬក៏លោកធ្លាប់មានទទួលភារៈមើលការងារដែលគេយកមនុស្សចេញទៅដែរឬទេ?

**ឆ៖** អត់មានទេ ព្រោះអីសូម្បីតែខ្លួនខ្ញុំ ក៏ទទួលការលត់ដំនៅហ្នឹងដែរ។ ព្រោះគេថា ខ្ញុំជាប់និន្នាការនយោបាយជាមួយ កុយ ឃួន អ៊ីចឹង គេធ្វើតាមដានខ្ញុំដែរ។

**លោក អេនគ្រូ អ៊ីនូហ្សុំ៖**

សូមអរគុណលោកសាក្សី ខ្ញុំមិនមានសំណួរសួរពាក់ព័ន្ធទៅនឹងឯកសារនេះទៀតទេ។ ខ្ញុំមានឯកសារមួយទៀត គឺD125/207 អង់គ្លេសERN គឺ 002530139 ខ្មែរគឺ 002420055 (ស៊ីក) បារាំងគឺ00277308។ ខ្ញុំសូមលើកឡើងថា ឯកសារនេះមាននៅក្នុងបញ្ជីរបស់លោកសហព្រះរាជអាជ្ញា ឬក៏យ៉ាងណានោះទេ។ ក៏ប៉ុន្តែយើងខ្ញុំ សូមយកឯកសារនេះយកមកធ្វើការសួរតទល់ដើម្បីឲ្យមានភាពជឿជាក់។ ដូច្នេះហើយ ខ្ញុំសូមឲ្យលោកប្រធាន អនុញ្ញាតឲ្យយើងខ្ញុំបង្ហាញឯកសារនេះ ដើម្បីសួរទៅលើចំណុចតូចមួយនៅក្នុងនោះ។ គឺ ខ្ញុំគិតថាប្រហែលមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា ក៏ប៉ុន្តែមិនមាននៅក្នុងបញ្ជីឯកសាររបស់យើងខ្ញុំនោះទេ ចំពោះឯកសារមួយនេះ។

[១៥:០៩:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមសារភាពថា ខ្ញុំច្របូកច្របល់មែនទេ ព្រោះថាឯកសារពីមុននោះ ពុំមានអ្នកណា-- សាក្សីមិនស្គាល់ទេ ហើយខ្ញុំមិនគិតថា យើងមិន-- ខ្ញុំគិតថា យើងមិនអាចបង្ហាញឯកសារដែលគាត់មិនស្គាល់ទេ។ ហើយសូមឲ្យអង្គជំនុំជម្រះប្រាប់ថា តើអាចធ្វើអ៊ីចឹងបានដែរឬក៏អត់? ឬក៏ថាសិទ្ធិដែលធ្វើបែបនេះមានតែសម្រាប់ក្រុម នួន ជា ទេឬ? ឬក៏យើង ភាគីទាំងអស់មានសិទ្ធិធ្វើយ៉ាងដូច្នោះដែរ? ហើយខ្ញុំគិតថា លទ្ធភាពដែលផ្ដល់ជូនទៅខាងមេធាវីដើមបណ្ដឹងរដ្ឋ-- អ្ហ៎!ខាងក្រុម នួន ជា នេះ គឺថាគួរតែឲ្យសិទ្ធិដូចគ្នាដែរទៅភាគីផ្សេងទៀត។ ហើយបើសិនជាមិនមានដូចគ្នានោះ វាបង្កឲ្យមានបញ្ហា។

[១៥:១០:១៦]

**ប្រធានអង្គជំនុំ៖**

លោកស្រីមានបញ្ហាលើកឯកសារនេះទេ? ឯកសារអម្បាញ់មិញនេះ ឥឡូវគេកំពុងស្នើសុំដាក់នេះ កាលពីគេស្នើសុំដាក់ឯកសារអម្បាញ់មិញតទល់ លោកស្រីអត់មានបាននិយាយជំទាស់ តវ៉ាអីសោះនៅអង្គុយស្ងៀម។ គេបង្ហាញអំពីចរិតលក្ខណៈនៃឯកសារ ដែលវាខុសពីឯកសារលើកមុន ឯកសារពេលមុនគឺឯកសារយកកំណត់ហេតុសាក្សី ដែលគ្រោងនឹងកោះហៅមកឲ្យផ្ដល់សក្ខីកម្ម ចំណែកឯកសារនេះ គឺជាឯកសារដោយឡែកដែលធ្វើឡើងដោយមនុស្សផ្សេង ហើយសាក្សី-- ហើយគោលដៅនេះមិនមែនជាសាក្សីទេ។ នៅក្នុងបញ្ជីគ្រោងហៅធ្វើជាសាក្សីមិនមានទេ។ អង្គជំនុំជម្រះបានសម្រេចរួចហើយរឿងបញ្ហានេះ។

[១៥:១០:៥៨]

ឥឡូវបញ្ហាថ្មីនេះ! បញ្ហាគេដាក់ឯកសារនេះ តើវាមានបញ្ហាអី?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមជំទាស់ ពីព្រោះថាប្រសិនបើជាឯកសារនេះ សាក្សីមិនស្គាល់ទេ។ ខ្ញុំចង់ដឹងថា តើអង្គជំនុំជម្រះប្រកាន់គោលជំហរមួយ គឺថាបង្ហាញឯកសារហ្នឹងទៅសាក្សីដែលថា សាក្សីមិនស្គាល់ឯកសារនុ៎ងទេ។ ឧទាហរណ៍ ឯកសារមុនហ្នឹង ដូចគ្នាផងដែរ។ ហើយខ្ញុំគ្រាន់តែចង់សួរថា--

**ប្រធានអង្គជំនុំ៖**

ឥឡូវនិយាយពីរឿងឯកសារនេះ លោកស្រីយកឯកសារនេះ។ ចំពោះឯកសារដូចគ្នា ប្រភេទដូចគ្នា ដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ ប្រសិនបើមានករណីដូចគ្នានេះ លោកស្រីអាចលើកយកមកធ្វើបាន ឲ្យតែប្រភេទប្រហាក់ប្រហែលគ្នាជាមួយនឹងឯកសារដែលយើងបានសម្រេចរួចហើយ។ ដោយសារឯកសារនេះ វាខុសពីឯកសារដែលយើងបានសម្រេចលើកមុន ដែលមិនអនុញ្ញាតឲ្យលោកមេធាវីដកស្រង់នូវចម្លើយសាក្សីដទៃទៀតមកសួរសាក្សីរូបនេះទេ។ បើចង់សួរនៅពេលណាដែលកោះហៅសាក្សីនោះ មកចំពោះមុខអង្គជំនុំជម្រះ នេះគឺជាសាក្សីដែលអង្គជំនុំជម្រះកំណត់នៅក្នុងបញ្ជីដែលខ្លួនគ្រោងកោះហៅមកធ្វើសាក្សី។ ចំណែកឯបញ្ហាអម្បាញ់មិញនេះ វាខុសប្លែកពីហ្នឹង ហើយភាគីខាងមេធាវីការពារក្តីគេបានឆ្លើយបង្ហាញនូវហេតុផលរបស់គេសមស្រប អំពីភាពខុសគ្នារវាងឯកសារពេលមុន ហើយនិងឯកសារដែលគេដាក់។ ហើយអង្គជំនុំជម្រះបានសម្រេចរួចហើយ។

[១៥:១២:៣៥]

ប្រសិនបើលោកស្រីមានបញ្ហានេះ ដូចគ្នាគឺលោកស្រីអាចលើកយកមកបញ្ហាហ្នឹងបាន ដរាបណាតុលាការមិនបដិសេធ លោកស្រីអាចយកសេចក្តីសម្រេចដែលយើងបានសម្រេចរួចហើយនេះ យកធ្វើជាមូលដ្ឋានទៅក្នុងការស្នើ។ ប៉ុន្តែឥឡូវវាឈានដល់ឯកសារនេះ ដែលគេដាក់ចំពោះមុខអង្គជំនុំជម្រះថ្មីនេះ តើមានបញ្ហាអីទេ? មិនមែនអង្គុយស្ងៀម ហើយស្រាប់មកដល់សម្រេចរួម មកតវ៉ាក្រោយអ៊ីចឹងទេ។

ឥឡូវនេះ ជជែកលើឯកសារដែលគេដាក់នេះ តើវាមានបញ្ហាអី? ស្គាល់ទេ? ហើយជំទាស់យ៉ាងដូចម្តេចទៅ? ដើម្បីអង្គជំនុំជម្រះកត់ត្រានូវសេចក្តីជំទាស់របស់លោកស្រី និងមូលហេតុនៃការជំទាស់ ដើម្បីយើងយកទៅពិចារណា និងសម្រេចជាថ្មីម្តងទៀតលើបញ្ហាថ្មីនេះ។

[១៥:១៣:៣២]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំមានបញ្ហាពីរ គឺថាបញ្ហាទីមួយ គឺថាខ្ញុំគិតថា ភាគីការពារក្តីរបស់ នួន ជា មិនបានបង្ហាញថា ឯកសារនេះនៅក្នុងបញ្ជីឯកសារឬអត់? ហើយបញ្ហាទីពីរ គឺថា ថាតើមេធាវី នួន ជា នឹងចោទសំណួរទៅសាក្សីថា តើសាក្សីហ្នឹងស្គាល់ឯកសារនុ៎ងដែរឬក៏អត់? ពីព្រោះថា រហូតដល់ពេលនេះ ត្រង់ពីឯកសារមុនហ្នឹងក៏ដោយ អង្គជំនុំជម្រះមានគោលជំហរដែលថា យើងមិនអាចបង្ហាញ

ឯកសារណាដែលខ្លួនមិនស្គាល់នោះទេ។ នេះជាអ្វីដែលខ្ញុំចង់ដឹងថា តើសិទ្ធិយើងនេះ សិទ្ធិមានកម្រិតណា? ហើយទាក់ទងទៅនឹងឯកសារដែលបង្ហាញនៅលើអេក្រង់នេះ?

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៤:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា យើងត្រូវបែងចែកបញ្ហាមួយចំនួន គឺថាបញ្ហាមួយ គឺថាតើឯកសារណាដែលអាចយកមកពិភាក្សាបាន ហើយឧទាហរណ៍គឺថា ដើម្បីសួរផ្ទាល់សាក្សីនោះ។ ទាក់ទងនឹងចំណុចជាក់លាក់នេះ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចក្នុងពេលយ៉ាងឆាប់ខាងមុខនេះ។ ក៏ប៉ុន្តែជាការច្បាស់ណាស់ ដែលថាអង្គជំនុំជម្រះរហូតមកដល់ពេលនេះ យល់ឃើញថា មិនអាចប្រើឯកសារណាមួយ ដែលជាចម្លើយរបស់សាក្សីដែលយើងនឹងស្តាប់នៅពេលក្រោយនោះទេ។ នៅទីនេះ អ្វីដែលស្នើឡើងដោយមេធាវី នួន ជា គឺថាម្យ៉ាង គឺថាដាក់ឯកសារចម្លើយរបស់បុគ្គលម្នាក់មកពិភាក្សា ដែលចម្លើយនេះ គឺថាបានប្រមូលដោយអ្នកស្រាវជ្រាវ ប៉ុន្តែមិនមែនសហចៅក្រមស៊ើបអង្កេតទេ ហើយមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា ហើយពុំមានការជំទាស់អ្វីនោះទេ។ ដូច្នេះ ឯកសារនេះអាចដាក់មកពិភាក្សាបានដោយគ្មានបញ្ហា ហើយនិងអាចប្រើប្រាស់ជាមូលដ្ឋានទាក់ទងទៅនឹងសំណួររបស់ក្រុមមេធាវី នួន ជា។

[១៥:១៦:១៤]

ក៏ប៉ុន្តែជាការពិតណាស់ ដែលអង្គជំនុំជម្រះច្បាស់ណាស់ ថាអង្គជំនុំជម្រះនឹងយល់ឃើញថាបញ្ហា-- ឯកសារនេះ មិនសូវតម្លៃនោះទេ។ ពីព្រោះថាសាក្សីមិនស្គាល់ឯកសារនេះ ឬមិនស្គាល់អ្នកដែលផ្តល់សក្ខីកម្ម ហើយមិនដឹងពីខ្លឹមសារ។ អង្គជំនុំជម្រះនឹងលើកឡើងថាបញ្ហានេះ មិនមានភាពពាក់ព័ន្ធប៉ុន្មាន ហើយតើអ្វីដែលខ្ញុំលើកឡើងនេះ បំភ្លឺអំពីគោលជំហររបស់អង្គជំនុំជម្រះដែរឬទេអ្នកស្រីមេធាវី? តើអ្នកស្រីយល់ច្បាស់ដែរឬទេ?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសោកស្តាយដែលថា ខ្ញុំនិយាយសង្កត់ធ្ងន់ដដែលៗនេះ។ ខ្ញុំចង់ដឹងថាតើយើងអាចបង្ហាញ

សក្ខីកម្មរបស់បុគ្គលផ្សេងទៀតទៅសាក្សីដែរឬទេ? សំណួរ-- បញ្ហាមួយទៀត គឺថាបញ្ហាឯកសារដែលថាសាក្សីស្គាល់ ឬក៏មិនស្គាល់? ព្រោះថាជួនកាល សក្ខីកម្ម-- ឯកសារទាំងពីរនេះ វាជាន់គ្នា វាអាចថាជាសក្ខីកម្មរបស់មនុស្សម្នាក់ ឬក៏ឯកសារដែលសាក្សីមិនស្គាល់។ បើសិនជាសាក្សីពិនិត្យមើលឯកសារនេះ ហើយសំណួរទីមួយ ដែលយើងត្រូវចោទសួរទៅគាត់នោះ ហើយនេះជាមូលដ្ឋាននៃការជំទាស់របស់ខ្ញុំ។ យើងត្រូវសួរគាត់ ថាតើគាត់ស្គាល់ឯកសារនុ៎ង ឬក៏អត់? ហើយអង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចនៅពេលដែលខ្លួនចង់។ ហើយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះ ត្រូវតែអនុវត្តចំពោះគ្រប់ភាគីទាំងអស់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តីលោក នួន ជា!

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណចៅក្រម ឡាវែន៍ ដែលបានបញ្ជាក់បំភ្លឺ។ ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ដើម្បីប្រតិចារឹក។ ជំហររបស់យើងខ្ញុំនោះ គឺយើងមិនមាន-- មិនមើលឃើញមានភាពខុសគ្នា រវាងចម្លើយដែលសាក្សីបានផ្តល់ជូនទៅដល់អ្នកផ្សេង អ្នកមុន និងទៅដល់អ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះនោះទេ។ តាមគោលការណ៍របស់យើង គឺថាយើងនៅតែរក្សាជំហរថា សម្ភារៈឯកសារទាំងឡាយ ដែលអាចពាក់ព័ន្ធទៅនឹងសក្ខីកម្ម គួរតែអនុញ្ញាតឲ្យយកមកប្រើប្រាស់ ដើម្បីសួរតទល់ ដើម្បីឲ្យមានភាពជឿជាក់ទៅលើសាក្សី។

[១៥:១៨:៤៣]

ខ្ញុំនឹងលើកបញ្ហានេះ នាពេលក្រោយទៀត ក៏ប៉ុន្តែពេលនេះ ខ្ញុំគិតថា មិនទាន់សមស្របក្នុងការលើកនោះទេ។ ចំពោះការសួរដេញដោលជាលក្ខណៈអសាធារណៈដែលបានធ្វើឡើងនៅថ្ងៃទី០៥ ឧសភា គឺនៅថ្ងៃនោះ គឺយើងបានបើកសវនាការជាអសាធារណៈលើវិធាន២៨ នៃវិធានផ្ទៃក្នុង ហើយសំណើទាំងឡាយនោះបានបញ្ជូនទៅអង្គជំនុំជម្រះរួចមកហើយ។ ការពិភាក្សាទាំងឡាយនៅក្នុងសវនាការអសាធារណៈនោះ គឺវាពាក់ព័ន្ធទៅនឹងចំណុចទាំងអស់នេះ ដែលយើងបានពិភាក្សា។ លោកចៅក្រម ឡាវែន៍ ហាក់ដូចជាធ្វើដៃឲ្យឈប់សិន។

[១៥:១៩:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៩:៤៤]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

(គ្មានការបកប្រែ)

**ប្រធានអង្គជំនុំ៖**

បញ្ហានេះ អង្គជំនុំជម្រះបានទទួលសំណើសុំរបស់លោកហើយ ហើយអង្គជំនុំជម្រះកំពុងតែដំណើរការពិនិត្យពិចារណា និងចេញសេចក្ដីសម្រេច។ ដូច្នេះ បញ្ហាដដែលៗនេះ គឺគប្បីមេធាវីចៀសវាងក្នុងការលើករឿងដដែលៗ វាអាចភ័ន្តច្រឡំរឿងដដែលៗ វាមិនដឹងថាតើដំណើរមួយណាដែលត្រូវអង្គជំនុំជម្រះដោះស្រាយទេ។

[១៥:២០:១៧]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ដូច្នេះហើយជាប្រតិចារឹក គឺយើងខ្ញុំយល់ទៅលើចំណុចហ្នឹងសម្រាប់មេធាវី សហនាំមុខ-- មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនេះ គឺថាឯកសារទាំងពីរនេះបាន-- យើងខ្ញុំបានដាក់ជូននៅក្នុងកម្មវិធី ប្រព័ន្ធអ៊ីនធឺហ្វេសរួចមកហើយ ហើយក៏ខ្ញុំបានអានលេខឯកសារនៅក្នុងសវនាការមុនៗផងដែរ។ ដូច្នេះហើយវាមិនមានអ្វី ដែលជាការភ្ញាក់ផ្អើលសម្រាប់យើងទាំងអស់គ្នានោះទេ។

[១៥:២០:៤៥]

ខ្ញុំទទួលយកសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរ-- អ៉ំ! សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។ នៅពេលនេះគឺយើងខ្ញុំសូមយោងទៅលើឯកសារ D125/207 ខ្ញុំបានអាន ERN រួចមកហើយ ឯកសារនេះគឺប្រហែលជាមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា។ ដូច្នេះហើយជំហររបស់ខ្ញុំដែរ ដែលលើកឡើងពាក់ព័ន្ធទៅនឹងឯកសារនេះ គឺដូចទៅនឹងជំហរ និងហេតុផលមុនៗ ដែលថា យើងខ្ញុំប្រើឯកសារដើម្បីសួរតទល់ឲ្យមានភាពជឿជាក់ទៅលើសាក្សី។ សូមអរគុណ។

[១៥:២១:២២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា គប្បីគួរតែត្រូវបានជំទាស់មុនជាមួយគ្នា ទន្ទឹមគ្នាជាមួយនឹងការប្រើពេលជំទាស់របស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ប្រសិនបើតំណាងសហ

ព្រះរាជអាជ្ញាធ្វើដូច្នេះ វានឹងអាចចំណាយពេលច្រើន ដោយសារមេធាវីការពារក្តី នៅពេលដែលលោកជំទាស់គឺនឹងមានសេចក្តីពីមេធាវីការពារក្តីទៀតហើយ។ បញ្ហានេះ យើងបានរំឭកច្រើនលើកច្រើនសាហើយ ហាក់ដូចជានៅតែដដែលៗសោះ។

[១៥:២១:០២]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមែនក្រោកឈរឡើងជាក់លាក់ ដើម្បីជំទាស់ទៅនឹងការលើកឡើងរបស់មេធាវីការពារក្តីនោះទេ ក៏ប៉ុន្តែនៅពេលនេះ គឺយើងបានដំណើរការដោយផ្អែកទៅលើព័ត៌មានជាច្រើនមួយចំនួន ដែលវាមិនត្រឹមត្រូវនោះទេ។ ពាក់ព័ន្ធទៅនឹងឯកសារមួយនេះ ដែលមេធាវីការពារក្តីបានយោងអម្បាញ់មិញ គឺយើងឃើញថា ឯកសារនេះមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញានៅក្នុងឧបសម្ព័ន្ធលេខ២០។ វាជាដីកាចាត់ឲ្យសួរ-- កំណត់ហេតុដែលធ្វើឡើងតាមដីកាចាត់ឲ្យសួរជំនួសដោយចៅក្រម សហចៅក្រមស៊ើបអង្កេត ដោយយើងមើលនិងស្តាប់ឮសេចក្តីសម្រេចរបស់អង្គជំនុំជម្រះអម្បាញ់មិញនេះ គឺឯកសារដែលវាជាឯកសារ តាមការចាត់ឲ្យសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេតនេះ គឺយើងស្ថិតនៅក្នុងការពិភាក្សាមុនៗ។ ឯកសារ D125/207 នេះ គឺជំទាស់ដោយមេធាវី អៀង សារី ដែលវាយោងទៅលើឯកសារ E131/1/10.9 ដែលមាននៅក្នុងឧបសម្ព័ន្ធ២០។ ឧបសម្ព័ន្ធ២០ នេះមិនទាន់បានធ្វើការសម្រេចនៅឡើយនោះទេ។ ដូច្នេះ ខ្ញុំក្រោកឡើងដើម្បីធ្វើការបញ្ជាក់ទៅលើចំណុចនេះ។ យើងមានសេចក្តីសម្រេចដែលបានទទួលយកឯកសារមួយចំនួន និងសេចក្តីសម្រេចមួយចំនួន ដែលមិនទាន់ធ្វើឡើងពាក់ព័ន្ធនឹងឯកសារផ្សេងទៀត។

[១៥:២៣:៣៥]

ដូច្នេះ ឯកសារ D125/207 នេះគឺមិនទាន់បានសម្រេចដោយអង្គជំនុំជម្រះនៅឡើយនោះទេ។ ដើម្បីជាប្រតិចារឹក ឯកសារ D224.14 នេះគឺ ត្រូវបានជំទាស់ផងដែរ យើងឃើញមានឯកសារ E131/1/10.11។ ដូច្នេះ ដើម្បីជាប្រតិចារឹកឯកសារមុន មួយមុននោះគឺត្រូវបានសម្រេចរួចមកហើយ ក៏ប៉ុន្តែឯកសារមួយនេះ មិនទាន់បានសម្រេចនៅឡើយនោះទេ។ របាយការណ៍កំណត់ហេតុ ដែលធ្វើឡើងតាមដីកាជំទាស់នោះ គឺមានការជំទាស់ដោយភាគី ហើយសេចក្តីសម្រេចមិនទាន់បានធ្វើឡើងនៅឡើយនោះទេ។

[១៥:២៤:២៣]

**លោក អេនគ្រូ អ៊ីនូហ្សុី៖**

លោកប្រធាន ខ្ញុំសូមធ្វើការឆ្លើយតបទៅលើចំណុចនេះ។ ចំណុចនេះហើយ ដែលវាសំខាន់ណាស់ ដែលយើងត្រូវការដេញដោលពិភាក្សាគ្នា ជាលក្ខណៈសាធារណៈ ជាពិសេសនៅថ្ងៃ២ ឧសភា។ នៅថ្ងៃ២ ឧសភា នោះគឺយើងធ្វើការបែងចែករួចមកហើយ ការជំទាស់ដែលសហព្រះរាជអាជ្ញាលើកឡើងនោះ គឺវាទាក់ទងទៅនឹងសារធាតុ ជាពិសេសទៅលើឯកសារ ដែលបង្ហាញជាភស្តុតាង។ ខ្ញុំបានធ្វើការបែងចែកនៅក្នុងវគ្គសវនាការពេលមុននោះរួចមកហើយ ពាក់ព័ន្ធទៅនឹងសម្ភារៈឯកសារដែលយើងបានបង្ហាញ ដើម្បីបង្ហាញជាឯកសារសារធាតុ ហើយឯកសារសម្ភារៈមួយចំនួនទៀត ដែលប្រើប្រាស់សម្រាប់ធ្វើការសួរតទល់ ដើម្បីមានភាពជាក់តែប៉ុណ្ណោះ។

[១៥:២៥:០០]

ដូច្នេះហើយវាមានភាពខុសគ្នាចំណុចហ្នឹងដែលខ្ញុំបានធ្វើការបែងចែក។ ឯកសារមួយចំនួនដែលមិនបានធ្វើការជំទាស់ដោយផ្អែកទៅលើខ្លឹមសារសំខាន់របស់វានោះ វាគ្មានចំណុចណាមួយដែលយើងមិនអាចយកមកប្រើប្រាស់សម្រាប់សួរឲ្យមានភាពជឿជាក់ទៅលើសាក្សីនោះទេ។ យើងក៏មិនដឹងថា តើបុគ្គលណានឹងត្រូវកោះហៅមកផ្តល់សក្ខីកម្ម។ ដូច្នេះហើយវាសមហេតុផល ដែលយើងអាចធ្វើការទស្សន៍ទាយសាក-- ថាតើបុគ្គលណានឹងត្រូវកោះហៅមកធ្វើសក្ខីកម្ម។ ដូច្នេះហើយយើងត្រូវតែធ្វើការបែងចែកចំពោះឯកសារដែលយើងសួរទៅលើខ្លឹមសារសំខាន់ និងឯកសារដែលយើងយកមកប្រើប្រាស់សម្រាប់សួរតទល់ដើម្បីឲ្យមានភាពជឿជាក់។

សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៨:១០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោកសហព្រះរាជអាជ្ញាលោកបានបញ្ជាក់ថា ឯកសារនេះគឺកំពុងពិចារណា គឺឯកសារ D125/207។ ឯកសារនេះត្រូវបានជំទាស់ដោយភាគី។ តើលោកអាចរំឭកឲ្យអង្គជំនុំជម្រះបានដឹងដែរឬទេ ភាគីណាដែលបានជំទាស់ជាលាយលក្ខណ៍អក្សរ? ខាងមេធាវី អៀង សារី ឬ

ក៏អ្នកណា?

**លោក អាប់ឌុលឡាក់ ថាវីក៖**

ជាការពិតគឺក្រុមមេធាវី អៀង សារី។ ឯកសារដែលបានដាក់នោះគឺ E131/1/10.19 ។ វាគឺជាតារាងត្រង់ចំណុច៤១ នៅក្នុងតារាងនោះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណ។ ដូច្នេះមេធាវី អៀង សារី តើយើងអាចសន្និដ្ឋានថា លោកនៅតែរក្សាការជំទាស់នេះ ឬក៏យ៉ាងម៉េច? ដោយសារតែលោកមិនបានរំឭកឲ្យអង្គជំនុំជម្រះដឹងអំពីការជំទាស់របស់លោកសាជាថ្មីពាក់ព័ន្ធទៅនឹងឯកសារនេះ។

[១៥:២៩:២៣]

តើលោកចាំដែរឬទេ ថាលោកបានជំទាស់ទៅលើឯកសារហ្នឹង?

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំចាំទៅលើការជំទាស់ ដែលថាយើងជំទាស់ទៅលើឯកសារប្រភេទនេះ គឺឯកសាររបាយការណ៍តាមការចាត់ឲ្យសួរជំនួស។ នៅពេលដែលយើងដាក់ការជំទាស់របស់យើងនោះគឺ យើងឃើញថាមានសេចក្ដីសម្រេច មានជំហរមួយដែលថា យើងខ្ញុំមិនចង់ក្រោកឡើងរៀងរាល់ពេល ដើម្បីអង្គជំនុំជម្រះថា យើងជំទាស់ទៅលើឯកសារទាំងអស់នេះ។ យើងខ្ញុំសូមលើកឡើងថា មានឯកសារ និងពិបាកឲ្យយើងពិនិត្យមើលឯកសារទាំងអស់នោះណាស់។

[១៥:៣០:០៣]

ក៏ប៉ុន្តែជំហររបស់យើងច្បាស់ណាស់ ភាគីដែលប្រើ-- ចង់ប្រើប្រាស់ឯកសារទាំងអស់នេះ គឺវាអាស្រ័យទៅលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះធ្វើការសម្រេចទៅលើប្រភេទឯកសារទាំងអស់នេះ។ ហើយអង្គជំនុំជម្រះជាអ្នកផ្ដល់ទម្ងន់ទៅលើឯកសារទាំងអស់នេះ។ យើងដឹងហើយថា យើងសល់តែពេល៣០នាទីតែប៉ុណ្ណោះ ដើម្បីប្រសិទ្ធភាពពេលវេលារបស់យើង យើងគួរតែអនុញ្ញាតឲ្យធ្វើយ៉ាងណាឲ្យបាន-- សួរគាត់ឲ្យបានលឿន ដើម្បីឲ្យសាក្សីនេះត្រឡប់ទៅផ្ទះរបស់គាត់ឡើងវិញ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ខ្ញុំសូមសង្ខេបនូវអ្វីដែលលោកបានលើកឡើង។ លោកមិនមានការជំទាស់ទៅលើការប្រើប្រាស់ឯកសារនេះនោះទេ ដោយផ្អែកទៅលើយោបល់របស់អង្គជំនុំជម្រះ ដែលថាអង្គជំនុំជម្រះគឺនឹងផ្ដល់ទម្ងន់

មួយមានលក្ខណៈកម្រិត លើកលែងតែមានការកោះហៅសាក្សីដែលមាននៅក្នុងឯកសារនេះ។

**លោក ម៉ៃខល កាណាវាស៖**

*(គ្មានការបកប្រែ)*

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ហើយលោកមានការចាប់អារម្មណ៍ និងព្រួយបារម្ភអំពីការតវ៉ាហេតុផលគ្នា ដែលវាអាចចំណាយពេលច្រើនទៅលើការងាររបស់យើង។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកស្រីចៅក្រម គឺចំណុចនេះហើយ។

[១៥:៣១:២១]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះអង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវីការពារក្តី នួន ជា អាចយកឯកសារនេះដេញដោលសាក្សីនេះបាន។ ដោយសារមូលហេតុការជំទាស់មិនមានមូលដ្ឋានអ្វីខ្លាំងក្លាទេ លើការជំទាស់នឹងការតទល់ឯកសារ យកឯកសារនេះមកសួរតទល់ចំពោះសាក្សីនៅពេលនេះ។ សូមអញ្ជើញ!

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោក លោកស្រីចៅក្រម។ ខ្ញុំសូមទោសដែលខ្ញុំមិនបានបញ្ជាក់ថាតើឯកសារនេះត្រូវបានជំទាស់ ឬក៏យ៉ាងណានោះ។ ហើយដោយសារវាប៉ុន្មានខែមកហើយ ប៉ុន្តែខ្ញុំប្រហែលជា មិនមែនមេធាវីមួយដែលមានការចងចាំល្អ ប៉ុន្តែខ្ញុំគ្រាន់តែសូមអាននូវផ្នែកតូចមួយដែលបានមកពីចម្លើយសាក្សី ដែលបានបង្ហាញជូននៅលើអេក្រង់នេះរួចជាស្រេចហើយ។

[១៥:៣២:២៣]

**សួរដោយលោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

**ស៖** “នៅពេលខ្ញុំរស់នៅវត្តស្វាយមាស មានឡានឃ្លុបដែលមានស្លាកលេខមន្ទីរ ៨៧០ បានមកចាប់មនុស្សយូរៗម្តង គេចាប់ម្នាក់ ឬពីរនាក់។ ខ្ញុំបានដឹងគឺក្រោយពីឆ្នាំ១៩៧៩ គឺកម្មករដែលត្រូវបានគេដឹកចេញពីក្រុងកំពង់សោម ត្រូវបានគេៗសម្លាប់នៅក្នុងស្រុកស្មោង”។ ខ្ញុំសូមបញ្ជាក់ថាតើលោកសាក្សីខ្ញុំអានប៉ុណ្ណេះលោកអាចនៅចាំបានថាតើមានគេយកមនុស្សចេញពីវត្តស្វាយមាសអីយ៉ាងដូច្នេះមែនទេ?

**លោក ពាន ឃាន៖**

**ឆ៖** តាមខ្ញុំចាំ រឿងយកចេញ មិនដឹងជាយកចេញរបៀបណាទេ។ ប៉ុន្តែគ្រាន់ថា ចេញផ្លាស់ប្តូរមនុស្ស ចេញចូលៗហ្នឹង ប៉ុន្តែត្រង់គេយកទៅណាពិតប្រាកដ ខ្ញុំអត់ដឹងទេ។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកសាក្សី។

សូមអរគុណលោកប្រធានអង្គជំនុំជម្រះ ខ្ញុំអស់សំណួរត្រឹមប៉ុណ្ណេះ។ សូមអរគុណ។

[១៥:៣៣:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាបន្តសូម-- អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមសាជាថ្មី។ សូមគោរពអង្គសវនាការ សួស្តីលោកអ្នកទាំងឡាយនៅក្នុងបន្ទប់សវនាការនេះ ឬក៏នៅក្រៅបន្ទប់សវនាការក្តី។

សួស្តីលោក ពាន ឃាន។ ខ្ញុំ អាង ឧត្តម ជាសហមេធាវីការពារក្តីលោក អៀង សារី។ ពេលនេះខ្ញុំស្នើសុំពិភាក្សាជាមួយលោកតែលើពីរចំណុច។ ហើយសំណួរមិនមានច្រើនទេ ប្រហែលជាខ្ញុំចំណាយពេលប្រហែលជាដប់នាទីអីប៉ុណ្ណឹងទេ។ ប្រហែលជាលើសខ្វះតិចតួច។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** លោក ពាន ឃាន ក្នុងសវនាការកន្លងមកនេះ នៅក្នុងបន្ទប់សវនាការនេះ លោកបានជម្រាបអង្គសវនាការថា លោកអត់ដែលបានចូលរួមកិច្ចប្រជុំណាមួយជាមួយនឹងមេដឹកនាំជាន់ខ្ពស់ទេ។ តើលោកនៅរក្សាចម្លើយនេះដដែលអ៊ីចឹងទេ?

[១៥:៣៥:២៧]

**លោក ពាន ឃាន៖**

**ឆ៖** ខ្ញុំនៅយកតែតាមការពិត អ្វីដែលខ្ញុំឃើញ អ្វីដែលខ្ញុំបានដឹង។ បើថាខ្ញុំមិនដឹង ខ្ញុំមិនអាចនិយាយបាន។ អ៊ីចឹងខ្ញុំនៅរក្សាដដែល។

**ស៖** សូមអរគុណ។ ហើយលោកក៏បានជម្រាបអង្គសវនាការផងដែរថា ក្នុងខណៈពេលដែលមេដឹកនាំធំៗប្រជុំហ្នឹង លោកមិនដែលបានលើកម្ហូបអាហារ បាយទឹក ភេសជ្ជៈអីទៅជូនពួកគាត់ ក្នុងខណៈដែលគាត់កំពុងប្រជុំទេ។ តើលោកនៅរក្សាចម្លើយនេះដដែលទេ?

[១៥:៣៦:២៤]

**ឆ៖** ខ្ញុំនៅរក្សាដដែល ព្រោះខ្ញុំមិនបានដឹងបានឃើញ និយាយតាមការពិត។

**ស៖** សូមអរគុណ។ អ៊ីចឹង វាត្រឹមត្រូវទេ ដែលយើងអាចនិយាយថា លោកអត់បានដឹងថាអ្នកណាខ្លះ ថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងអស់ហ្នឹងអ្នកណាគេខ្លះដែលចូលរួមប្រជុំទាំងអស់ហ្នឹងទេ លោកអត់បានដឹកអ៊ីចឹងទេ តើលោកនៅរក្សាចម្លើយ តើយើងអាចនិយាយអ៊ីចឹងត្រឹមត្រូវបានទេ?

**ឆ៖** ខ្ញុំនៅរក្សាដដែល ព្រោះអ៊ំៗ ដែលខ្ញុំស្គាល់ប៉ុន្មាន ខ្ញុំស្គាល់ប៉ុណ្ណឹង ក្រៅពីហ្នឹងខ្ញុំអត់ដែលស្គាល់ ខ្ញុំអាច-- មិនអាចនិយាយបាន។

**ស៖** សូមអរគុណ។ ហើយតើត្រឹមត្រូវទេ ដែលយើងអាចនិយាយថា លោកមិនដែលបានដឹងថានៅឯកិច្ចប្រជុំរបស់មេដឹកនាំធំៗខ្ពស់ៗហ្នឹង គេពិភាក្សាពីប្រធានបទអ្វីខ្លះនោះ។ តើលោកគិតថានិយាយអ៊ីចឹងត្រឹមត្រូវ ហើយរក្សានៅដដែលអ៊ីចឹងទេ?

**ឆ៖** វាជាការពិត ព្រោះមនុស្សដែលយើងមិនយល់ ព្រោះយើងមិនមែនជាអ្នកដឹកនាំ។ អ៊ីចឹងការងារពាក់ជ្រៅ ជ្រៅជ្រះយើងមិនអាចដឹងបានទេ។

[១៥:៣៨:៣២]

**ស៖** អ៊ីចឹង ត្រឹមត្រូវទេដែលយើងអាចថាលោកមិនបានដឹងពីលទ្ធផលនៃការប្រជុំរបស់អស់លោកទាំងអស់ហ្នឹង គឺថាក្រោយពីប្រជុំមក លោកមិនបានដឹងពីលទ្ធផលនៃកិច្ចប្រជុំនុ៎ងទេ។ តើយើងនិយាយអ៊ីចឹងត្រឹមត្រូវទេ? តើលោកទទួលស្គាល់ថាអ៊ីចឹងទេ?

**ឆ៖** ខ្ញុំពិតជាទទួលស្គាល់អ៊ីចឹងមែន។

**ស៖** សូមអរគុណ។ អ៊ីចឹងផ្អែកទៅលើចម្លើយទាំងអម្បាលម៉ានរបស់លោកហ្នឹង ហើយដោយហេតុថាលោកអត់បានដឹងឮដោយផ្ទាល់ពីកិច្ចប្រជុំរបស់អស់លោកថ្នាក់ដឹកនាំខ្ពស់ៗទាំងអស់ហ្នឹង តើយើងអាចនិយាយបានថា ការដែលអ្នកអស់ហ្នឹងចូលទៅក្នុងបន្ទប់ហ្នឹងប្រជុំហ្នឹង នេះជាការស្មាន ជាការសន្មត ជាការសន្និដ្ឋានរបស់លោកទេអ្ហេស? តើលោកយល់ស្របអ៊ីចឹងមែនទេ?

[១៥:៤០:១១]

**ឆ៖** គឺបានន័យថា ការប្រជុំក៏ដោយសារឃើញចំណាំគាត់មកប្រមូលផ្តុំជួបគ្នា ទំនងជាគាត់ប្រជុំការងារ អាហ្នឹង។ ហើយម្យ៉ាងទៀត ខ្ញុំក៏មិនបានចូលទៅដល់កន្លែងប្រជុំទេ វានៅខាងក្រៅ នៅឯចង្ក្រានបាយឯណោះ គ្រាន់តែចេញចូលទៅកន្លែងហូបបាយម្តងមួយកាល។ អ៊ីចឹងខ្ញុំមិនអាចយល់ដឹងបានជ្រៅទេ។

**ស៖** អ៊ីចឹងអម្បាញ់មិញលោកមានប្រសាសន៍ថា នេះជា លោកប្រើពាក្យថា "ទំនងជាអ៊ីចឹង" ហើយនេះជាការយល់ដឹង ហើយជាការសន្និដ្ឋានស្មាន ឬសន្មតរបស់លោក អ៊ីចឹងមែនទេបាទ?

**ឆ៖** អាហ្នឹង គឺខ្ញុំយល់អ៊ីចឹងដែរ ការពិតគឺអ៊ីចឹង។

[១៥:៤១:៣៥]

**ស៖** សូមអរគុណ។ និយាយពីរឿងអង្គការ ចុះទាក់ទងនឹងកិច្ចប្រជុំវាងរបស់អង្គការវិញ តើលោកធ្លាប់បាន ដែលបានចូលរួមប្រជុំ កិច្ចប្រជុំរបស់អង្គការទេ?

**ឆ៖** អត់ទេ។

**ស៖** សូមអរគុណ។ លោកបានជម្រាបថា លោកមិនដែលបានចូលរួមប្រជុំកិច្ចប្រជុំនៅក្នុងរវាងនៅក្នុងអង្គការទេ។ អ៊ីចឹងក្រោយការប្រជុំទាំងឡាយ ឬក្រោយការប្រជុំនីមួយៗរបស់អង្គការហ្នឹង តើលោកដែលបានទទួល ឬគេដែលប្រគល់ឱ្យលោកនូវកំណត់ហេតុប្រជុំទាំងឡាយនោះ ឬក៏ជាសេចក្តីសង្ខេបនៃកិច្ចប្រជុំនោះដល់លោកទេ?

**ឆ៖** គឺអត់ទេ អត់មាន។

[១៥:៤៣:១១]

**ស៖** សូមអរគុណ។ និយាយពីសមាជិករបស់អង្គការវិញ តើសមាជិករបស់អង្គការទាំងឡាយនោះ ត្រូវបានគេផ្សព្វផ្សាយដឹងឮទូលំទូលាយជាសាធារណៈអីទេ?

**ឆ៖** អត់ទេ អត់មានផ្សព្វផ្សាយទេ។

**ស៖** សូមអរគុណ។ នៅថ្ងៃ ប្រហែលជាថ្ងៃនេះហើយ ប្រហែលជាលោកថ្ងៃហ្នឹងឯង លោកបាននិយាយថា ក្នុងចំណោមសមាជិករបស់អង្គការហ្នឹង គឺមានលោក អៀង សារី នៅក្នុងអង្គការ ជាសមាជិករបស់អង្គការដែរ។ តើជាការត្រឹមត្រូវទេ ដែលយើងអាចថា លោកនិយាយបែបនេះ គឺលោកគ្រាន់តែស្មាន សន្និដ្ឋាន ឬក៏សន្មតផ្ទាល់ខ្លួនតែប៉ុណ្ណឹង តើយើងនិយាយ អ៊ីចឹងត្រឹមត្រូវទេបាទ?

[១៥:៤៤:៥៤]

**ផ៖** អានេះ តាមដែលការដឹង ការឮ ការយល់ ដែលជាទូទៅ គេនិយាយក្នុងក្របខ័ណ្ឌអ៊ំៗ ប៉ុន្មាននាក់ហ្នឹង គឺជាក្របខ័ណ្ឌអង្គការ។

**ស៖** អាហ្នឹងគេនិយាយជាទូទៅពីមាត់មួយទៅមាត់មួយ ឬក៏យ៉ាងម៉េចខ្ញុំអត់សូវយល់ចំណុច ហ្នឹង ឬមួយមានការផ្សាយអីៗជាផ្លូវការអី បោះពុម្ពផ្សាយ ឬផ្សព្វផ្សាយតាមវិធីផ្លូវការណាមួយ ឬមួយ ក៏គ្រាន់តែឮគ្នាឯង ឮពីគ្នាទៅវិញទៅមក ពីមាត់មួយទៅមាត់មួយ? មួយណាសូមលោកបញ្ជាក់?

**ផ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)* តែប៉ុណ្ណឹង។

**ស៖** ខ្ញុំដូចអត់បានឮចម្លើយចុងក្រោយអំមិញ ឬមួយក៏-- សូមលោកឆ្លើយម្ដងទៀតបានទេ?

**ផ៖** ខ្ញុំគ្រាន់តែឮតគ្នាទេ។ មិនបានដឹងជាមូលដ្ឋានជាក់លាក់ ជាឯកសារអីទេ។

**ស៖** សូមអរគុណលោក ពាន ឃាន។ ខ្ញុំមានសំណួរតែមួយទៀតទេ ហើយលោកបានមាន ប្រសាសន៍អំមិញថា ឮគេប្រាប់ ហើយឮតពីគេ ហើយខ្ញុំចង់ដឹងថា អ្នកណាបានប្រាប់លោកពីរឿងហ្នឹង ថាអ្នកណាៗជា-- ខ្លះជាសមាជិក ឬមួយក៏ជាក់លាក់ថា លោក អៀង សារី ជាសមាជិករបស់អង្គការ ដែរ តើលោកឮពីនរណាគេ?

[១៥:៤៧:២៣]

**ផ៖** ខ្ញុំឮពីលោក ពូប៉ង់ ហើយនិង លីន ហ្នឹងឯង។

**ស៖** ឮពីលោក ប៉ង់ និងលោក លីន ហើយគាត់-- ឮយ៉ាងម៉េចគាត់មកប្រាប់លោក ឬមួយ លោកសួរគាត់ ឬមួយក៏ក្នុងឱកាសអីណាមួយ?

**ផ៖** ឮក្នុងពេលប្រជុំការងារអី ពេលល្ងាចៗធម្មតាតែថ្ងៃធ្វើការល្ងាចប្រជុំហើយ ហើយគាត់អ្នក ដឹកនាំប្រជុំ មាន ប៉ង់ មាន លីន ហ្នឹងហើយ ហើយគាត់បង្ហើបឲ្យដឹងខ្លះៗប៉ុណ្ណឹងទេ។

**ស៖** សូមអរគុណ។ ហើយក្រៅពីលោក អៀង សារី តើលោក ប៉ង់ ហើយនិងលោក លីន ហ្នឹង បានប្រាប់លោកថា មានអ្នកណាទៀតជាសមាជិករបស់អង្គការនុ៎ង?

**ផ៖** អត់មានទេ។

[១៥:៤៨:៥៤]

**ស៖** តើលោកចង់និយាយថា អង្កាល់នុ៎ងលោក ប៉ង់ និងលោក លីន ហ្នឹងបានប្រាប់លោក ឬក៏ ប្រាប់នៅក្នុងអង្គប្រជុំ។ តាមសម្ដីលោកថា អត់បានប្រាប់ថា អ្នកណាផ្សេងទៀតក្រៅពីលោក អៀង សារី ហ្នឹងជាសមាជិករបស់អង្គការ ឬមួយលោកចង់មានន័យផ្សេងពីនេះ?

**ឆ៖** អត់ទោស ខ្ញុំអត់ទាន់យល់សំណួរហ្នឹង។

**ស៖** សូមអភ័យទោស! សូមអធ្យាស្រ័យ! លោកមានប្រសាសន៍អំមិញថា នៅក្នុងកិច្ចប្រជុំរឿងណាមួយនោះ លោក ប៉ង់ ឬលោក លីន ហ្នឹងបានប្រាប់នៅក្នុងប្រជុំថា សមាជិកអង្គការហ្នឹងមានលោក អៀង សារី នៅក្នុងហ្នឹង។ តើការប្រកាសពេលប្រជុំហ្នឹង តើលោក ប៉ង់ លោក លីន ហ្នឹងបានប្រាប់ថាមានអ្នកណាផ្សេងទៀត ក្រៅពីលោក អៀង សារី ទេ ដែលជាសមាជិកនៅក្នុងអង្គការហ្នឹង? តើលោក ប៉ង់ ប្រាប់ថាមានអ្នកណាផ្សេងទៀតទេ ក្រៅពីលោក អៀង សារី ហ្នឹង?

[១៥:៥០:២០]

**ឆ៖** អត់មានទេ ប្រាប់តែប៉ុណ្ណឹង។

**ស៖** អម្បាញ់មិញហ្នឹង លោកមានប្រសាសន៍ ប៉ង់ និង លីន។ ឥឡូវខ្ញុំសួរពីរឿង ប៉ង់ តើប៉ង់មានសមាសភាពអ្វីនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍? ខ្ញុំចង់សួរថា តើលោកដឹងថា ប៉ង់ ជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេ គ្រាន់តែដឹងថាគាត់ ក្នុងក-៣, ក-១ ហ្នឹង គាត់ជាអ្នកគ្រប់គ្រងតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ចុះលោក លីន ដែលលោកបានរៀបរាប់អម្បាញ់មិញ តើលោកដឹងពីសមាសភាព មុខងារ មុខនាទីរបស់លោក លីន ដែរទេ? តើលោក លីន ហ្នឹង ជាសមាជិកនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ហ្នឹងដែរឬអត់? តើលោកដឹងរឿងហ្នឹងទេ?

[១៥:៥១:៥៤]

**ឆ៖** ខ្ញុំមិនបានដឹងទេ គ្រាន់តែដឹងថាគាត់ជាប្រធានមន្ទីរក-១ តែប៉ុណ្ណឹង។

**លោក អាង ឧត្តម៖**

សូមអរគុណ។ សូមអរគុណលោក ពាន ឃាន ខ្ញុំអស់សំណួរសួរលោកហើយ ហើយក្នុងនាមសហមេធាវីលោក អៀង សារី លោក ម៉ៃខល កាណាវាស ហើយនិងខ្ញុំ សូមអរគុណលោកជាច្រើនដែលបានអញ្ជើញមកចូលរួមចំណែកផ្តល់សក្ខីកម្មដល់តុលាការ ក្នុងការស្វែងរកយុត្តិធម៌ និងការពិត។ សូមជូនពរលោកឱ្យមានដំណើរសុវត្ថិភាព ពេលត្រឡប់ទៅផ្ទះវិញ។ សូមអរគុណ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី ហើយជាបន្ត គឺអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[១៥:៥៣:០៣]

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន។ អស់លោក លោកស្រីចៅក្រមជាទីគោរព។ ខ្ញុំសូមអភ័យទោស ពីព្រោះថា ខ្ញុំមិនអាចបញ្ចប់ការចោទសំណួរនេះ ក្នុងរយៈពេលដប់នាទីនេះទេ។ អ៊ីចឹង ជាអកុសល ខ្ញុំសូមជូនដំណឹងនេះ ទៅដល់អង្គជំនុំជម្រះ ហើយយើងបន្តទៅព្រឹកស្អែកទៀត។ លោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាមេធាវីរបស់លោក ខៀវ សំផន។ ហើយខ្ញុំចោទសំណួរលោក ក្នុងឋានៈជាមេធាវីលោក ខៀវ សំផន នេះឯង។ ហើយជាទូទៅ ថាជាសំណួរសូមបំភ្លឺទាក់ទងទៅនឹងការផ្ដល់សក្ខីកម្មរបស់លោកចំពោះអង្គជំនុំជម្រះ។

[១៥:៥៣:៥៥]

បើសិនជាមានសំណួរណាមួយដែលមានភាពស្រពេចស្រពិល សូមលោកកុំអល់អែកក្នុងការសុំឲ្យខ្ញុំបំភ្លឺ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ចំណុចទីមួយដែលខ្ញុំចង់និយាយជាមួយលោក គឺថាទាក់ទងនឹងរយៈកាលដែលលោកធ្វើការនៅមន្ទីរក-១។ លោកបានបង្ហាញកាលនៅ-- កាលពីថ្ងៃទី០៣ ឧសភា លោកបានធ្វើការនៅទីនោះអស់រយៈពេលប្រាំមួយខែ តើលោកអាចបញ្ជូនជូនអង្គជំនុំជម្រះឲ្យច្បាស់ទេ ថាតើរយៈពេលប្រាំមួយខែនេះ នៅក្នុងដំណាក់កាលណាដែរ?

**លោក ពាន ឃាន៖**

**ឆ៖** រយៈប្រាំមួយខែ ចាប់ពីខែ-- សូមអត់ទោស ខ្ញុំវាយូរពេកហើយ ខ្ញុំមិនអាចចងចាំបានទេ។ គ្រាន់តែដឹងថា ក្នុងឆ្នាំ ចុងឆ្នាំ៧៥ៗតែប៉ុណ្ណឹង។

[១៥:៥៥:២២]

**ស៖** សូមអរគុណ។ លោកក៏បានជម្រាបជូនអង្គជំនុំជម្រះ នៅថ្ងៃទី៣ ឧសភា ផងដែរ គ្រាន់គឺថានៅពេលដែលគេសុំឲ្យពិពណ៌នាអំពីមន្ទីរក-១ នេះ លោកថាមន្ទីរក-១ នោះថា ផ្ទុំឡើងដោយផ្ទះ

ពីរដែលនៅជិតគ្នា ហើយលោកក៏បានប្រាប់ផងដែរថា លោកស្ថិតនៅកន្លែងនោះក្នុងបរិវេណ ក-១ អស់រយៈពេល៦ខែ។ សំណួរខ្ញុំដូចតទៅនេះ តើលោកស្នាក់នៅក្នុងផ្ទះទាំងពីរ ដែលថាលោកបានពិព័ណ៌នានេះ ឬក៏លោកស្នាក់នៅកន្លែងផ្សេង?

[១៥:៥៦:១៩]

**ធ៖** បញ្ហាស្នាក់នៅវាអត់ទៀង ជួនកាលខ្ញុំនៅក្រៅ ផ្ទះល្វែងខាងក្រៅ ជួនកាលខ្ញុំទៅក្នុងអ៊ីចឹងទៅ។ អ៊ីចឹងវាអត់ទៀង បើអ៊ីចឹង ឲ្យខ្ញុំនិយាយប្រាប់ថាម៉េច បើវាមិនទៀងៗទាត់ទេ។

**ស៖** សូមអរគុណ។ លោកបានជម្រាបផងដែរថាមន្ទីរក-១ គឺជាកន្លែងដែល ប៉ុល ពត ស្នាក់នៅ។ នៅពេលដែលលោកស្នាក់នៅក្នុងក្នុងបរិវេណ ក-១ នេះ តើនៅ-- លោកស្នាក់នៅក្នុងអគារ ដូចនឹងអគារ ប៉ុល ពត ដែរឬក៏យ៉ាងម៉េច? អគារតែមួយទេ ឬក៏អគារផ្សេងទៀត?

**ធ៖** ខ្ញុំនៅអគារផ្សេង។ គ្រាន់តែពេលថ្ងៃអ៊ីចឹង ចូលធ្វើការកន្លែងដាំបាយ ដាំស្លកន្លែងហ្នឹងតែប៉ុណ្ណឹង ហើយការជម្រះស្មៅ ជម្រះអីនាយអាយតែប៉ុណ្ណឹង។

[១៥:៥៨:០៧]

**ស៖** លោកជម្រាបផងដែរថា លោកទៅក្នុងអគារនោះ ដែល-- អគារដែល ប៉ុល ពត នៅ។ អ៊ីចឹងបានន័យថា ចង្ក្រានបាយនោះនៅក្នុងអគារហ្នឹង ឬក៏យ៉ាងម៉េច?

**ធ៖** ចង្ក្រានបាយ គឺនៅក្នុងបរិវេណហ្នឹង។ បរិវេណអគារហ្នឹង ហើយក្រៅចង្ក្រានបាយមានរបងជុំវិញ។

**ស៖** តើអគារនោះមានប៉ុន្មានជាន់ដែរ?

**ធ៖** ខ្ញុំចាំអត់បានទេ ព្រោះមិនបាននឹកស្មានដល់។

**ស៖** នេះគឺជាសំណួរចុងក្រោយរបស់ខ្ញុំសម្រាប់ថ្ងៃនេះ។ តើមានដំណើរការសន្តិសុខជាក់លាក់ណាមួយក្នុងការចូលទៅមន្ទីរក-១ នោះដែរឬទេ?

**ធ៖** បញ្ហាចេញចូល ប្រឡោះចេញចូលមានរោងយាមប្រចាំថ្ងៃ។ រាល់ថ្ងៃការយាមច្រកចេញចូល។

[១៦:០០:១១]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ឥឡូវនេះម៉ោងបួនហើយ ខ្ញុំគិតថាគួរតែបញ្ចប់នូវត្រឹមណេះហើយ។

**ប្រធានអង្គជំនុំ៖**

ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន តើទំនងជាត្រូវការពេលវេលាប៉ុន្មានទៅក្នុងការសួរសាក្សីរូបនេះ?

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំគិតថា ខ្ញុំត្រូវការប្រហែលពីរ ៣០នាទីទៅ៣៥នាទី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មេធាវីជាតិយ៉ាងម៉េចដែរ មេធាវីជាតិត្រូវការតាំងសំណួរអីទេ?

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន ខ្ញុំមានសំណួរបន្តិចបន្តួចដែរបាទ។ ប្រហែល--

[១៦:០០:៥៨]

**ប្រធានអង្គជំនុំ៖**

ឈប់ៗ! ប្រហែលជាត្រូវការពេលវេលាប៉ុន្មាននទៅ?

**លោក គង់ សំអុន៖**

ប្រហែលពី១០ ទៅ១៥នាទីបាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០២:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះយើង អង្គជំនុំជម្រះមានបំណងបញ្ចប់ការតាំងសំណួរដេញដោល ចំពោះសាក្សីរូបនេះដោយសារគាត់អញ្ជើញមកភ្នំពេញនេះពីរដងហើយ។ ហើយពេលវេលាដូចជាមិនច្រើនទេ ហើយមិនគប្បីពន្យារដល់ពេល-- ដល់ថ្ងៃស្អែកទេ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចផ្តល់ពេលវេលា ៣០នាទីសម្រាប់មេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីតាំងសំណួរចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១៦:០៣:១៩]

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** លោកសាក្សី ខ្ញុំសោកស្តាយដែលធ្វើឲ្យលោកអស់កម្លាំងជាងនេះបន្តិចទៀតនោះ ហើយខ្ញុំព្យាយាមនិយាយដោយសង្ខេប។ លោកបានឆ្លើយទៅនឹងសហព្រះរាជអាជ្ញា លោកបានលើកឡើងថា

ប៉ុល ពត រស់នៅតែម្នាក់ឯងនៅ ក-១ ហើយមនុស្សម្នាក់ទៀត គឺឈ្មោះ ប៉ង់។ តើលោករក្សាចម្លើយរបស់លោកនេះដែរឬទេ?

**លោក ពាន ឃាន៖**

**ឆ៖** ខ្ញុំនៅតែរក្សាដដែលហ្នឹង ព្រោះតាមដែលខ្ញុំឃើញ។

**ស៖** ហើយបន្ទាប់ពីនៅទីនោះអស់រយៈពេលប្រាំមួយខែ លោកបានជម្រាបថា ពេលខ្លះលោកបានគេងនៅខាងក្នុងមន្ទីរក-១ ជួនកាលនៅខាងក្រៅមន្ទីរក-១។ តើលោកបន្ទាប់ពីប្រាំមួយខែហ្នឹង តើលោកធ្លាប់បានមកមន្ទីរក-១ វិញទេ? ហើយបើមកក្នុងឱកាសណាដែរ?

**ឆ៖** កាលពីខ្ញុំចេញពីក-១ ទៅ ខ្ញុំអត់ដែលបានចូលវិញទេ។

[១៦:០៥:០៥]

**ស៖** ឥឡូវនេះ ខ្ញុំសូមនិយាយអំពីមន្ទីរក-៣ ម្តង។ ធៀបទៅនឹងមន្ទីរក-១ តើលោកអាចពិពណ៌នាអំពីមន្ទីរក-៣ ដែរឬទេ? ថាមន្ទីរនេះធំជាង ក-១ ឬក៏តូចជាង ក-១?

**ឆ៖** មន្ទីរក-៣ ដោយសារកន្លែងនោះគាត់នៅគ្នាច្រើន អ៊ីចឹងខ្ញុំសន្និដ្ឋានថា-- ហើយផ្ទះក៏ច្រើនខ្ទង់ដែរ ប៉ុន្តែខ្ញុំមិនបានរៀបរាប់អស់ទេ។ ហើយគ្នាគាត់នៅជុំគ្នាកន្លែងហ្នឹង កន្លែង ក-៣ ហ្នឹង។ អ៊ីចឹងខ្ញុំចាត់ទុកថា កន្លែង ក-៣ ជាធំជាង ក-១។

**ស៖** លោកបានលើកឡើងថា ពួកគាត់ទាំងអស់នោះនៅក្នុងមន្ទីរក-៣ នោះ។ តើលោកអាចពិពណ៌នា អំពីការិយាល័យនៅក្នុង ក-៣ នោះដែរឬទេ? ព្រោះថាខ្ញុំពុំសូវច្បាស់ទេ ចំណុចនេះ។

**ឆ៖** ខ្ញុំមិនចាំ ឬក៏ស្គាល់តែទីការិយាល័យពិតប្រាកដទេ ប៉ុន្តែគាត់នៅតាមផ្ទះមួយៗរៀងខ្លួន។

[១៦:០៧:១២]

**ស៖** លោកធ្វើការនៅមន្ទីរ ក-៣ នុំងអស់រយៈពេលប៉ុន្មានឆ្នាំដែរ?

**ឆ៖** សរុបទៅប្រហែលជាកន្លះឆ្នាំដែរ។

**ស៖** ហើយក្នុងរយៈពេលប្រាំមួយខែនេះ លោកទៅ ក-៣ នុំងញឹកញាប់យ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំទៅញឹកញាប់ដោយសារការនាំស្បៀង នាំបន្លែ ផ្លូង អង្ករ ត្រីសាច់ ចេញចូល ក-៣, ក-១ ហ្នឹង។

**ស៖** បើសិនជាខ្ញុំមិនច្រឡំទេ គឺថាផ្ទុយពីមន្ទីរក-១ នោះ គឺថាលោកមិនបានស្នាក់នៅ ក-៣នេះជាអចិន្ត្រៃយ៍ទេ តើអ៊ីចឹងមែនទេ?

**ឆ៖** គឺប្រាកដជាអ៊ីចឹង។

**ស៖** តើមន្ទីរក-៣ ហ្នឹងមានព័ទ្ធរបងដែរឬទេ?

**ឆ៖** តាមខ្ញុំចំណាំ ខ្ញុំឃើញតែរបងពីខាងមុខ និងខាងក្រោយ អាចំហៀង ខ្ញុំមិនបានដើរជុំទេ។ គ្រាន់តែដើរចេញចូលមុខក្រោយប៉ុណ្ណឹង។

[១៦:០៩:២២]

**ស៖** ដែលខ្លួនលោកផ្ទាល់ហ្នឹង នៅពេលដែលលោកទៅមន្ទីរក-៣ នោះ តើលោកត្រូវឆ្លងកាត់កុងត្រូលសន្តិសុខអីមួយទេ ព្រោះថាមានន័រប្បៀបរបបសន្តិសុខដូចនៅមន្ទីរក-១ ដែលនោះ។ តើលោកបានធ្វើអ៊ីចឹងទេ?

**ឆ៖** ជាធម្មតា កន្លែង ក-៣ ដូច ក-១ ដែរ កន្លែងចេញចូលត្រូវមានអ្នក រោងយាមដែរ។ រោងយាមទ្វារចេញចូលដូចគ្នា។

[១៦:១០:១៥]

**ស៖** លោកបានជម្រាបផងដែរ កាលពីពីរបីនាទីមុននេះ គឺថានៅមន្ទីរក-៣ គេមានផ្ទះដាច់ដោយឡែកពីគ្នា។ តើលោកអាចជម្រាបមកខ្ញុំបានដែរឬទេ ថាចង្ក្រានបាយនោះនៅកន្លែងណាធៀបទៅនឹងផ្ទះដែលមាននៅក្នុងមន្ទីរក-៣ នេះ?

**ឆ៖** បើតាមខ្ញុំចាំ ឯជ្រុងខាងជើង អាហ្នឹងជាផ្ទះបាយ ហើយខាងត្បូងផ្ទះស្នាក់នៅរបស់អ៊ំៗ។

**ស៖** លោកបានជម្រាបថា លោកសន្មតថាមានការប្រជុំរវាងថ្នាក់ដឹកនាំផ្សេងៗ ហើយលោកមិនដែលបានទៅបន្ទប់ប្រជុំនោះទេ។ តើលោកអាចកំណត់ទីតាំងបន្ទប់ប្រជុំដែលលោកសន្មតថាមានការប្រជុំនៅក្នុងនោះ ហើយបើធៀប ហើយសាលបន្ទប់ប្រជុំនេះធៀបទៅនឹងចង្ក្រានបាយនោះនៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំចាំអត់បាន ប៉ុន្តែដឹងថាកន្លែងស្នាក់នៅ ហើយនិងកន្លែងចង្ក្រាន។ ត្រង់គាត់ប្រជុំកន្លែងណា ពិភាក្សាកន្លែងណា ខ្ញុំអត់បានចូលទៅដល់ទេ។

[១៦:១២:៤៤]

**ស៖** តើលោកត្រូវបានអនុញ្ញាតក្នុងឋានៈលោកជាអ្នកធ្វើការនៅចង្ក្រានបាយនោះ តើលោកអាចធ្វើចរាចរនៅក្នុងបរិវេណមន្ទីរក-៣ ហ្នឹងដែរឬទេ?

**ឆ៖** គឺអត់ទេ គឺចូលពីក្រៅមក ត្រឹមផ្ទះបាយហ្នឹងតែម្តង។

**ស៖** ពីចង្ក្រានបាយទៅផ្ទះនោះ ហើយលោកចង់និយាយពីផ្ទះមួយណាដែរ?

**ឆ៖** ផ្ទះស្នាក់នៅរបស់អ៊ំៗ។

**ស៖** តើជាកន្លែងតែមួយហ្នឹងទេ ដែលលោកអាចចូលបានមែនទេ ជាផ្ទះហ្នឹង?

**ឆ៖** ខ្ញុំចូលបានតែផ្ទះតែមួយ ផ្ទះបាយហ្នឹងទេ ដែលជាចូលញ៉ឹកញាប់ត្រឹមផ្ទះបាយហ្នឹង។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចូលទៅដល់ប្រធានបទមួយទៀត។ ថ្ងៃនេះលោកបាន-- ថ្ងៃនេះ និងថ្ងៃមុនៗនោះ លោកបាននិយាយអំពីការសម្ភាសលោកពីរដងអំពីអង្គហេតុដែលកើតនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ លោកបានលើកឡើងជាមួយនឹងខាងសហព្រះរាជអាជ្ញា គឺថានៅខែកក្កដា ឆ្នាំ២០០៥ ជាលើកទីមួយ ហើយលើកទីពីរ គឺលោកត្រូវបានសួរដោយខាងអ្នកស៊ើបអង្កេតនៃ អ.វ.ត.ក។ ខ្ញុំចង់សួរអំពីការសម្ភាសលើកទីមួយ គឺនៅខែកក្កដា ឆ្នាំ២០០៥។ លោកបានឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ដោយបានបញ្ជាក់ថា លោកមិនបានចាំឈ្មោះអ្នកដែលបានសួរលោកទេ។ សំណួររបស់ខ្ញុំ ដូចតទៅនេះ៖ ដោយមិនបានចាំឈ្មោះនេះ តើលោកដឹងថា តើអ្នកទាំងមកជួបលោកយ៉ាងម៉េច? គាត់មានបានប្រាប់លោកថា គាត់មកសួរសម្ភាសលោកហ្នឹងតំណាងឲ្យអង្គការណា? គាត់ធ្វើការអីដែរឬទេ?

**ឆ៖** ពេលនុំងគេគ្រាន់តែប្រាប់ថា ពួកគាត់ជាក្រុមស្រាវជ្រាវសាលាក្តីខ្មែរក្រហម។ គេប្រាប់ខ្ញុំតែប៉ុណ្ណឹង។

[១៦:១៦:៣៦]

**ស៖** ខ្ញុំសូមរំឭកម្តងទៀតថា ខ្ញុំនិយាយអំពីកិច្ចសម្ភាសន៍លើកទីមួយ ដែលលោកបានធ្វើនៅឆ្នាំ ២០០៥ គឺថាមានអ្នកស្រាវជ្រាវមកពីតុលាការទៅសួរលោកអ៊ីចឹងមែនទេ? អ្វីដែលលោកឆ្លើយអំមិញនេះ?

**ឆ៖** គឺពិតជាអ៊ីចឹង។

**ស៖** តើគេទាក់ទងលោកយ៉ាងម៉េច ដើម្បីឲ្យលោកផ្តល់បទសម្ភាសន៍នេះ?

**ឆ៖** ហើយរឿងនេះ មានអ្នកស្គាល់ៗខ្ញុំ ប៉ុន្តែខ្ញុំអត់ចាំឈ្មោះគេទេ ឥឡូវនេះ។ គេក៏ធ្លាប់ស្គាល់ខ្ញុំដែរ។ ហើយកាលនៅភ្នំពេញ ក៏នៅជាមួយគ្នា ក្បែរគ្នាដែរ ប៉ុន្តែឥឡូវគេស្គាល់ខ្ញុំ គេដឹងថាខ្ញុំនៅកន្លែង ក-១ និង ក-៣ អ៊ីចឹងគេនាំខាងក្រុមស្រាវជ្រាវហ្នឹងទៅដល់ផ្ទះខ្ញុំតែម្តង។

[១៦:១៨:៣៣]

**ស៖** កាលពីព្រឹកមិញនេះ ហើយនិងនៅរសៀលនេះដែរ គេបានអាននូវសម្រង់ជាច្រើន គឺជាសេចក្ដីសង្ខេបដែលធ្វើដោយបុគ្គលនោះ ដែលថា គឺថា គឺជាបទសម្ភាសន៍ដែលលោកបានធ្វើ។ លោកបានបញ្ជាក់ដោយឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាថា ការសង្ខេបនេះ គឺត្រូវបានផ្ដល់ជូនលោកនូវមុនពេលដែលលោកមកផ្ដល់សក្ខីកម្មនៅចំពោះមុខតុលាការនេះ។ សំណួររបស់ខ្ញុំចង់ដឹងថាមុនពេលដែលបុគ្គលិកតុលាការផ្ដល់ជូនឯកសារសម្ភាសនេះទៅដល់លោក តើលោកមានធ្លាប់ឃើញទេពីមុនមកនោះ?

[១៦:១៩:២៦]

**ឆ៖** អត់ដែលឃើញទេ។ ម្យ៉ាងក្រែងលោខ្ញុំវាភ្លេចចាំឈ្មោះ វាយូរហើយ មិនបានចំណាំ។

**ស៖** នៅថ្ងៃសម្ភាសនោះ គឺនៅខែកក្កដា ឆ្នាំ២០០៥ តើលោកមានបានចុះហត្ថលេខាលើឯកសារអីទេ?

**ឆ៖** ខ្ញុំចាំអត់បានទេ។

**ស៖** តើលោកមានបានជួបអ្នកដែលបានសម្ភាសលោកទេ នៅក្រោយខែកក្កដា ឆ្នាំ២០០៥ នោះ?

**ឆ៖** អត់ទេ ឃើញតែម្ដងហ្នឹង។

**ស៖** នៅក្នុងលក្ខខណ្ឌបែបនេះ តើវាជាការពិតដែរទេ ដែលនិយាយថាលោកថាមិនបានកែតម្រូវ ឬក៏ធ្វើការបញ្ជាក់ចំពោះកំណត់ហេតុដែលគេបានធ្វើនៅពេលសម្ភាសនេះទេ មែនទេ?

**ឆ៖** ខ្ញុំអត់យល់សំណួរ។ សូមបញ្ជាក់ម្ដងទៀត។

**ស៖** មិនអីទេ ខ្ញុំសូមទោសដែលសំណួរខ្ញុំនេះ ដូចជាមិនច្បាស់។ សំណួរដែលខ្ញុំសួរនោះ គឺថាតើលោកមានបានអានឯកសារដែលគេបានសម្ភាសលោកហ្នឹងឡើងវិញទេ ពេលដែលគេសម្ភាសហើយគេធ្វើជាកំណត់ហេតុហ្នឹង? អ៊ីចឹង តើលោកមានបានអានកំណត់ហេតុហ្នឹងទេ?

**ឆ៖** តាំងពីសម្ភាសហើយ ខ្ញុំមិនដែលបានអានទេ។ ទុកនៅផ្ទះរហូត ហើយម្យ៉ាងរវល់ជាប់ការងារផ្ទាល់ខ្លួនទៅ មិនបានដែលមើលទេ។ ទើបតែថ្ងៃកោះហៅនេះ ទើបប្រមូលឯកសារដែលដឹងហ្នឹងមក យកមកតាមវិញ។

[១៦:២២:២៧]

**ស៖** ខ្ញុំចង់សួរបំភ្លឺមួយ ចំពោះចម្លើយចុងក្រោយរបស់លោក។ តើនៅខែកក្កដា ឆ្នាំ២០០៥ នៅពេលដែលគេសម្ភាសលោកហើយនោះ គេមានផ្ដល់ឯកសារអីជូនលោកទេ ក្រោយពីបញ្ចប់កិច្ចសម្ភាសន៍?

**ឆ៖** កាលនោះ អត់មានទេ។ ពេលសម្ភាសហើយ ចប់អ៊ីចេះ ក៏ចប់ទៅបណ្ដោយ លើកទីមួយ។

**ស៖** បើខ្ញុំស្ដាប់ចម្លើយចុងក្រោយរបស់លោកនោះ គឺថា នៅពេលរៀបចំមកបង្ហាញខ្លួននៅសវនាការនេះ គឺលោកមានឯកសារនេះនៅក្នុងដៃ តើអ៊ីចឹងមែនទេ?

**ឆ៖** ឯកសារនេះ ជាឯកសារលើកទីពីរ ដែលសម្ភាសលើកទីពីរទេ។ អារឿងលើកទីមួយ អត់មានទេ។

**ស៖** ខ្ញុំគិតថាមានបញ្ហាខាងការបកប្រែជាភាសាបារាំង គឺថាឯកសារដែលគេផ្ដល់ជូននោះ គឺជាឯកសារសម្ភាសលើកទីពីរ អ៊ីចឹងមែនទេ? មិនមែនសម្ភាសលើកទីមួយទេ?

[១៦:២៤:១៥]

**ឆ៖** សម្ភាសលើកទីពីរ។ ទីមួយ អត់មានទេ។

**ស៖** ខ្ញុំចង់ត្រឡប់មកនិយាយអំពីខ្លឹមសារនៃសេចក្ដីសង្ខេបកិច្ចសម្ភាសន៍លើកទីមួយ។ ពីព្រោះថា នៅថ្ងៃនោះ លោកបានបញ្ជាក់ជូនអំពីអង្គហេតុមួយចំនួនដែលមាននៅក្នុងកិច្ចសម្ភាសន៍សង្ខេបនោះ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីជាការចងចាំឲ្យដល់សាក្សីនោះ សូមឲ្យអង្គជំនុំជម្រះមេត្តាអនុញ្ញាតឲ្យបញ្ចាំងសេចក្ដីនៃកិច្ចសម្ភាសន៍ដែលមានលេខ E187.9 ដែលមានលេខចាស់ D2/15.58 ដើម្បីសួរសំណួរមួយចំនួនទៅកាន់សាក្សីរូបនេះ។ តើខ្ញុំអាចទទួលបានការអនុញ្ញាតពីអង្គជំនុំជម្រះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមផ្ដល់នូវលេខយោង ERN សម្រាប់ជាបីភាសា។ ជាភាសាបារាំង 00644576, ជាភាសាអង់គ្លេស 00089701 និងជាភាសាខ្មែរ 00801770។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមឲ្យសាក្សីពិនិត្យមើលនៅកថាខណ្ឌទី២ ជាភាសាបារាំង ខ្ញុំមិនដឹងថាតើក្នុងភាសាខ្មែរនៅកថាខណ្ឌណាមួយទេ? គឺមានសេចក្ដីថា កាលមុនគឺខ្ញុំស្នាក់នៅក-១ និងក-៣ តើលោករកឃើញទេ កថាខណ្ឌដែលខ្ញុំនិយាយអម្បាញ់មិញនេះ?

*(សាក្សីពិនិត្យមើលឯកសារ)*

លោកសាក្សីតើលោករកឃើញកថាខណ្ឌ ដែលខ្ញុំអានអម្បាញ់មិញនេះទេ?

[១៦:២៧:៤២]

**លោក ពាន ឃាន៖**

**ឆ៖** កថាខណ្ឌនេះនិយាយពីរឿង ក-១ និង ក-៣ មែនទេ?

**ស៖** គឺអ៊ីចឹងហើយ គឺថានៅក្នុងកថាខណ្ឌនោះ គឺមានផ្នែកមួយ ដែលខាងសហព្រះរាជអាជ្ញាបានអានជូនលោកស្ដាប់កាលពីព្រឹកមិញនេះរួចហើយ។ គឺនៅខាងក្រោមបន្តិចមក គឺប្រាំបន្ទាត់មុនបញ្ចប់កថាខណ្ឌនេះជាភាសាបារាំង។ “ប៉ង់ ទទួលបន្ទុកមន្ទីរកទាំងអស់ គឺ ប៉ង់ ជាអ្នករៀបចំកិច្ចប្រជុំ ប៉ុន្តែហែម ខៀវ សំផន គឺគាត់ធ្វើជាអធិបតីភាពខាងផ្នែកនយោបាយ គឺក្រោម ប៉ុល គឺគាត់ទទួលខុសត្រូវខាងនយោបាយជាមួយ នួន។ ហែម (ខៀវ សំផន) គឺធ្វើប្រធានក្នុងកិច្ចប្រជុំសាខាបក្ស នៅតាមមន្ទីរការិយាល័យមន្ទីរ ក”។ សំណួររបស់ខ្ញុំដូចតទៅនេះ៖ អ្វីដែលលោកបានអះអាងជូនទៅខាងសហព្រះរាជអាជ្ញាថា បងហែម ទទួលខុសត្រូវខាងផ្នែកកិច្ចប្រជុំនយោបាយ ដូចដែលមានបញ្ជាក់ជូននៅក្នុងឯកសារសង្ខេបនេះ តើលោកផ្អែកលើអ្វីដែលលោកបានអះអាងបែបនេះនោះ? លោកមានសំអាងបែបណា?

[១៦:២៨:២៥]

**ឆ៖** សំអាងបែបណា គឺដោយសារ ប៉ង់ ហើយនិង លីន គឺជាអ្នកប្រាប់។ មើលកិច្ចការទាំងអស់ហ្នឹង ព្រោះធម្មតាកន្លែងហ្នឹង ខ្ញុំជាអ្នកចេញចូលដឹកស្បៀង ដឹកអាហារ ហើយខ្ញុំក៏មិនបានយល់ន័យជ្រៅជ្រះអីទេ ប៉ុន្តែគ្រាន់ថា តាមការប្រជុំ តាមការរស់នៅ ឆ្លងកាត់តាមការឃើញ ឆ្លងកាត់ ហើយការសន្និដ្ឋានខ្លះ ក៏ឃើញថាអាចកំណត់ថា អ៊ំ ខៀវ សំផន ពេលប្រជុំគាត់ជាប្រធាន ប៉ុន្តែចាត់ចែងការងារគឺនៅលើ ប៉ង់។ ប៉ុន្តែខ្លឹមសារពិតយ៉ាងណាទៀត ខ្ញុំវាមិនបានយល់ជ្រៅដែរ ព្រោះអីខ្ញុំមិនបានទៅយល់ទៅក្នុងការដឹកនាំហ្នឹងទេ ខ្ញុំគ្រាន់តែអ្នកនៅក្រៅ។ តាមការសង្កេត និងតាមការឮ ការដឹងខ្លះៗប៉ុណ្ណឹង។

**ស៖** លោកបាននិយាយថា លោកបានទទួលព័ត៌មាននេះតាមរបៀបការសង្កេត។ តើការប្រជុំនេះប្រព្រឹត្តទៅនៅក្នុងផ្ទះរបស់ នួន ជា មែនទេ?

**ឆ៖** កន្លែងប្រជុំ ខ្ញុំមិនបាន ដូចបានជម្រាបពីខាងដើមច្រើនសាហើយថា ខ្ញុំមិនបានដឹងទេ ខ្ញុំដឹងតែផ្ទះស្នាក់នៅ។

**ស៖** លោកមិនដឹងទេថា កិច្ចប្រជុំប្រព្រឹត្តទៅនៅកន្លែងណានោះ។ ហើយលោកបានបញ្ជាក់ថា លោកក៏មិនធ្លាប់ចូលរួមនៅក្នុងកិច្ចប្រជុំណាមួយដែរ។ អ៊ីចឹង តើចំណុចណាមួយដែលធ្វើឲ្យលោក

សន្និដ្ឋានបានថា ខៀវ សំផន ធ្វើជាប្រធាននៅក្នុងកិច្ចប្រជុំនៅតាមមន្ទីរនៃការិយាល័យ “ក” នោះ?

[១៦:៣២:១៥]

**ធ៖** អានេះទៅតាមការសន្និដ្ឋាន ព្រោះធម្មតានៅក-៣។ បន្ទាប់លើ ប៉ុង មានតែអ៊ំ ខៀវ សំផន ប៉ុណ្ណឹង ដើរតួក្នុងការងារប្រជុំនៅក-៣។ អ៊ីចឹងជាការសន្និដ្ឋានរបស់ខ្ញុំ ហើយតាមការដឹង ការឮក៏វាដូច្នោះដែរ។

**ស៖** លោកសាក្សីតើលោកដឹង អំពីមុខងារពិតប្រាកដរបស់លោក ខៀវ សំផន នៅសម័យនោះទេ?

**ធ៖** ជាផ្លូវការ ខ្ញុំដឹងថាគាត់ធ្វើជាប្រធានគណៈប្រធានរដ្ឋ។

**ស៖** តើលោកដឹងទេថា មុខតំណែងជាប្រធានគណៈប្រធានរដ្ឋនោះ គាត់ធ្វើអីខ្លះដែរ?

**ធ៖** ខ្ញុំអត់ដឹងទេ ខ្ញុំអត់បានដឹងចូលជ្រៅទេ គ្រាន់តែដឹងតែប៉ុណ្ណឹង។

**ស៖** ដូច្នេះ អ្វីដែលលោកអាចបាន និយាយបានពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន នៅថ្ងៃនេះ ឬក៏នៅក្នុងសេចក្ដីប្រកាសរបស់លោកពីមុនៗនោះ គឺគ្រាន់តែជាការសន្និដ្ឋានព្រាវៗរបស់លោកទេ មែនទេ?

[១៦:៣៤:២៥]

**ធ៖** វាមិនព្រាវទាំងអស់ទេ។ ពិតប្រាកដដូចថា អ៊ំ ខៀវ សំផន គាត់ដើរតួខាងគណៈប្រធានរដ្ឋអាហ្នឹងគឺវាពិតហើយ។ ឯរាល់តែការ កិច្ចការនៅ ក-៣ គឺគាត់បានចូលរួមពិតប្រាកដ មិនមែនព្រាវទេ គឺគាត់នៅស្នាក់នៅហ្នឹងដែរ។ ផ្ទះគាត់ស្នាក់នៅ អ៊ំប៉ុល ពត ក៏នៅហ្នឹង អ៎! អ៊ំ នួន ជា ក៏នៅហ្នឹង អ៊ំ ខៀវ សំផនក៏នៅហ្នឹង អ៊ំ អៀង សារី ក៏នៅហ្នឹង។ អាហ្នឹងគឺប្រាកដតែម្ដង។

[១៦:៣៥:១១]

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងមន្ទីរក-៣។ លោកដឹងទេថា មានអ្នកផ្សេងណាទៀតទេដែលរស់នៅ ក-១ និង ក-៣ ដែលជាសមាជិកក្រុមគ្រួសាររបស់មេដឹកនាំដែលលោកបាននិយាយនោះ?

**ធ៖** អត់មានទេ។ អត់ដែលឃើញក្រៅពីហ្នឹងទេ។

**ស៖** យោងតាមចម្លើយរបស់លោកអម្បាញ់មិញនេះ ដែលលោកឆ្លើយជូនចំពោះមេធាវីលោក អៀង សារី តើជាការត្រឹមត្រូវដែរឬទេ ដែលនិយាយ-- ក្នុងការនិយាយថា លោកមិនបានដឹងដោយផ្ទាល់អំពីតួនាទីរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យទេ មែនទេ?

**ឆ៖** ខ្ញុំពិតជាមិនបានដឹងអស់ទេ ពីតួនាទីដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ ព្រោះជាលាក់ការណ៍របស់មេដឹកនាំធំៗ គេមិនអាចឲ្យខ្ញុំដឹងបានទេ។

[១៦:៣៦:៥៦]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកសាក្សី ដែលបានមានភាពអត់ធ្មត់ក្នុងការឆ្លើយតបទៅនឹងសំណួរក្នុងរយៈពេលដ៏វែងនេះ។

**ប្រធានអង្គជំនុំ៖**

មេធាវីជាតិ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ដោយសារពេលវេលាយើងនេះហើយ ខ្ញុំបាទសូមសួរសំណួរខ្លីៗ។

សូមលោកសាក្សីជួយឆ្លើយសំណួរខ្លីៗមកខ្ញុំបាទដើម្បីជម្រាបជូនទៅអង្គជំនុំជម្រះផងបាទ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំជាដំបូង សូមលោកជួយបញ្ជាក់អំពីឋានៈរបស់លោកនៅមុនឆ្នាំ១៩៧៥ គឺមុនរំដោះ នៅពេលដែលលោកនៅជាមួយលោក កុយ ឃួន ដែលលោកនិយាយនោះ។ តើលោកមានឋានៈជាអ្វីដែលពេលនោះ?

**លោក ពាន ឃាន៖**

**ឆ៖** សូមអត់ទោសដល់លោកប្រធានផងចុះ ខ្ញុំបញ្ជាក់តែខ្លីប៉ុណ្ណឹង។ តាំងពីខ្ញុំចូលរួមចលនាបដិវត្តន៍តាំងពីអាយុ១៦ រហូតមកដល់រំដោះ១៧ មេសា។ ខ្ញុំអត់មានតួនាទីអីទាំងអស់។ និយាយខ្លីប៉ុណ្ណឹងតែម្ដង។ អត់មានឋានៈ តំណែងអីទេ។

[១៦:៣៨:២០]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ជូនក្រុមប្រឹក្សាជំនុំជម្រះបន្តិចអំពីការងារប្រចាំថ្ងៃដែលលោកបានធ្វើនៅក្នុងឆ្នាំមុន-- មុនឆ្នាំ៧៥នោះ ជាកិច្ចការអីខ្លះដែលលោកបានធ្វើជាប្រចាំនៅក្នុងគ្រួសាររបស់លោក កុយ ឃួន ហ្នឹង?

**ឆ៖** នៅពេលនោះ ខ្ញុំនៅជាមួយប្រពន្ធលោក កុយ ឃួន ក៏ដូចជានៅជាមួយ កុយ ឃួន ដែរ។ ជូនគាត់ចុះឡើងពីកំពង់ធំ កំពង់ចាម ហើយកាលនោះ បើថានៅកន្លែង ជួយដាំបាយ ដាំស្ល ឲ្យនៅ រហូត

ដល់គក់ខោអាវទាំងប្តីទាំងប្រពន្ធទៀត។ តាមបម្រើអស់លទ្ធភាព។ ជម្រាបត្រង់អ៊ីចឹង។

**ស៖** បាទសូមអរគុណ។ អ៊ីចឹងខ្ញុំសរុបមកវិញថា ការងាររបស់លោកដែលធ្វើជាប្រចាំនោះ មែនទែនទៅគឺជាការងារបម្រើនៅក្នុងផ្ទះរបស់លោកគ្រួសារលោក កុយ ធួន។ អ៊ីចឹងមែនទេ?

**ឆ៖** គឺពិតជាអ៊ីចឹងលោក។

[១៦:៣៩:៤៨]

**ស៖** បាទសូមអរគុណ។ អ៊ីចឹងឆ្លងមកពេលរំដោះឆ្នាំ១៩៧៥ ដែលលោក អម្បាញ់លោកបាន មានប្រសាសន៍ ហើយតាំងពីដំបូងមក គឺថាលោកបានមកធ្វើការនៅ ក-១ ឬក៏ ក-៣។ លោកអាច បញ្ជាក់បានទេថា ការងារប្រចាំថ្ងៃរបស់លោកនៅ ក-១ និងនៅ ក-៣ នោះធ្វើអ្វីខ្លះ?

**ឆ៖** ខ្ញុំអាចបញ្ជាក់បាន។ ការងារនៅក-១ ក៏ដូចនៅ ក-៣ ហើយក៏ខ្ញុំបានបញ្ជាក់រឿយៗហើយ ដែរ។ តួនាទីខ្ញុំ គឺដឹកបន្លែ ដឹកស្រូវ ដឹកអង្ករ ដឹកបន្លែ ត្រីសាច់ ចេញចូល ក-១, ក-៣ ចង្ក្រានបាយទាំងពីរ ហ្នឹង។ ទាំងនេះការងារប្រចាំថ្ងៃរបស់ខ្ញុំ ហើយជួនកាលក៏ជួយដាំស្ល ចុងភៅកន្លែងនុំងទាំងពីរហ្នឹង។

**ស៖** បាទ សូមអរគុណ។ ការងារជញ្ជូនបន្លែនេះហ្នឹង លោកមានដាំបន្លែដែរទេ?

[១៦:៤១:១៧]

**ឆ៖** ខ្ញុំធ្លាប់ដាំ ដាំបន្លែ ដាំជីតាមចន្លោះផ្ទះ ក-១ និង ក-៣ នេះដែរ ក្បែរៗចង្ក្រានបាយហ្នឹង។

**ស៖** លោក-- បាទ សូមអរគុណ។ ការដាំបន្លែរបស់លោក ដាំជារបៀបជារង ជាថ្នាល ឬមួយ ក៏ដាំបន្តិចបន្តួចនៅក្បែរពាងទឹកអីទេ?

**ឆ៖** ដាំបន្តិចបន្តួចទេ សម្រាប់តែជីបន្លែតិចតួចសម្រាប់ផ្ទះបាយហ្នឹង ប្រើប្រាស់ហ្នឹង។

**ស៖** តើលោកចំណាយពេលធ្វើការរយៈពេលប៉ុន្មានម៉ោងដែរក្នុងមួយថ្ងៃក្នុងការដាំបន្លែហ្នឹង?

**ឆ៖** ជួនកាលក៏កន្លះម៉ោង ជួនកាលក៏មួយម៉ោងអ៊ីចឹងទៅ។

**ស៖** បាទ ទាក់ទងទៅនឹងសំណួរដែលលោកបានឆ្លើយចំពោះក្រុមមួយដែលមានឈ្មោះ អក្សរ កាត់ថា អូ.អេស.អេ.អេស នៅឆ្នាំ២០០៥ តើលោកបានឆ្លើយប្រាប់គេថា លោករស់នៅជាមួយ កុយ ឃួន ឬមួយក៏ កុយ ធួន នៅពេលនោះ?

**ឆ៖** ឈ្មោះនេះ ខ្ញុំធ្លាប់បានបញ្ជាក់ញឹកញាប់ហើយតាំងពីថ្ងៃមុន។ គឺមិនមែន កុយ ធួន ទេ គឺ កុយ ឃួន គេហៅ ធុច។

[១៦:៤៣:២១]

**ស៖** បាទ សូមអរគុណ។ សូមលោកបញ្ជាក់ថា តើក្នុង-- នៅពេលដែលលោកធ្វើសម្ភាសន៍ជាមួយគេនៅឆ្នាំ២០០៥នោះ លោកបាន ឬក៏គេបានសួរបញ្ជាក់លោកថា ឈ្មោះនោះជាឈ្មោះ កុយ ឃួន ឬក៏ កុយ ធួន ដែរឬទេ? មានបានពិភាក្សាពីឈ្មោះហ្នឹងទេ?

**ឆ៖** គេអត់បានសួរបញ្ជាក់ខ្ញុំទេ។

**ស៖** បាទ សូមអរគុណ។

**លោក គង់ សំអុន៖**

លោកប្រធាន សូមអស់សំណួរ។

[១៦:៤៣:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះកិច្ចដំណើរការពិភាក្សាដេញដោលចំពោះសាក្សី ពាន ឃាន ឃើញថាដល់ទីបញ្ចប់ហើយ។ ហើយមុននឹងបញ្ចប់ អង្គជំនុំជម្រះសូមថ្លែងអំណរគុណចំពោះលោក ពាន ឃាន ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញមកចូលរួម ការផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតាមដីកាកោះហៅរបស់អង្គជំនុំជម្រះ។ ហើយពីរដងហើយដែលលោកអញ្ជើញមកទីនេះ ដោយលើកទីមួយលោកមានបញ្ហាសុខភាព មិនអាចធ្វើបានចប់ចុងចប់ដើម។ ហើយថ្ងៃនេះ លោកបាន ប្រឹងប្រែង អត់ធ្មត់ហើយឆ្លើយតបនឹងសំណួរបានល្អ។ ហើយដោយសារការដែលលោកបានផ្ដល់សក្ខីកម្មចប់សព្វគ្រប់ ហើយអង្គជំនុំជម្រះមិនមានអ្វីដែលនឹងត្រូវការសួរសំណួរចំពោះបញ្ហាអង្គហេតុដែលចោទប្រកាន់ កំពុងធ្វើសវនាការនេះចំពោះលោកទៀតទេ។ ដូច្នេះលោកអាចវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅដែលលោកចង់ទៅបានហើយ។

[១៦:៤៥:០៧]

ហើយឥឡូវនេះ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះឃើញថា សមល្មមនឹងផ្អាកហើយ។ ហើយសវនាការគ្រោងទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២១ ខែឧសភា ឆ្នាំ២០១២ ហើយនៅក្នុងកិច្ចដំណើរការសវនាការដែលគ្រោងធ្វើនៅថ្ងៃចន្ទនោះ គឺអង្គជំនុំជម្រះសូមជម្រាបដល់ភាគី និងសាធារណជនថា អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-487។ អង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនផងដែរ ថាដោយសារកាលវិភាគនៃការស្ដាប់សក្ខីកម្មសាក្សីរូបនេះតាមការគណនាពេលវេលាដែលភាគីបានស្នើសុំគឺ អាចនឹងចប់នៅថ្ងៃស្អែក។ អ៊ីចឹងហើយអង្គជំនុំជម្រះបាន

ជម្រាបជូនដំណឹងតាំងពីថ្ងៃទី០៣ ថាគ្រោងធ្វើពីរថ្ងៃ គឺថ្ងៃ១៧ និងថ្ងៃ១៨ ប៉ុន្តែឥឡូវនេះ គឺទីមួយបានចប់មុនពេលវេលាដែលបានគ្រោងទុក។

[១៦:៤៦:១៩]

បញ្ហាទីពីរ គឺដោយហេតុថានៅថ្ងៃស្អែកនេះ ពុំមានសាក្សីដែលត្រូវកោះហៅបម្រុងទុកដែលអាចនឹងបន្តធ្វើសវនាការបានទេ។ បញ្ហាទីបី គឺរហូតដល់ពេលនេះអង្គជំនុំជម្រះមិនទាន់បានទទួលនូវរបាយ-ការណ៍វេជ្ជសាស្ត្រពាក់ព័ន្ធនឹងបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី នៅឡើយទេ។ ហើយអង្គជំនុំនឹងពិនិត្យលើរបាយការណ៍នៅថ្ងៃស្អែក ឬក៏ថ្ងៃចន្ទមុនពេលដំណើរការសវនាការ។ ហេតុដូច្នេះ សូមភាគី និងសាធារណជនជ្រាប។

ហើយអង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទពីររូប គឺ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំខ្លួននៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំជនជាប់ចោទទាំងបីរូប រួមទាំងលោក អៀង សារី ផងមកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃចន្ទ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ប្រសិនបើលោក អៀង សារី គាត់មានបញ្ហាសុខភាពធ្ងន់ ឬមធ្យមដែលមិនអាចចូលរួមបាននោះ សូម-- អង្គជំនុំជម្រះនឹងពិនិត្យពិចារណាលើរបាយការណ៍របស់វេជ្ជសាស្ត្រ របស់លោកគ្រូពេទ្យដែលប្រចាំការនៅមណ្ឌលឃុំខ្លួននៃ អ.វ.ត.ក ដើម្បីពិនិត្យសម្រេច ដោយប្រៀបធៀបទៅនឹងបទប្បញ្ញត្តិដែលមានចែងនៅក្នុងវិធាន៨១ អនុវិធាន៥ ផងដែរ។ ដូច្នេះករណីនេះ អង្គជំនុំជម្រះនឹងចាត់ការតាមស្ថានភាពជាក់ស្តែងនៅព្រឹកថ្ងៃចន្ទ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:៤៨ នាទី)*